**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ ស្រុកកោះធំ (ខេត្តកណ្ដាល)

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ **ក. គង់ ស្រីនិ** | សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា** |
| **ក. ឆេន អេនជី** | |


| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលរៀន | ២០២០ |
| ជំនាន់ទី២៤ | ឆ្នាំសរសេរសារណា | ២០២៤ |

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ ស្រុកកោះធំ (ខេត្តកណ្តាល)

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. គង់ ស្រីនិ**

**ក. ឆេន អេនជី**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គង់ ស្រីនិ** និងនាងខ្ញុំឈ្មោះ **ឆេន អេនជី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ឆ្នាំសិក្សា២០២៣-២០២៤។

ជាបឋមនាងខ្ញុំទាំងពីរនាក់ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេ គឺ**លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារហូតដល់ធំធាត់ពេញវ័យ ព្រមទាំងផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជំរុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ថវិកា និងសិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រធ្វើឱ្យកូនចងចាំជានិច្ច ដោយមិនអាចបំភ្លេចបាន។

សូមគោរពថ្លែងអរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលា ព្រមទាំងកម្លាំងកាយកម្លាំងចិត្តដល់នាងខ្ញុំទាំងពីរនាក់ ដើម្បីឱ្យនាងខ្ញុំទាំងពីរនាក់ទទួលបាននូវចំណេះដឹងផ្នែកនីតិសាស្ត្រលើបញ្ហានានាដែលពាក់ព័ន្ធនឹងច្បាប់ជាតិ ព្រមទាំងច្បាប់អន្តរជាតិ ជាពិសេសសូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យជំនួយបណ្ឌិត អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យណែនាំដើម្បីធ្វើឱ្យមាននូវដំណើរការនៃការតាក់តែង កិច្ចការស្រាវជ្រាវនេះឡើង ប្រកបដោយភាពជោគជ័យ។ ជាពិសេសទៀតនោះ គាត់បានចំណាយកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ និងអនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យកិច្ចការស្រាវជ្រាវមួយនេះ បានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតា ឥន្ទព្រហ្មជួយឱ្យប្រទេសជាតិយើង រួមទាំងប្រជាជនកម្ពុជាទាំងអស់ជួបតែសន្តិភាព សុវត្ថិភាព និងការអភិវឌ្ឍរីកចម្រើនឆ្ពោះទៅមុខជានិរន្តន៍។

# អារម្ភកថា

បន្ទាប់ពីនាងខ្ញុំទាំងពីរបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលបួនឆ្នាំកន្លងមកនេះ នាងខ្ញុំទាំងពីរនាក់ គឺទទួលនូវចំណេះដឹង ទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះផងដែរ។ ជាក់ស្តែងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ គឺជាស្នាដៃដែលអាចវាស់វែងស្ទង់សមត្ថភាព និងចំណេះដឹងរបស់នាងខ្ញុំទាំងពីរដែលមានតាំងពីមុនមក និងការសិក្សាស្រាវជ្រាវបន្ថែមទៀតនៅលើចំណុចដែលខ្វះខាត។ កត្តាទាំងនេះហើយ ដែលជាហេតុបណ្តាលឱ្យនាងខ្ញុំទាំងពីរបាន ពិភាក្សាគ្នាសម្រេចចិត្តក្នុងការជ្រើសរើសប្រធានបទទាក់ទងទៅនឹងនីតិនគរូបនីយកម្ម និងសំណង់ដែលស្តីពី "**ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ ខេត្តកណ្តាល**" មកធ្វើជាប្រធានបទ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

កម្មវត្ថុសំខាន់មួយទៀតនោះ គឺចង់ឱ្យនិស្សិតជំនាន់ក្រោយ និងសាធារណជនបានយល់ដឹងអំពីបញ្ហានៃការរៀបចំសណ្តាប់ធ្នាប់ ព្រមទាំងសោភ័ណភាពរបស់ស្រុកកោះធំ ដែលប្រកបទៅដោយ ភាពស្ងប់ស្ងៀម មានសន្តិសុខ សុវត្ថិភាពល្អ បរិស្ថានស្អាត ការរស់នៅដោយគ្មានការរំខាន ព្រមទាំងគ្មានការបំពុលផ្សេងៗគួបផ្សំជាមួយនឹងវិធានការក្នុងការដោះស្រាយមួយចំនួន ដែលកើតមានឡើងក្នុងការរៀបចំសណ្តាប់ធ្នាប់ស្រុកកោះធំផងដែរ។ ជាក់ស្តែង នាងខ្ញុំទាំងពីរមានគោលបំណងរួមគ្នា គឺចង់បង្ហាញអំពីសក្តានុពលនៃការអភិវឌ្ឍ រួមទាំងភាពរីកចម្រើនដែលមាននៅក្នុងស្រុកកោះធំ។ លើសពីនេះទៅទៀត គឺចង់ឱ្យនិស្សិត ព្រមទាំងសាធារណជនគ្រប់រូបបានយល់ដឹងបន្ថែមអំពីការអភិវឌ្ឍ ការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធរបស់ស្រុកកោះធំ និងជាគន្លឹះមួយដែលអាចជួយសម្រួលដល់ប្អូនៗនិស្សិតជំនាន់ក្រោយក្នុងការសិក្សាស្វែងយល់បន្ថែម ព្រមទាំងអាចយកធ្វើជាឯកសារពិគ្រោះបានផងដែរ។

មុននឹងបញ្ចប់ នាងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណ និងគោរពទទួលនូវរាល់កំហុសឆ្គងណាមួយដោយអចេតនាក្តី ឬមានចំណុចខ្វះខាតនៅត្រង់ចំណុចណាមួយ សូមមេត្តាខន្តី អភ័យទោស ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំទាំងពីរនាក់។ ជាមួយគ្នានេះដែរ នាងខ្ញុំទាំងពីរនាក់ សូមទទួលយកនូវរាល់មតិរិះគន់កែលម្អ នូវរាល់ចំណុចខ្វះខាតទាំងឡាយក្នុងន័យស្ថាបនា ដើម្បីឱ្យការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំទាំងពីរនាក់មាននូវអត្ថន័យគ្រប់គ្រាន់ និងកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរដល់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ព្រមទាំងមិត្តនិស្សិត អ្នកអានទាំងអស់ទទួលបានភាពជោគជ័យគ្រប់ភារកិច្ច កម្លាំងពលំមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាវាងវៃមានអាយុយឺនយូរ ព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការ **គឺអាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រទី

**សេចក្តីផ្តើម** ........................................................................................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការរៀបចំស្រុកកោះធំ

**១.១. ទិដ្ឋភាពទូទៅនៃស្រុកកោះធំ** ........................................................................ ៤

១.១.១. ទីតាំងភូមិសាស្ត្រស្រុកកោះធំ ................................................................ ៤

១.១.២. ដង់ស៊ីតេប្រជាជន ...................................................................................... ៥

១.១.៣. ស្ថានភាពសេដ្ឋកិច្ច ..................................................................................... ៥

**១.២. រចនាសម្ព័ន្ធគ្រប់គ្រងស្រុកកោះធំ** ................................................................. ៨

១.២.១. សមាសភាព ............................................................................................. ៩

១.២.១.១. ក្រុមប្រឹក្សាស្រុក ................................................................................ ៩

១.២.១.២. គណៈអភិបាលស្រុក ......................................................................... ១០

១.២.២. តួនាទី និងភារកិច្ច ................................................................................... ១១

១.២.២.១. ក្រុមប្រឹក្សាស្រុក .............................................................................. ១១

១.២.២.២. គណៈអភិបាលស្រុក ......................................................................... ១៥

**១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំស្រុកកោះធំ** .................................................. ១៧

១.៣.១. កំណើនប្រជាជន ..................................................................................... ១៧

១.៣.២. ភាពក្រីក្រ .............................................................................................. ១៨

១.៣.៣. ការដាក់សម្ពាធបរិស្ថាន............................................................................ ១៩

១.៣.៤. គមនាគមន៍ ........................................................................................... ២០

# ជំពូកទី២

# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ

**២.១. ការរៀបចំស្រុកកោះធំ** ........ ២១

២.១.១. ការរៀបចំសោភ័ណភាពស្រុកកោះធំ ........ ២១

២.១.១.១. សោភ័ណភាពពេលថ្ងៃ ........ ២១

២.១.១.២. សោភ័ណភាពពេលយប់ ........ ២៣

២.១.២. ការរៀបចំសណ្តាប់ធ្នាប់ស្រុកកោះធំ ........ ២៤

២.១.២.១. សន្តិសុខ ........ ២៤

២.១.២.២. ភាពស្ងប់ស្ងៀម ........ ២៥

២.១.២.៣. គ្មានការបំពុលបរិស្ថាន ........ ២៦

**២.២. បច្ចុប្បន្នភាព នៃការរៀបចំស្រុកកោះធំ** ........ ៣០

២.២.១. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ ........ ៣១

២.២.២. ការអភិវឌ្ឍវិស័យកសិកម្ម ........ ៣៣

២.២.៣. ការអភិវឌ្ឍវិស័យសុខាភិបាល ........ ៣៥

២.២.៤. ការអភិវឌ្ឍវិស័យអប់រំ ........ ៣៧

២.២.៥. ការអភិវឌ្ឍវិស័យធនធានទឹក ........ ៣៨

**២.៣. បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តន៍បន្ត** ........ ៤០

២.៣.១. បញ្ហាប្រឈម និងដំណោះស្រាយ ........ ៤០

២.៣.១.១. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៤១

២.៣.១.២. បញ្ហាបរិស្ថាន ........ ៤៣

២.៣.២. ទិសដៅអនុវត្តន៍បន្ត ........ ៤៥

២.៣.២.១. ផ្នែករដ្ឋបាល និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ ............................................ ៤៥

២.៣.២.២. ផ្នែកសេដ្ឋកិច្ច ............................................................................................... ៤៦

២.៣.២.៣. ផ្នែកសង្គម................................................................................................... ៤៦

**សេចក្ដីសន្និដ្ឋាន**................................................................................................... ៤៨

**អនុសាសន៍**............................................................................................................ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ខេត្តកណ្តាល គឺជាខេត្តមួយដែលស្ថិតនៅជាប់នឹងជាយទីក្រុងភ្នំពេញ។ ខេត្តនេះ មានសក្តានុពលទៅលើវិស័យមួយចំនួនដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យទេសចរណ៍ ដែលជាវិស័យគោលចម្បងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្តឱ្យទទួលបាននូវការរីកចម្រើន។ ចំណែកឯវិស័យហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តកណ្តាលវិញ ក៏មានផ្លូវជាតិ សាលារៀន មន្ទីរពេទ្យ ស្ពានថ្នល់សំខាន់ៗជាច្រើនខ្សែថែមទៀត សម្រាប់តភ្ជាប់ទៅកាន់បណ្តាខេត្តនានាដើម្បីសម្របសម្រួលដល់ការដឹកជញ្ជូន ការនាំចូល នាំចេញទំនិញ និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។

ខេត្តកណ្តាលស្ថិតនៅប៉ែកខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះមានក្រុងចំនួន ០៣ និងមានស្រុកចំនួន ១០។ ក្នុងនោះដែរ ស្រុកកោះធំ ជាស្រុកមួយនៅក្នុងខេត្តកណ្តាលដែលមានសក្តានុពល និងមានការអភិវឌ្ឍដោយហេតុថា រដ្ឋបាលស្រុកកោះធំ បានខិតខំយកចិត្តទុកដាក់អភិវឌ្ឍន៍ ក៏ដូចជាគិតគូរទៅលើការរៀបចំកែលម្អសោភ័ណភាព សណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាព បរិស្ថាន និងខិតខំរិះរកវិធីសាស្ត្រដែលធ្វើយ៉ាងណាឱ្យការរៀបចំក្នុងស្រុករបស់ខ្លួនកាន់តែល្អប្រសើរ និងបានខិតខំរិះរកនូវដំណោះស្រាយ ដែលទាក់ទងទៅនឹងបញ្ហាប្រឈមផ្សេងៗដែលកើតមានឡើង ដើម្បីឱ្យស្របទៅតាមបច្ចុប្បន្នភាព និងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយស្តង់ដារ បរិស្ថានស្អាត ដើម្បីបង្ហាញពីសក្តានុពលភាព ការអភិវឌ្ឍ និងការរីកចម្រើននៅក្នុងស្រុករបស់ខ្លួន។

រាល់បញ្ហាប្រឈមនានាដែលបានកើតឡើង រាជរដ្ឋាភិបាល ព្រមទាំងរដ្ឋបាលស្រុកកោះធំ បានខិតខំកែលម្អ រិះរកមធ្យោបាយនានា ក្នុងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងស្រុករបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរ និងមានរបៀបរៀបរយ ដែលជាកត្តាដ៏សំខាន់ក្នុងការលើកកម្ពស់ក៏ដូចជា ជួយជំរុញឱ្យកាន់តែមានការអភិវឌ្ឍនៅក្នុងស្រុកកោះធំបន្ថែមទៀត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីលើកកម្ពស់ ក៏ដូចជាជំរុញឱ្យស្រុកកោះធំកាន់តែមានភាពរីកចម្រើន និងការអភិវឌ្ឍទៅមុខបន្ថែមនោះ ដូច្នេះហើយស្រុកកោះធំចាំបាច់ត្រូវតែយកចិត្តទុកដាក់ទៅលើការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ឱ្យបានកាន់តែល្អថែមទៀត។ ហេតុដូចនេះ ដើម្បីឱ្យសាធារណជនទាំងអស់បានយល់ដឹងកាន់តែច្បាស់ពីស្រុកកោះធំនាងខ្ញុំទាំងពីរនាក់ ក៏បានចោទជាសំណួរថា៖

- តើស្រុកកោះធំបានធ្វើការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់យ៉ាងដូចម្តេច?
- តើនៅពេលបច្ចុប្បន្នស្រុកកោះធំមានការអភិវឌ្ឍអ្វីខ្លះ?
- តើស្រុកកោះធំមានបញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តន៍បន្តអ្វីខ្លះនាពេលអនាគត?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណង ក្នុងការកំណត់យកប្រធានបទស្រាវជ្រាវ ដែលទាក់ទងទៅនឹងនីតិនគរូបនីយកម្មដែលស្តីអំពី " ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ ខេត្តកណ្តាល " យកមកធ្វើការសរសេរជាសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំទាំងពីរនាក់ គឺដើម្បីចង់បង្ហាញឱ្យឃើញពីផែនការក្នុង ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងស្រុកកោះធំ តួយ៉ាងស្រុកនេះមាន ការរៀបចំអភិវឌ្ឍន៍ស្រុកប្រកបដោយភាពច្នៃប្រឌិត និងអនុវត្តន៍ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ បន្ថែមពីនេះទៀត ស្រុកកោះធំ ក៏បានរៀបចំឱ្យមានភាពងាយស្រួលសមស្របតាមការរស់នៅ និងបំពេញនូវតម្រូវការរបស់ប្រជាពលរដ្ឋដោយបង្កើតឱ្យមាន ផ្សារ ហាងលក់ទំនិញគ្រប់ប្រភេទ ភោជនីយដ្ឋាន កន្លែងកម្សាន្ត និងរមណីយដ្ឋានផងដែរ។ មួយវិញទៀត នាងខ្ញុំទាំងពីរមានគោលបំណងក្នុងការបង្កើតស្នាដៃស្រាវជ្រាវមួយនេះឡើង ដើម្បីឱ្យការសិក្សាស្រាវជ្រាវមួយនេះ បានក្លាយជាឯកសារជំនួយស្មារតីបន្ថែមសម្រាប់ការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាគ្រប់ៗរូប។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ នាងខ្ញុំទាំងពីរបានធ្វើការស្រាវជ្រាវ និងបានផ្តោតសំខាន់ទៅលើការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងស្រុកកោះធំនៃខេត្តកណ្តាលតែប៉ុណ្ណោះ ដោយពុំមានវិសាលភាពគ្របដណ្តប់លើខេត្តកណ្តាលទាំងមូលនោះទេ ហើយនាងខ្ញុំទាំងពីរនាក់ចង់ បង្ហាញពីអ្វីដែលទាក់ទងទៅនឹងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្នុងស្រុកកោះធំ។

## ៥. សារសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវដែលទាក់ទងទៅនឹងប្រធានបទខាងលើនេះ គឺពិតជាមានសារសំខាន់ណាស់ និងមានសារប្រយោជន៍ ចំពោះនាងខ្ញុំទាំងពីរនាក់ ជាពិសេសចំពោះសាធារណជនក៏ដូចជា មិត្តនិស្សិត មិត្តអ្នកអានមិត្តអ្នកស្រាវជ្រាវគ្រប់ៗរូប សម្រាប់ជាឯកសារជំនួយស្មារតីក្នុងការសិក្សាស្រាវជ្រាវ ស្វែងយល់បន្ថែមឱ្យបានកាន់តែស៊ីជម្រៅ ដែលទាក់ទងទៅនឹងផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ និងការរៀបចំស្រុកមួយដើម្បីធ្វើយ៉ាងណាឱ្យមានសោភ័ណភាព និងមានសណ្តាប់ធ្នាប់របៀបរៀបរយល្អ ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រទេសជាតិទាំងមូលផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទ "ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ (ខេត្តកណ្តាល)" នេះនាងខ្ញុំទាំងពីរនាក់បានធ្វើការសិក្សាស្រាវជ្រាវទៅលើគ្រប់ឯកសារដែលពាក់ព័ន្ធនានាដែលបានមកពីឯកសារយោង តាមរយៈបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សៀវភៅតែងនិពន្ធ គេហទំព័រផ្សេងៗ ក៏ដូចជា ឯកសារមួយចំនួនដែលបានមកពីការចុះស្រាវជ្រាវដោយផ្ទាល់នៅឯសាលាស្រុកកោះធំផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សារបស់ នាងខ្ញុំទាំងពីរនាក់ បានធ្វើការបែងចែកជាពីរជំពូករួមមាន៖

- **ជំពូកទី១ "សញ្ញាណទូទៅនៃការរៀបចំស្រុកកោះធំ"**៖ នៅក្នុងជំពូកទី១នេះ នាងខ្ញុំទាំងពីរនាក់បានធ្វើការបែងចែកជាបីចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពីទិដ្ឋភាពទូទៅនៃស្រុកកោះធំ ចំណុចទី២ និយាយអំពីរចនាសម្ព័ន្ធគ្រប់គ្រងស្រុកកោះធំ និងចំណុចទី៣ និយាយអំពីកត្តាដែលជំរុញឱ្យមានការរៀបចំស្រុកកោះធំ ។
- **ជំពូកទី២ "ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ"**៖ នៅក្នុងជំពូកទី២នេះនាងខ្ញុំទាំងពីរនាក់ បានធ្វើការបែងចែកជាបីចំណុចបន្ថែមទៀតដូចគ្នា ដោយចំណុចទី១ និយាយអំពីការរៀបចំស្រុកកោះធំ ចំណុចទី២ និយាយអំពីបច្ចុប្បន្នភាពនៃការរៀបចំស្រុកកោះធំ និងចំណុចទី៣ និយាយអំពីបញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តន៍បន្ត ក្នុងស្រុកកោះធំ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំ

# ស្រុកកោះធំ

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំស្រុកកោះធំ

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះសង្កេតឃើញថា ស្រុកកោះធំមានការអភិវឌ្ឍ និងការរៀបចំទៅលើសោភ័ណភាព និងសណ្ដាប់ធ្នាប់បានយ៉ាងល្អប្រសើរ។ នៅក្នុងនោះ មានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់រាជរដ្ឋាភិបាល រដ្ឋបាលស្រុកកោះធំ និងអាជ្ញាធរដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ទាំងអស់ បានធ្វើការរៀបចំសោភ័ណភាព សន្តិសុខ សុខសុវត្ថិភាព របៀបរៀបរយ និងសុខុមាលភាពដល់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះ រដ្ឋបាលស្រុកកោះធំ បានយកចិត្តទុកដាក់រៀបចំ កែលម្អ ជួសជុល សាងសង់ផ្លូវបេតុង រៀបចំប្រព័ន្ធធារាសាស្ត្រ ការដាក់ភ្លើងបំភ្លឺនៅតាមដងផ្លូវ ភូមិ ឃុំ និងការដាំដើមឈើតាមផ្លូវ ឬសួនច្បារជាដើម ដើម្បីបង្កើនសោភ័ណភាព សុខសុវត្ថិភាព និងភាពងាយស្រួលជូនទៅដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក។ ទោះបីជានៅមានផ្នែកខ្លះនៅសេសសល់ ការអនុវត្តពុំទាន់មានប្រសិទ្ធិភាព និងមិនទាន់មានការផ្លាស់ប្តូរក៏ដោយក្តី ក៏រដ្ឋបាលស្រុកកោះធំខិតខំរកមធ្យោបាយ និងដំណោះស្រាយ ដើម្បីមកកែលម្អ និងបំពេញបន្ថែម។ តាមរយៈការខិតខំប្រឹងប្រែងរបស់រដ្ឋបាលស្រុក រួមជាមួយរាជរដ្ឋាភិបាល អាជ្ញាធរដែលមានពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសនោះមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋផងដែរនោះ បានជំរុញឱ្យស្រុកកោះធំមានការអភិវឌ្ឍជាបន្តបន្ទាប់ ដោយបានរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់បានកាន់តែល្អប្រសើរ និងរីកចម្រើនទៅមុខបន្ថែមទៀត។

## ១.១. ទិដ្ឋភាពទូទៅនៃស្រុកកោះធំ

### ១.១.១. ទីតាំងភូមិសាស្ត្រស្រុកកោះធំ

ស្រុកកោះធំ ជាស្រុកមួយក្នុងចំណោមក្រុង ស្រុកទាំង១៣ របស់ខេត្តកណ្ដាល មានទីតាំងស្ថិតនៅប៉ែកខាងត្បូងនៃរាជធានីភ្នំពេញ មានចំងាយ ៥៤គ.ម។ លាតសន្ធឹងតាមបណ្ដោយដងទន្លេបាសាក់មានប្រវែងពីជើងទៅត្បូង ១៩គ.ម និងប្រវែងពីលិច ទៅកើត ១៥.៥គ.ម។ បន្ថែមពីនេះទៅទៀត ស្រុកកោះធំ មានផ្ទៃដីសរុប ២១៥.៣០គីឡូម៉ែត្រការ៉េ និងមានព្រំប្រទល់ដូចខាងក្រោម៖

- ខាងជើងទល់នឹងស្រុកស្អាង ខេត្តកណ្ដាល
- ខាងកើតទល់នឹងស្រុកលើកដែក ខេត្តកណ្ដាល
- ខាងត្បូងទល់នឹងក្រុងសំពៅពូន ខេត្តកណ្ដាល
- ខាងលិចទល់នឹងស្រុកព្រែកប្បាស ខេត្តតាកែវ។[១]

[១] របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាល ស្រុកកោះធំ ប្រចាំខែមីនា ឆ្នាំ២០២៤

- ស្រុកកោះធំមានឃុំចំនួន ០៦ឃុំ ស្មើនឹង ៦០ភូមិ

| ស្រុកកោះធំ | | | |
|---|---|---|---|
| ល.រ | ឈ្មោះឃុំជាអក្សរខ្មែរ | ឈ្មោះឃុំជាអក្សរឡាតាំង | ចំនួនភូមិ |
| ១ | ឃុំកោះធំ ក | Kaoh Thum Ka | ៧ |
| ២ | ឃុំកោះធំ ខ | Kaoh Thum Kha | ៥ |
| ៣ | ឃុំកំពង់កុង | Kampong Kong | ១២ |
| ៤ | ឃុំពោធិបាន | Pouthi Ban | ៩ |
| ៥ | ឃុំលើកដែក | Leuk Daek | ១៥ |
| ៦ | ឃុំព្រែកថ្មី | Preaek Thmei | ១២ |

### ១.១.២. ជន់ស៊ីតេប្រជាជន

គិតត្រឹមខែមីនា ឆ្នាំ២០២៤ នៅក្នុងស្រុកកោះធំ មានប្រជាជនសរុបចំនួនប្រមាណ ៨៤,៥៤០នាក់ ដែលស្មើនឹងប្រមាណ ២០,០៧២គ្រួសារ ដោយនៅក្នុងនោះស្រីមានចំនួនប្រមាណ ៤៤,៣៨៧នាក់ និងប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើងមានចំនួនប្រមាណ ៥៦,៩៧៩នាក់ ស្រីប្រមាណ ២៩,៧៥០នាក់។[២]

### ១.១.៣. ស្ថានភាពសេដ្ឋកិច្ច

ស្រុកកោះធំ ជាស្រុកស្ថិតនៅជាប់ដងទន្លេបាសាក់ និងមានបឹងបួរ ព្រែកជាច្រើនដែលជាប្រភពទឹកសំខាន់ ដើម្បីបម្រើឱ្យការប្រើប្រាស់ប្រចាំថ្ងៃ និងជាប្រព័ន្ធធារាសាស្ត្រ ដ៏សំខាន់សម្រាប់វិស័យកសិកម្មដូចជាការស្រោចស្រព ស្រូវ និងដំណាំរួមផ្សំផ្សេងៗរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក។ ក្រៅពីវិស័យកសិកម្មហើយនោះ ប្រជាជននៅក្នុងស្រុកកោះធំ ក៏បានប្រកបមុខរបរផ្សេងៗទៀតសម្រាប់ជីវភាពប្រចាំថ្ងៃដូចជា ការធ្វើអាជីវកម្ម និងសិប្បកម្មជាដើម ក្នុងការបង្កើនកម្រិតជីវភាពគ្រួសារ ព្រមទាំងសេដ្ឋកិច្ចក្នុងស្រុកផងដែរ។

- ❖ **កសិកម្ម**

ស្ថានភាពដីកសិកម្មនៅក្នុងស្រុកកោះធំបានចែកជាពីរ គឺតំបន់ (ទី១) ប៉ែកខាងលិចមាន ឃុំកោះធំ ខ និងឃុំព្រែកថ្មីដែលភាគច្រើនធ្វើ អនុផលស្វាយ និងដំណាំរួមផ្សំដូចជា ពោត សណ្តែក បន្លែ ហើយតំបន់ (ទី២) ប៉ែកខាងកើតមាន ឃុំពោធិបាន ឃុំកំពង់កុង ឃុំលើកដែក និងឃុំកោះធំ ក ជាតំបន់លិចទឹក ដែលភាគច្រើនធ្វើ

---

[២] របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាល ស្រុកកោះធំ ប្រចាំខែមីនា ឆ្នាំ២០២៤

ស្រូវប្រាំង អនុផល និងដំណាំរួមផ្សំដូចជា ពោត សណ្តែក ដំឡូង និងបន្លែគ្រប់មុខ ព្រមទាំងជាតំបន់នេសាទផងដែរ។ កសិករដែលរស់នៅតំបន់ប៉ែកខាងកើត និងតំបន់ប៉ែកខាងលិច ភាគច្រើនមានកម្រិតជីវភាពរស់នៅប្រហាក់ប្រហែលគ្នាដោយសារតែពួកគាត់មានមុខរបរច្រើនដូចគ្នា។ ចំពោះផ្ទៃដីសរុបសម្រាប់បង្កបង្កើនផលស្រូវមានចំនួន ៦៧៧៥.៨ហិកតា ដោយនៅក្នុងនោះផ្ទៃដីស្រូវប្រាំង ៦,២៦៩ហិកតា និងផ្ទៃដីស្រូវវស្សា ៧៩៦ហិកតា ហើយទិន្នផលស្រូវសរុបជាមធ្យម ៣.៩តោន/១ហិកតា ដែលបរិមាណស្រូវសរុបស្មើនឹង ២៦,១០០.៩តោន ហើយចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីដំណាំស្រូវទទួលបាន ៧៥.២ (ដុល្លា)។ ទន្ទឹមនឹងគ្នានេះ ផ្ទៃដីដាំដុះទាំងស្រូវប្រាំង និងវស្សា ក៏មិនទាន់ធ្វើអស់នៅឡើយ ដោយពឹងផ្អែកទៅលើកត្តាធម្មជាតិ និងការស្តាប្រឡាយ។ ចំពោះដំណាំរយៈពេលខ្លីមានដូចជា ពោតផ្ទៃដីដែលដាំបានមាន ៧៧៨ហិកតា សណ្តែកបាយ ៦២៨ហិកតា ដំឡូងមី ៣ហិកតា ដំឡូងផ្វា ៨០ហិកតា និងដំណាំរយៈពេលវែងនៅក្នុងនោះមាន ស្វាយចន្ទី ៦ហិកតា និងស្វាយ ៣៤៩ហិកតា។ បន្ទាប់ពី ការធ្វើស្រែចំការហើយនោះ ប្រជាជននៅក្នុងស្រុកកោះធំ ក៏មានការចិញ្ចឹមសត្វផងដែរដូចជា គោ ជ្រូក មាន់ ទា ពពែ ត្រីជាដើម។[៣]

❖ **អាជីវកម្ម**

ក្រៅពីការធ្វើកសិកម្មហើយនោះ ប្រជាពលរដ្ឋនៅក្នុងស្រុកកោះធំបានប្រកបអាជីវកម្មដូចជា ផលិតកម្ម និងសេវាកម្ម ដោយឃើញមានទីតាំងផលិតកម្ម និងសេវាកម្មសរុបចំនួន ១,២៣១ទីតាំងដែលប្រជាពលរដ្ឋបានធ្វើអាជីវកម្ម។ នៅក្នុងស្រុកកោះធំមានផ្សារសរុបចំនួន ១១ ដែលបានបែងចែកផ្សារជា ០២ប្រភេទ គឺផ្សាររបស់រដ្ឋ និងផ្សាររបស់ឯកជន ដែលនៅក្នុងនោះមាន ផ្សារកោះធំ ជាផ្សាររបស់រដ្ឋ ហើយក៏មានផ្សារឯកជនជាច្រើនកន្លែងដែលស្ថិតនៅតាមបណ្តាឃុំដូចជា ផ្សារក្រោលគោ ផ្សារសាលាឃុំ ផ្សារចាមក្រោម ផ្សារព្រែកតាដុល ផ្សារព្រែកគល់ ផ្សារព្រែកហង់ ផ្សារកំពង់កុង ផ្សារលើកដែក ផ្សារព្រែកបិ និងផ្សារសំប៉ាន។ ជាក់ស្តែង ការធ្វើអាជីវកម្មនៅក្នុងស្រុកកោះធំមាន ផលិតកម្ម និងសេវាកម្មជាច្រើនទីតាំងដូចខាងក្រោម៖

- **ផលិតកម្ម** មានម៉ាស៊ីនកិនស្រូវខ្នាតមធ្យម ឬធំចំនួន ៣១ទីតាំង ការធ្វើអាជីវកម្មផ្តល់ថាមពលចំនួន ៣២ទីតាំង សិប្បកម្មត្បាញរវៃចំនួន ០៣ទីតាំង សិប្បកម្មផលិតពីផ្តៅ ឬស្សី ល្ពាក់ចំនួន ០៣ទីតាំង សិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើចំនួន ១៤ទីតាំង សិប្បកម្មចម្លាក់ផលិតពីស្ពាន់ ថ្ម ស្បែកចំនួន ០២ទីតាំង សិប្បកម្មផលិតពីជ័រចំនួន ០១ទីតាំង សិប្បកម្មផលិតទឹកសុទ្ធចំនួន ១៣ទីតាំង សិប្បកម្មកែច្នៃ ឬវេចខ្ចប់ផលនេសាទចំនួន ០១ទីតាំង និងសិប្បកម្មផ្សេងៗចំនួន ០២ទីតាំង។

[៣] ឯកសារព័ត៌មានស្ថានភាព ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ស្រុកកោះធំ ឆ្នាំ២០២៤

- **សេវាកម្ម** មានកន្លែងលក់គ្រឿងបរិភោគ និងទំនិញប្រើប្រាស់ចំនួន ៤០៩ទីតាំង លក់ខោអាវស្បែកជើង និងគ្រឿងក្រអូបចំនួន ១០៧ទីតាំង លក់គ្រឿងអលង្ការចំនួន ៤១ទីតាំង លក់គ្រឿងអេឡិចត្រូនិកចំនួន ៣២ទីតាំង លក់គ្រឿងសង្ហារឹម (តុ ទូ កៅអី) ចំនួន ២៣ទីតាំង លក់សម្ភារៈសំណង់ចំនួន ៣៥ទីតាំង លក់សម្ភារៈសិក្សា និងកីឡាចំនួន ១៩ទីតាំង សេវាកម្មខ្នាតតូច (កាត់សក់ ម៉ាស្សារ...) ចំនួន ៧២ទីតាំង អាជីវកម្មខ្នាតតូច (លក់បាយ គុយទាវ...) ចំនួន ១៨០ទីតាំង ភោជនីយដ្ឋានចំនួន ០៥ទីតាំង ជួសជុល ឬលក់កង់ម៉ូតូចំនួន ៩៤ទីតាំង ជួសជុល ឬលក់គ្រឿងយន្ត និងឧបករណ៍កសិកម្មចំនួន ៣៧ទីតាំង ជួសជុលគ្រឿងអេឡិចត្រូនិកចំនួន ២៦ទីតាំង ឱសថស្ថាន និងឱសថស្ថានរងចំនួន ២៥ទីតាំង គ្លីនិកចំនួន ១២ទីតាំង និងផ្ទះសំណាក់ចំនួន ១២ទីតាំង។[៤]

បន្ថែមពីនោះទៀត នៅក្នុងស្រុកកោះធំមាន វត្តទួលរាជា ជាវត្តព្រះពុទ្ធសាសនាដ៏ស៊ីមស្តែមួយ ដែលមានសំណង់ពុទ្ធសាសនាដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា។ វត្តទួលរាជាសម្បូរទៅដោយសមិទ្ធិផល និងមានព្រះពុទ្ធរូបដ៏ធំស៊ីមស្តែ ដែលផុសចេញនៅលើទីទួលខ្ពស់មួយស្របតាមមាត់ទន្លេបាសាក់នៅត្រើយខាងកើត ស្ថិតនៅក្នុងភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ដោយតំនប់នេះជារមណីយដ្ឋានបែបព្រះពុទ្ធសាសនាមួយដែលបានទាក់ទាញមនុស្សជាច្រើនឱ្យចូលមកទស្សនា ដែលជាចំណែកក្នុងការជួយលើកស្ទួយកម្រិតជីវភាព និងសេដ្ឋកិច្ចរបស់ប្រជាជននៅស្រុកកោះធំមួយកម្រិតទៀតផងដែរ។ វត្តទួលរាជា ស្ថិតនៅចម្ងាយពីក្រុងតាខ្មៅប្រមាណជា ៣០គីឡូម៉ែត្រ ដោយឆ្លងស្ពានព្រែកសំរោងទៅត្រើយខាងកើត តាមផ្លូវជាតិមាត់ទន្លេរហូតទៅដល់វត្តទួលរាជា ឬមួយក៏ធ្វើដំណើរពីតាខ្មៅតាមផ្លូវជាតិលេខ២១ កាត់ស្រុកស្អាង ស្រុកកោះធំ រួចឆ្លងស្ពានកោះធំ ហើយត្រឡប់ថយក្រោយបន្តិចនឹងបានឃើញ វត្តទួលរាជា។ ព្រះពុទ្ធរូបទ្រង់គង់ពែនព្រះភ្នែនមានកម្ពស់ខ្ពស់ត្រដែតត្រដឹម ដែលអាចធ្វើឱ្យយើងសម្លឹងមើលឃើញពីចម្ងាយហាក់បីដូចជាផ្ទាំងគំនូរដ៏ល្អវិចិត្រ ដែលផុសចេញនៅកណ្តាលវេហា។ ព្រះពុទ្ធរូបដ៏ធំសម្បើមតំណាងឱ្យព្រះសមណគោត្តបរមគ្រូ ដែលព្រះអង្គទ្រង់បានឈ្នះអស់មារសត្រូវ។ ចំណែកឯព្រះពុទ្ធបដិមាប្រក់នាគទ្រង់គង់ពែនព្រះភ្នែន នៅផ្នែកខាងស្តាំ បើសម្លឹងមើលចំពីមុខនឹងឃើញថាពិតជាមានសោភ័ណភាពស្រស់ស្អាតគួរជាទីជ្រះថ្លានៃពុទ្ធសាសនិកជនគ្រប់មជ្ឈដ្ឋាន និងមានរចនាបថខ្មែរដ៏ល្អឥតខ្ចោះ ដែលឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិខ្មែរពិតៗ ក្រៅពីនេះ ក៏មានសំណង់យ៉ាងច្រើនរាប់មិនអស់ទៀតត្រូវបានសាងសង់នៅទីនោះ។[៥]

[៤] ឯកសារព័ត៌មានស្ថានភាព ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ស្រុកកោះធំ ឆ្នាំ២០២៤

[៥] គេហទំព័រ https://www.popular.com.kh/tours/127956.html/ ចូលទស្សនានៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤

## ១.២. រចនាសម្ព័ន្ធគ្រប់គ្រងស្រុកកោះធំ

ដើម្បីឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មួយទទួលបាននូវសោភ័ណភាព សណ្តាប់ធ្នាប់ល្អ រួមទាំងមានសុខសុវត្ថិភាព នោះចាំបាច់ឱ្យមានការគ្រប់គ្រងមួយដែលច្បាស់លាស់ ដោយត្រូវបង្កើត និងរៀបចំឱ្យមាននូវរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលមួយ ដើម្បីធ្វើការដឹកនាំ ព្រមទាំងគ្រប់គ្រងទៅតាមតួនាទី ភារកិច្ចដែលច្បាប់បានកំណត់។ ដោយនៅក្នុងរចនាសម្ព័ន្ធនោះបង្កើតឱ្យមាន ក្រុមប្រឹក្សា និងគណៈអភិបាល ដើម្បីរួមសហការគ្នាក្នុងការអនុវត្ត និងចេញនូវសេចក្តីសម្រេចមួយ ដែលជាកត្តាជួយជំរុញក្នុងការអភិវឌ្ឍ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ របស់ខ្លួន។ ជាក់ស្តែង នៅក្នុងរដ្ឋបាលស្រុកកោះធំ ក៏បានបង្កើត រៀបចំ និងបែងចែកនូវរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុករបស់ខ្លួនផងដែរ ក្នុងនោះមាន ក្រុមប្រឹក្សាស្រុក និងគណៈអភិបាល ដើម្បីធ្វើការអនុម័តនូវកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ សម្រាប់តាមដានអំពីស្ថានភាពជាក់ស្តែងនៅក្នុងស្រុកកោះធំ និងផែនការសម្រាប់អភិវឌ្ឍន៍បន្តនៅឆ្នាំបន្ទាប់។ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ គឺដើម្បីបំលែងខ្លឹមសារនៃផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌឱ្យទៅជាគម្រោង សកម្មភាព ឬសេវាជាក់ស្តែង សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍន៍ នៅក្នុងក្រុង ស្រុក ខណ្ឌ សម្រាប់រយៈពេលបីឆ្នាំ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ពាក្យថា បីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ មានន័យថា កម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ គឺជាផែនការដែលឆ្លុះបញ្ចាំងនូវគម្រោង ឬសេវាជាអាទិភាពតាមបណ្តាឆ្នាំនីមួយៗក្នុងរយៈពេលបីឆ្នាំ និងស្របនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម បីឆ្នាំ របស់រដ្ឋបាលក្រុង។ ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះនាំឱ្យមានភាពងាយស្រួលក្នុងការបង្ហាញឱ្យឃើញនូវអ្វីដែលបម្រុងនឹងអនុវត្តបន្តទៀត នៅឆ្នាំខាងមុខដែលហាក់ដូចជាការជំរុញឱ្យមាននិរន្តរភាពយូរអង្វែងសម្រាប់គម្រោងនីមួយៗ។ កម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ ត្រូវការពិនិត្យ និងរៀបចំឡើងវិញជារៀងរាល់ឆ្នាំ។[៦] ជាមួយគ្នានេះដែរ ចំពោះផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា និងតម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។[៧]

---

[៦] សៀវភៅណែនាំ ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ខែសីហា ឆ្នាំ២០១៤, ទំព័រទី១-២

[៧] សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ស្រុក, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ខែមីនា ឆ្នាំ២០១៧, ទំព័រទី១

### ១.២.១. សមាសភាព

នៅក្នុងរដ្ឋបាលស្រុកកោះធំ មានសមាសភាពពីរ គឺក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកក្នុងការគ្រប់គ្រង ដឹកនាំ រួមទាំងការងារទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកទាំងមូល។

**រចនាសម្ព័ន្ធរដ្ឋបាលស្រុកកោះធំ**




#### ១.២.១.១. ក្រុមប្រឹក្សាស្រុក

ជាគោលការណ៍ច្បាប់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមាននូវក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតអសកល ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ដោយស្មើភាព និងសម្ងាត់ ស្របទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហៅកាត់ថា ក្រុមប្រឹក្សា។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សា គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាមាន អាណត្តិប្រាំឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។[៨]

ជាទូទៅ សមាជិកក្រុមប្រឹក្សាស្រុក មានចំនួនចាប់ពី ១១រូប ដល់ ២១រូប ដោយចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ។[៩] ដោយយោងទៅតាមរបាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកកោះធំ ប្រចាំខែមីនា ឆ្នាំ២០២៤ ជាក់ស្តែង សមាជិកក្រុមប្រឹក្សាស្រុកកោះធំមានចំនួន ២១រូប (ស្រី ០៣រូប) ក្នុងនោះផងដែរ មានប្រធានក្រុមប្រឹក្សាស្រុកចំនួន ០១រូប និងសមាជិកក្រុមប្រឹក្សាស្រុកចំនួន ២០រូប។

### ១.២.១.២. គណៈអភិបាលស្រុក

ស្រុកនីមួយៗ ត្រូវមានគណៈអភិបាលមួយដែលរួមមានអភិបាលមួយ និងអភិបាលរង ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ស្រុក-ក្រុង ខណ្ឌ។ អភិបាល និងអភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សាស្រុកឡើយ។[១០] អភិបាល និងអភិបាលរងមានអាណត្តិការងារមិនលើសពីបួន (៤) ឆ្នាំ និងអាចត្រូវបានតែងតាំងបានបួន (៤) ឆ្នាំទៀត សម្រាប់អាណត្តិទី២របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល។[១១]

ជាទូទៅ គណៈអភិបាលស្រុកមានចំនួនចាប់ពី ០៥ (ប្រាំ) រូប ទៅ ០៧ (ប្រាំពីរ) រូប។[១២] ដោយយោងទៅតាមរបាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកកោះធំ ប្រចាំខែមីនា ឆ្នាំ២០២៤ ដោយនៅក្នុងនោះ គណៈអភិបាលស្រុកកោះធំ មានសមាសភាពចំនួន ០៧រូប (ស្រី ០១រូប) ក្នុងនោះមានអភិបាលចំនួន ០១រូប និងអភិបាលរងចំនួន ០៦រូប។

---

[៨] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលស្រុក, ក្រសួងមហាផ្ទៃ, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២, ទំព័រទី២០

[៩] ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៩, លេខ នស/រកម/០១១៩/០០៤, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩, មាត្រា១៨ថ្មី

[១០] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៤៣ និងមាត្រា១៤៤

[១១] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលស្រុក, ក្រសួងមហាផ្ទៃ, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២, ទំព័រទី២០

[១២] ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២២, លេខ នស/រកម/០៦២២/០០៥, ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២, មាត្រា១៤០ថ្មី

### ១.២.២. តួនាទី និងភារកិច្ច

ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក គឺជាអ្នកតំណាងរបស់ប្រជារាស្ត្រ និងរាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រង រៀបចំស្រុកឱ្យមានសោភ័ណភាព សន្តិសុខ សុវត្ថិភាព រួមទាំងសណ្តាប់ធ្នាប់ល្អជូនដល់ប្រជាពលរដ្ឋដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកត្រូវបានបែងចែក តួនាទី និងភារកិច្ចបានយ៉ាងច្បាស់លាស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយស្របតាមច្បាប់ បទបញ្ញត្តិ រួមទាំងលិខិតបទដ្ឋានគតិយុត្តនានា។ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាល ត្រូវបានបែងចែកដូចខាងក្រោម៖

#### ១.២.២.១. ក្រុមប្រឹក្សាស្រុក

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ក្រុមប្រឹក្សាប្រើប្រាស់អំណាចបញ្ញត្តិរបស់ខ្លួន តាមរយៈការធ្វើដីកា និងប្រើប្រាស់អំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាស្របតាមក្របខ័ណ្ឌដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ដែលបានប្រគល់ និង/ឬដែលបានធ្វើប្រតិភូកម្ម ដោយមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

**ក. ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សា**

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងតិចចំនួន ១២ដងក្នុងមួយឆ្នាំ ទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបាន តាមការចាំបាច់។

**ខ. ការងាររៀបចំបទបញ្ជាផ្ទៃក្នុង**

ក្រោយប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងតាមទម្រង់ជាដីកា និងត្រូវអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុន២៥ថ្ងៃ ឬលើសពី ៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១។

**គ. ការងាររៀបចំវិធានគ្រប់គ្រងផ្ទៃក្នុង**

ក្រុមប្រឹក្សានៃអាណត្តិនីមួយៗត្រូវរៀបចំ និងអនុម័តដីកា ស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុង ដើម្បីធានានូវការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

**ឃ. ការងារដាក់ចេញដីកា និងសេចក្តីសម្រេច**

ក្រុមប្រឹក្សាអាចដាក់ចេញដីកា ដើម្បីកំណត់ ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាព នីតិវិធី ឬកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនធានរបស់ខ្លួន ដោយផ្អែកតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និង/ឬតម្រូវការក្នុងមូលដ្ឋាន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏អាចដាក់ចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាមានពីរប្រភេទ គឺសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ក្នុងអង្គប្រជុំក្រុមប្រឹក្សាដោយត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សា។

**ង. ការងាររៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**

ក្រុមប្រឹក្សាត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខ្លួន ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗដោយត្រូវធ្វើឡើងនៅតាមឃុំ និងសង្កាត់នានាក្នុងស្រុក ក្នុងគោលបំណងផ្តល់ឱកាសឱ្យក្រុមប្រឹក្សាដើម្បី៖

- **ផ្តល់នូវព័ត៌មាន** ក្រុមប្រឹក្សារាយការណ៍អំពី សកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និងបង្ហាញពីផែនការសម្រាប់ឆ្នាំខាងមុខ
- **ផ្តល់ប្រឹក្សា** អ្នកចូលរួមពិភាក្សាអំពីលទ្ធផល ផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាអំពីការងារ នៅក្នុងឆ្នាំកន្លងមក និងលើកជាសំណើសម្រាប់ឆ្នាំបន្ទាប់
- **ជំរុញឱ្យមានការចូលរួម** អ្នកចូលរួមអាចរួមចំណែកនៅក្នុងដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្តដែលក្នុងនោះសំណើ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានលើកយកមកពិចារណានៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា
- **លើកកម្ពស់ការសហការ** ក្រុមប្រឹក្សាទទួលបានព័ត៌មានប្រសើរជាងមុនអំពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។ វេទិការបស់ក្រុមប្រឹក្សា ជំរុញ និងលើកកម្ពស់កិច្ចសហការគ្នារវាង ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។ វេទិកានេះ ចូលរួមចំណែក ក្នុងការបង្កើតនូវដំណោះស្រាយដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ។

### ច. ការងារផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ក្រោយប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ យ៉ាងយូរត្រឹមឆ្នាំទី២នៃអាណត្តិរបស់ក្រុមប្រឹក្សា។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមរយៈការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ។ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេង និងអ្នកពាក់ព័ន្ធនានាដោយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។

ជាក់ស្តែង នៅឆ្នាំទី១នៃអាណត្តិទី៣របស់ខ្លួនក្រុមប្រឹក្សាស្រុកកោះធំ បានរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០២០-២០២៤) រៀបចំឡើងដោយផ្អែកតាមស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច។[១៣] នៅឆ្នាំទី៥នៃអាណត្តិទី៣របស់ខ្លួនក្រុមប្រឹក្សាស្រុកកោះធំ ក៏បានរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤-២០២៦) យោងតាមមាត្រា៣៨ និងមាត្រា៣៩នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យ ស្តីពីការកសាងផែនការ លេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល។[១៤]

[១៣] សៀវភៅ ផែនការអភិវឌ្ឍន៍ ស្រុកកោះធំ ឆ្នាំ២០២០-២០២៤

[១៤] សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល ស្រុកកោះធំ ឆ្នាំ២០២៤-២០២៦

### ឆ. ការអនុវត្តមុខងារ

ក្រុមប្រឹក្សាត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាថារាល់មុខងារដែលផ្ទេរទៅឱ្យក្រុមប្រឹក្សារួមទាំងមុខងារជាអាណត្តិទូទៅដែលក្រុមប្រឹក្សាបានសម្រេចជ្រើសរើសយកមកអនុវត្តន៍ត្រូវបានយកទៅអនុវត្តន៍ យ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន។ ទន្ទឹមនេះ ក្រុមប្រឹក្សា ក៏ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងផ្តល់យោបល់ការអនុវត្តមុខងារទាំងនោះតាមរយៈការពិនិត្យ ពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដោយមានគណៈអភិបាលជាអ្នកធ្វើសេចក្តីរាយការណ៍ពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារទាំងនោះ។

### ជ. ការងារគ្រប់គ្រងបុគ្គលិក

ក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួននៅរដ្ឋបាលស្រុក ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តលើការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាល និងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែល និង
- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។

### ឈ. ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ដោយក្នុងនោះការងារសំខាន់ៗរួមមាន៖

- ការពិនិត្យ និងអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ការពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ
- តាមដានត្រួតពិនិត្យការអនុវត្តថវិកាដោយគណៈអភិបាល
- ការពិនិត្យ និងអនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ការពិនិត្យ និងអនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិជាដើម។[១៥]

[១៥] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលស្រុក, ក្រសួងមហាផ្ទៃ, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២, ទំព័រទី១២-១៥

### ១.២.២.២. គណៈអភិបាលស្រុក

គណៈអភិបាលស្រុក មានតួនាទីជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះអភិបាលក៏ជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងដែនសមត្ថកិច្ចរបស់ស្រុកផងដែរ។

ក្នុងនាមជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា គណៈអភិបាលមានភារកិច្ចសំខាន់ៗដូចជា៖

- អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា
- លើកយោបល់ជូនក្រុមប្រឹក្សា ពាក់ព័ន្ធកិច្ចការនានាដែលក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័ត
- ផ្ដួចផ្ដើម រៀបចំ និងដាក់ជូនក្រុមប្រឹក្សានូវសេចក្ដីព្រាងដីកា សេចក្ដីសម្រេច និង/ឬ បទបញ្ជានានា ដើម្បីក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ការអនុវត្ត ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកា និងសកម្មភាពផ្ដល់សេវាកម្មនានារបស់រដ្ឋបាលស្រុក ព្រមទាំងការអនុវត្តគម្រោង ឬកម្មវិធីនានា។

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងស្រុក អភិបាលស្រុកមានភារកិច្ច៖

- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុកឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុកក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលស្រុកត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួល បច្ចេកទេសក្រុមប្រឹក្សាស្រុក អភិបាលស្រុកត្រូវសម្របសម្រួលតម្រង់ទិសការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាស្រុក។
- ពិនិត្យវាយតម្លៃ ផ្ដល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យអង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាស្រុកជាមុន ក្នុងការផ្ដល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំក្នុងស្រុករបស់ខ្លួន។ ក្នុងករណីមិន

គាំទ្រ បេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលស្រុកត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះ ជូនអភិបាលខេត្ត ដើម្បីឱ្យអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរអង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងស្រុករបស់ខ្លួន ឬករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលស្រុក ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ និងជាបន្ទាន់ទៅអភិបាលខេត្ត។ អភិបាលខេត្តត្រូវណែនាំដល់មន្ទីរអង្គភាពខ្សែបណ្តោយសាមីនៅថ្នាក់ខេត្ត ឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារដែលមានការចូលរួម ពីតំណាងស្រុកពាក់ព័ន្ធឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី។
- អភិបាលស្រុកមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូត ពីមុខតំណែងនូវ ប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

អភិបាលស្រុកត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលក្នុងការថែរក្សា សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុកអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងស្រុក។

អភិបាលស្រុក គឺជាប្រធានគណៈបញ្ជាការឯកភាពស្រុក ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងស្រុក។[១៦]

[១៦] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៥៣ និងមាត្រា១៥៤

## ១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំស្រុកកោះធំ

កត្តាដែលនាំឱ្យមានការរៀបចំស្រុក ឬក្រុងមួយចាំបាច់ត្រូវធ្វើឡើងប្រកបដោយសនិទានកម្ម ពោលគឺមានការគិតគូរហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ។[១៧] ដូច្នេះការរៀបចំស្រុក ឬក្រុងមួយកើតឡើង ពុំមែនដោយសារភាពចៃដន្យនោះទេ គឺកើតឡើងដោយសារមូលហេតុជាច្រើន ដើម្បីបំពេញទៅតាមតម្រូវការ និងភាពខ្វះខាតរបស់ប្រជាជន ដើម្បីឱ្យស្របតាមបច្ចុប្បន្នភាព និងស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋក្នុងជីវភាពប្រចាំថ្ងៃក៏ដូចជានាពេលអនាគតផងដែរ។ តួយ៉ាង ស្រុកកោះធំក៏ដូចគ្នា គឺដោយសារសង្កេតឃើញមានភាពចន្លោះខ្វះខាតទៅលើកត្តាមួយចំនួន ដែលតម្រូវឱ្យមានការកែប្រែ និងរៀបចំ ដើម្បីឱ្យប្រកបដោយភាពល្អប្រសើរ និងការអភិវឌ្ឍទៅមុខថែមទៀត ហើយកត្តាដែលជំរុញឱ្យមានការរៀបចំស្រុកកោះធំនេះរួមមាន កំណើនប្រជាជន ភាពក្រីក្រ ការដាក់សម្ពាធបរិស្ថាន និងគមនាគមន៍។

### ១.៣.១. កំណើនប្រជាជន

ចំនួនប្រជាជនមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដូច្នេះហើយការកើនឡើងនូវចំនួនប្រជាជន គឺជាកត្តាចម្បងមួយដែលជំរុញឱ្យមានការរៀបចំស្រុកផងដែរ។ ជាទូទៅ មាននូវសមាសភាពនៃកំណើនប្រជាជនក្នុងស្រុក ឬក្រុង៣សំខាន់ៗ គឺកំណើនប្រជាជនក្នុងស្រុកជាលក្ខណៈធម្មជាតិ កំណើនដោយសារចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី។ កំណើនប្រជាជនក្នុងក្រុង ឬស្រុកជាលក្ខណៈធម្មជាតិបានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកកំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី គ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។[១៨] កំណើនប្រជាជនក្នុងស្រុក ឬក្រុងជាលក្ខណៈធម្មជាតិដោយចំនួនប្រជាជនពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងនៃកំណើនប្រជាជនថ្មីក្នុងស្រុក ដែលស្ថិតទៅតាមកាលៈទេសៈពេលវេលាចេះតែទៅមុខ ហើយអត្រាមរណៈតិចជាងអត្រាកំណើតផងដែរ។ កំណើនដោយសារចំណាកស្រុកពី ភូមិ ឃុំ ឬស្រុកផ្សេងមកកាន់ស្រុកកោះធំដើម្បីមកស្វែងរកការងារ ឬប្រកបអាជីវកម្ម លក់ដូរជាដើម។ កំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកតំបន់នោះមិនទាន់មានការរៀបចំ និងការអភិវឌ្ឍ។ ទន្ទឹមនឹងនេះផងដែរ នៅពេលដែលមានកំណើនប្រជាជនតម្រូវការសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃនោះ ក៏មានការកើនឡើងផងដែរ ដូចជា ចំណីអាហារ លំនៅដ្ឋាន យានជំនិះ សាលារៀន មន្ទីរពេទ្យ វត្តអារាម ផ្សារ ស្ពាន ផ្លូវថ្នល់ជាដើម ដែល

[១៧] សៀវភៅ នីតិនគររូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៨

[១៨] សៀវភៅ នីតិនគររូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៩

ចាំបាច់ឱ្យមានការរៀបចំ និងកែតម្រូវដើម្បីឱ្យស្របទៅតាមកំណើនរបស់ប្រជាជន រួមទាំងដើម្បីទទួលបាននូវសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អ។

ជាក់ស្តែង នៅស្រុកកោះធំ ក្នុងឆ្នាំ២០២៣ទៅនេះ ប្រជាជនសរុបមានចំនួនប្រមាណ ១៦០,៥៤០នាក់។[១៩] មួយវិញទៀត នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣នេះ រដ្ឋាភិបាលបានបង្កើតនូវក្រុងថ្មី ដែលជាក្រុងសំពៅពូន ដោយបានកាត់ឃុំចំនួន ០៥ ពីស្រុកកោះធំមានដូចជា ឃុំព្រែកស្តី ឃុំសំពៅពូន ឃុំព្រែកជ្រៃ ឃុំជ្រោយតាកែវ និង ឃុំឈើខ្មៅ ដែលបានធ្វើឱ្យចំនួនប្រជាជនមានការប្រែប្រួលទៅតាមនោះផងដែរ។

### ១.៣.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់តែជាទូទៅភាពក្រីក្រ សំដៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈលំនៅឋាន ការងារធនធានទឹក អគ្គិសនី អនាម័យសុខុមាលភាពសង្គមមានការខ្វះខាត។ ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួស ដោយការវាស់ស្ទង់ តាមរយៈប្រាក់ចំណូលនេះឡើយ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មតថា ជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង២០%នៃចំនួនប្រជាជនពិភពលោកដែលរស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយ៩០%ក្នុងចំនួននេះកំពុងស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[២០]ភាពក្រីក្រក៏ជាបញ្ហាមួយដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាព និងសណ្តាប់ធ្នាប់ផងដែរ ដោយហេតុថាប្រជាជនក្រីក្រភាគច្រើនពុំមានកន្លែងស្នាក់នៅមួយដែលច្បាស់លាស់ ឬសមរម្យទេដោយប្រជាជនមួយចំនួនស្នាក់នៅតាមសួនច្បារ ចិញ្ចើមផ្លូវ ក្រោមស្ពាន ឬតាមវត្តអារាម ព្រមទាំងមានការសុំទានតាមទីសាធារណៈដូចជា តាមភ្លើងស្តុប តាមផ្សារ សាលារៀន វត្តអារាម ឬតាមផ្ទះជាដើម ដូច្នេះហើយ តម្រូវឱ្យការមានយកចិត្តទុកដាក់ពីអាជ្ញាធរក្នុងការស្វែងរកដំណោះស្រាយពីបញ្ហាទាំងអស់នេះ ដើម្បីកាត់បន្ថយនូវភាពក្រីក្រ។ ដូចនេះហើយ ភាពក្រីក្រក៏ជាកត្តាមួយដែលជំរុញឱ្យមានការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្នុងស្រុកផងដែរ។

ជាក់ស្តែង ស្ថានភាពនៃភាពក្រីក្រនៅស្រុកកោះធំត្រូវបានកាត់បន្ថយជាបណ្តើរៗ ហើយដំណោះស្រាយចំពោះភាពក្រីក្រនោះ ដែលមួយចំនួនទាក់ទងនឹងការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការផ្តល់ឱកាស

[១៩] សៀវភៅ ផែនការអភិវឌ្ឍន៍ ស្រុកកោះធំ ឆ្នាំ២០២០-២០២៤

[២០] សៀវភៅ នីតិនគររូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៩-២០

របស់សង្គមដូចជា ការលើកទឹកចិត្តទៅលើវិស័យឯកជនក្នុងការបង្កើតរោងចក្រសហគ្រាស សិប្បកម្ម អាជីវកម្មផ្សេងៗ ដែលជាការបង្កើតមុខរបរ និងប្រាក់ចំណូលជូនប្រជាពលរដ្ឋ។[២១]

### ១.៣.៣. ការដាក់សម្ពាធបរិស្ថាន

ការដាក់សម្ពាធបរិស្ថាន គឺសំដៅទៅលើគ្រោះមហន្តរាយធម្មជាតិដូចជា គ្រោះរាំងស្ងួត ដីខ្សោះជីវជាតិមិនសមល្មមសម្រាប់ធ្វើកសិកម្មខ្វះទឹក ហើយពេលខ្លះមានទឹកជំនន់ជនលិចផលដំណាំរបស់ប្រជាជន។ សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធវិស័យបរិស្ថាន គឺកង្វះដីសម្រាប់បង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើន ក្នុងករណីដែលដីរបស់ពួកគេទទួលបានពីដូនតា ឪពុកម្ដាយ របស់ខ្លួនត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូច មិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីជាតិទៀត។ ប្រសិនបើក្រឡេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ ហើយតែគាត់បែរជាកង្វះនូវប្រព័ន្ធធារាសាស្ត្រ ស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញ។[២២]

ជាក់ស្ដែង ស្រុកកោះធំ ជាស្រុកមួយដែលមានទីតាំងមួយផ្នែកធំស្ថិតនៅ តាមបណ្ដោយទន្លេបាក់សាក់ ដែលជាហេតុនាំឱ្យប្រជាជន ដែលរស់នៅតាមបណ្ដោយទន្លេ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅលើផ្ទៃទឹកនោះងាយរងគ្រោះពីកត្តាធម្មជាតិជាច្រើននាពេលរដូវវស្សាដូចជា ការបាក់ស្រុតច្រាំងដី និងទឹកជន់ឡើង ដែលជាការគំរាមគំហែងធ្វើឱ្យប៉ះពាល់ទៅដល់ផ្ទះសម្បែង និងការរស់នៅរបស់ប្រជាជនដូចជា សុខភាព អនាម័យ បរិស្ថានជាដើម។ ហេតុនេះហើយ តម្រូវឱ្យមានការជួយរៀបចំពីសំណាក់រដ្ឋបាលស្រុកកោះធំ និងអាជ្ញាធរដែលពាក់ព័ន្ធដើម្បីស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋដូចជា ឱ្យប្រជាពលរដ្ឋផ្លាស់ទីលំនៅ ស្វែងរកទីទួលសុវត្ថិភាពសម្រាប់ទប់ស្កាត់ និងបង្ការពីគ្រោះធម្មជាតិដែលអាចកើតមានឡើងនៅពេលក្រោយណាមួយ។ នៅក្នុងឆ្នាំ២០២៣កន្លងទៅនេះ មានការបាក់ច្រាំងទន្លេ ប្រវែងបណ្ដោយ ២៥ម៉ែត្រ និងទទឹង ០៥ម៉ែត្រ ដែលស្ថិតនៅក្នុងភូមិព្រែកធន់ ឃុំព្រែកថ្មី។ រដ្ឋបាលស្រុកកោះធំ មានផែនការត្រៀមបម្រុងឆ្លើយតបទៅនឹងគ្រោះអាសន្នទឹកជំនន់ និងមានផែនការសង្គ្រោះបន្ទាន់ ជាពិសេសនោះគាំទ្រគំនិតផ្ដួចផ្ដើមគ្រប់គ្រងគ្រោះមហន្តរាយ។ ការខិតខំប្រឹងប្រែងក្នុងការចាត់ចែងចំពោះមហន្តរាយដោយធម្មជាតិ ជាមូលដ្ឋានសម្រាប់ជាជំហានៗសំដៅការកាត់បន្ថយភាពងាយរងគ្រោះចំពោះមនុស្ស និងសេដ្ឋកិច្ច។[២៣]

---

[២១] សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល ស្រុកកោះធំ ឆ្នាំ២០២៤-២០២៦

[២២] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ព ឆ្នាំ២០២៣, ទំព័រទី២០

[២៣] សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល ស្រុកកោះធំ ឆ្នាំ២០២៤-២០២៦

### ១.៣.៤. គមនាគមន៍

គមនាគមន៍ គឺជាផ្លូវសម្រាប់ការធ្វើដំណើរទៅវិញទៅមកដែលជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់ធ្វើចរាចរណ៍ និងជាតម្រូវការដ៏ចាំបាច់ដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរួមមានដូចជា វិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ជាដើម។ គមនាគមន៍ ក៏ជាកត្តាសំខាន់មួយក្នុងការជំរុញឱ្យមានការរៀបចំផងដែរ ព្រោះកាលណាដែលមានគមនាគមន៍ដែលល្អនោះ អាចជួយសម្រួលដល់ការធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចបានយ៉ាងច្រើនដូចជា ការធ្វើដំណើរ ការដឹកជញ្ជូន ការនាំចេញ និងការនាំចូលទំនិញដោយគ្មានការកកស្ទះ មានសុវត្ថិភាព ចំណេញពេលវេលាក្នុងការធ្វើដំណើរ ព្រមទាំងជួយជំរុញឱ្យសេដ្ឋកិច្ចរបស់ស្រុក ឬប្រទេសមានការរីកចម្រើន ធ្វើឱ្យមាននូវសណ្តាប់ធ្នាប់ និងសោភ័ណភាព។ ដូច្នេះហើយ ការអភិវឌ្ឍគមនាគមន៍ គឺជាកត្តាដែលសំខាន់សម្រាប់ជំរុញឱ្យមានការរៀបចំអភិវឌ្ឍន៍ក្នុងស្រុក។

ជាក់ស្តែង ស្រុកកោះធំមានការអភិវឌ្ឍទៅលើគមនាគមន៍បានច្រើនដូចជា មានផ្លូវបេតុង ស្ពានតូចធំជាច្រើនខ្សែ ដើម្បីជួយសម្រួលដល់ការធ្វើដំណើរ ក៏ដូចជាការដឹកជញ្ជូន និងការរស់នៅរបស់ប្រជាជននៅតាមភូមិ ឃុំ ស្រុកជាដើម។

# ជំពូកទី២
# ការរៀបចំសោភ័ណភាព
# និងសណ្ដាប់ធ្នាប់ស្រុកកោះធំ

# ជំពូកទី២

# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ

## ២.១. ការរៀបចំស្រុកកោះធំ

### ២.១.១. ការរៀបចំសោភ័ណភាពស្រុកកោះធំ

សោភ័ណភាព សំដៅលើភាពល្អប្រសើរ ភាពល្អហ្មត់ហ្មង។[២៤] ការរៀបចំសោភ័ណភាព ជាកត្តាសំខាន់មួយដែលត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍប្រទេសជាតិ ដើម្បីទទួលបាននូវភាពស្រស់ស្អាត មានរបៀបរៀបរយ និងប្រកបដោយភាពទាក់ទាញផងដែរ។

ស្រុកកោះធំ ជាស្រុកមួយដែលមានសក្តានុពល និងការអភិវឌ្ឍក្នុងចំណោមស្រុកផ្សេងទៀតនៅក្នុងខេត្តកណ្តាល។ ទន្ទឹមនឹងការអភិវឌ្ឍនេះ រដ្ឋបាលស្រុកកោះធំក៏បានខិតខំប្រឹងប្រែងរៀបចំសោភ័ណភាពនៅក្នុងស្រុករបស់ខ្លួនជាបន្តបន្ទាប់ឥតឈប់ឈរ និងនៅតែបន្តការរៀបចំសោភ័ណភាពនេះបន្តទៅមុខទៀត។ ការរៀបចំសោភ័ណភាពនឹងកាន់តែធ្វើឱ្យស្រុកនេះបង្កើននូវភាពទាក់ទាញក៏ដូចជា ជួយលើកកម្ពស់ក្នុងការអភិវឌ្ឍស្រុកកាន់តែល្អប្រសើរទៅមុខថែមទៀត។ មួយវិញទៀត រឿងដែលសំខាន់ក្នុងការរៀបចំសោភ័ណភាពនេះទៅបានដោយរលូនទៅមុខយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាពលុះត្រាតែមានការចូលរួម និងការយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំ អាជ្ញាធរដែលពាក់ព័ន្ធ និងពីសំណាក់ប្រជាពលរដ្ឋផ្ទាល់ផងដែរ។ ជាក់ស្តែង សោភ័ណភាពត្រូវបានបែងចែកជាពីរផ្នែក ដោយក្នុងនោះមានដូចជា សោភ័ណភាពពេលថ្ងៃ និងសោភ័ណភាពពេលយប់។

#### ២.១.១.១. សោភ័ណភាពពេលថ្ងៃ

សោភ័ណភាពពេលថ្ងៃ គឺសំដៅទៅលើការរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធរួមមាន (ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ ចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី និងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា, ស្លាកសញ្ញា, និងគំនូសសញ្ញាចរាចរណ៍រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ និងទាំងថ្មើរជើងផងប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយល្អថែមទៀត។[២៥]

---

[២៤] វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជ ជួនណាត

[២៥] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ គឺជាផ្នែកដ៏សំខាន់មួយដែលធ្វើឱ្យសោភ័ណភាពពេលថ្ងៃកាន់តែមាននូវភាពល្អប្រសើរ ស្រស់ស្អាត និងប្រកបដោយភាពទាក់ទាញ។ ជាក់ស្តែង បើយើងក្រឡេកមកមើលសោភ័ណភាពពេលថ្ងៃនៅក្នុងស្រុកកោះធំវិញ ឃើញថាក៏បានរៀបចំកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានារួមមាន (ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ ចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ) ជាពិសេសក៏បានបំពាក់នៅផ្លាកសញ្ញាចរាចរណ៍ គំនូសចរាចរណ៍តាមបណ្តោយផ្លូវ ដើម្បីជួយសម្រួលសុវត្ថិភាពចរាចរណ៍ដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរផងដែរ។

ដើម្បីបង្កើនសោភ័ណពេលថ្ងៃឱ្យកាន់តែមានភាពស្រស់ស្អាត មានរបៀបរៀបរយ ហើយប្រកបដោយភាពទាក់ទាញ ជាពិសេសដើម្បីជួយថែរក្សាបរិស្ថានឱ្យកាន់តែល្អប្រសើរទៅមុខថែមទៀត រដ្ឋបាលស្រុកកោះធំបានខិតខំប្រឹងប្រែងរៀបចំដាំដើមឈើលម្អនៅតាមទីសាធារណៈមិនថានៅតាម ដងផ្លូវ ទីធ្លាវត្តអារាម សាលារៀន សាលាស្រុក ភូមិឋានជាដើម។ មិនតែប៉ុណ្ណោះ ក៏បានខិតខំប្រឹងប្រែងបន្តរិះរកមធ្យោបាយក្នុងការកែលម្អសោភ័ណភាពនៅក្នុងស្រុកកោះធំឱ្យកាន់តែមានភាពល្អប្រសើរទៅមុខថែមទៀតផងដែរ។

នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ នៅក្រោមអធិបតីភាពអភិបាលរងខេត្តកណ្តាលតំណាងដ៏ខ្ពង់ខ្ពស់របស់គណៈអភិបាលខេត្តកណ្តាល បានអញ្ជើញចូលរួមក្នុងពិធីដាំកូនឈើនៅក្នុងស្រុកកោះធំ ដែលកូនឈើដែលត្រូវបានដាំនោះ គឺមានចំនួន ១០ ០០០ដើម ដោយបានធ្វើការបែងចែកដាំនៅតាមទីធ្លាសាលារៀន វត្តអារាម និងនៅតាមរដ្ឋបាលឃុំ ហើយកូនឈើទាំងចំនួន ១០ ០០០ដើមនោះមានការឧបត្ថម្ភមកពីរដ្ឋបាលខេត្តកណ្តាលផងដែរ។ មិនតែប៉ុណ្ណោះ បានជំរុញអោយអាជ្ញាធរស្រុកកោះធំគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋរួមគ្នាដាំដើមឈើគ្រប់ប្រភេទនៅតាមរមណីយដ្ឋាន ទីវត្តអារាម សាលារៀន ភូមិឋាន ប្រឡាយទឹក ដងផ្លូវ និង ទីសាធារណៈ ហើយខិតខំថែរក្សាឱ្យដុះលូតលាស់បានល្អដើម្បីផ្តល់ជាប្រយោជន៍បន្ថែម។ លើសពីនេះទៅទៀត ការដាំដើមឈើគ្រប់ប្រភេទក្នុងគោលបំណងជួយថែរក្សាបរិស្ថាន បង្កើនទេសភាព សោភ័ណភាព បង្កើតបានទៅជាម្លប់ពណ៌បៃតង និងជាម្លប់ដ៏ត្រជាក់សម្រាប់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋផងដែរ។ ជាងនេះទៀត ព្រៃឈើជាសម្បត្តិធម្មជាតិដ៏សំខាន់ ក្នុងការថែរក្សាលំនឹងបរិស្ថាន និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច ទេសចរណ៍ធម្មជាតិ វប្បធម៌ និងជាជម្រកដ៏សុខសាន្តចំពោះ មនុស្ស សត្វគ្រប់ប្រភេទ ដែលមានជីវិតរស់នៅលើភពផែនដីយើងនេះ។ យ៉ាងណាមិញ ការបាត់បង់នូវធនធានព្រៃឈើជាចំណែកមួយក្នុងចំណោមបញ្ហាធំៗក្នុងពិភពលោកដែលនឹងជះឥទ្ធិពលអាក្រក់បង្កឱ្យដីបាត់បង់ជីវជាតិ និងកើតមានគ្រោះធម្មជាតិដូចជា ភាពរាំងស្ងួត

ទឹកជំនន់ បម្រែបម្រួលអាកាសធាតុ កម្ដៅផែនដីកើនឡើង។ល។ ដែលនាំឱ្យមានផលវិបាកក្នុងការរស់នៅទាំងមនុស្ស សត្វ និងរុក្ខជាតិ ជាពិសេសជួបប្រទះផលវិបាកក្នុងរបរកសិកម្មផងដែរ។[២៦]

### ២.១.១.២. សោភ័ណភាពពេលយប់

សោភ័ណភាពពេលយប់ សំដៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដងមហាវិថីនានាក្នុងទីក្រុង ឬទីប្រជុំជន ជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌នាពេលរាត្រីនៅតាមសួនច្បារសាធារណៈ។ ការបំពាក់ភ្លើងបំភ្លឺនេះ គឺបានជួយសោភ័ណភាពពេលយប់ ដោយបានរំលេចពីសម្រស់ដ៏ស្រស់ស្អាត និងភាពទាក់ទាញនៅពេលរាត្រីបន្ថែមទៀត។ ជាមួយគ្នានេះដែរ ការបំពាក់ភ្លើងបំភ្លឺនៅពេលយប់ក៏មានសារៈប្រយោជន៍ជួយផ្ដល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរឆ្លងកាត់ទៅមក រួមទាំងសុខសុវត្ថិភាពក្នុងពេលធ្វើដំណើរនៅពេលយប់ថែមទៀតផង។[២៧] ជាក់ស្ដែង នៅក្នុងស្រុកកោះធំ ក៏មានការបំពាក់ភ្លើងលំអនៅតាមដងផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ វត្តអារាម អាគារនានា ដែលធ្វើឱ្យស្រុកកោះធំកាន់តែមាននូវសោភ័ណភាពដ៏ស្រស់ស្អាត ប្រកបភាពទាក់ទាញផងដែរ។

ការដែលទទួលបានផ្លូវគមនាគមន៍ក្នុងការធ្វើដំណើរទៅមកវាជារឿងមួយដែលល្អប្រសើរ ក៏ប៉ុន្តែវាពិតជាចាំបាច់ដែលត្រូវតែមានបំពាក់ភ្លើងបំភ្លឺនៅពេលយប់ផងដែរ។ ប្រសិនបើមិនមានភ្លើងបំភ្លឺនៅពេលយប់នោះទេ ប្រជាពលរដ្ឋដែលធ្វើដំណើរនឹងជួបប្រទះនូវការលំបាក ឬឧបសគ្គនៅក្នុងការធ្វើដំណើរឆ្លងកាត់ទៅមកនៅពេលយប់ជាក់ជាមិនខាន ជាពិសេសអាចធ្វើឱ្យប្រជាពលរដ្ឋមានការព្រួយបារម្ភអំពីសុខសុវត្ថិភាពរបស់ខ្លួននៅពេលធ្វើដំណើរថែមទៀតផង។ ជាងនេះទៅទៀត ការបំពាក់ភ្លើងបំភ្លឺនៅពេលយប់ក៏អាចជួយកាត់បន្ថយ និងការពារនូវបទល្មើសចោរកម្ម លួច ឆក់ ប្លន់ជាដើម ដែលកត្តាទាំងអស់នេះហើយទើបនៅតាមដងផ្លូវត្រូវតែមានភ្លើងបំភ្លឺផ្លូវជាចាំបាច់ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ប្រកបដោយសុខសុវត្ថិភាព។ ជាក់ស្ដែងនៅក្នុងស្រុកកោះធំផ្ទាល់ ក៏បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀបចំបំពាក់ភ្លើងបំភ្លឺនៅពេលយប់តាមដងផ្លូវទីសាធារណៈ ជាពិសេសឃើញថាតាមឃុំនីមួយៗនៅក្នុងស្រុកកោះធំនេះ ក៏មានបំពាក់នៅភ្លើងសូឡាបំភ្លឺនៅតាមបណ្ដោយផ្លូវបេតុងថែមទៀតផង។

[២៦] គេហទំព័រ រដ្ឋបាលខេត្តកណ្ដាល https://www.kandal.gov.kh/detail/16054 ចូលទស្សនានៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤

[២៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

### ២.១.២. ការរៀបចំសណ្តាប់ធ្នាប់ស្រុកកោះធំ

ការរៀបចំសណ្តាប់ធ្នាប់ គឺជាកត្តាដ៏សំខាន់មួយដែលត្រូវតែគិតគូរ និងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍប្រទេសជាតិដើម្បីឱ្យមានរបៀបរៀបរយល្អប្រសើរ គ្មានការរំខាន គ្មានការបំពុលបរិស្ថាន និងប្រកបទៅដោយសុខសុវត្ថិភាព។ សណ្តាប់ធ្នាប់ សំដៅដល់ធាតុចំនួន ៣រួមមាន សន្តិសុខ ភាពស្ងប់ស្ងៀម និងគ្មានការបំពុលបរិស្ថាន។

#### ២.១.២.១. សន្តិសុខ

ដើម្បីធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយសុខសុវត្ថិភាព រាជរដ្ឋាភិបាល និងអាជ្ញាធរដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់បានខិតខំប្រឹងប្រែងយកចិត្តយ៉ាងខ្លាំងក្នុងការការពារ និងធានាដល់សុខសុវត្ថិភាពជូនប្រជាពលរដ្ឋដែលអនុវត្តស្របតាមគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។ ទន្ទឹមនឹងនេះផងដែរ សន្តិភាព ស្ថិរភាព និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើង មានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានានូវតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បធានាឱ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។ ឆ្លងកាត់បទពិសោធន៍អស់រយៈពេល១០ឆ្នាំក្រសួងមហាផ្ទៃដោយមានការគាំទ្រ និងចូលរួមពី ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋានបានចាត់តាំងអនុវត្តន៍ប្រកបដោយជោគជ័យ និងបានធ្វើការកែលម្អផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ជាបន្តបន្ទាប់ ឱ្យស្របតាមបរិបទនៃការអភិវឌ្ឍរបស់សង្គមជាតិ។ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន និងការកៀរគរឱ្យមានការចូលរួមគាំទ្រកាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាលដែលមានគោលបំណង និងសំណូមពរដូចខាងក្រោម៖

- បន្តកសាង និងពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ

ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

➢ កសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុបក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

**លក្ខណសម្បត្តិរបស់ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»**

- ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។
- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។
- មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។
- គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។
- ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។
- មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ។
- ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។[២៨]

ស្របទៅតាមគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រដ្ឋបាលស្រុកកោះធំ អាជ្ញាធរដែលពាក់ព័ន្ធបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ ដោយបានចុះក្តាប់សភាពការណ៍ នៅតាមបណ្តាភូមិសាស្ត្រសំខាន់ៗក្នុងស្រុក និងកម្លាំងជំនាញក៏បានសហការជាមួយនឹងប៉ុស្តិ៍រដ្ឋបាល ០៦ប៉ុស្តិ៍ ក្នុងការចុះកំណត់មុខសញ្ញាបទល្មើសផ្សេងៗក្នុងមូលដ្ឋានទាំង ០៦ឃុំផងដែរ។

### ២.១.២.២. ភាពស្ងប់ស្ងៀម

ភាពស្ងប់ស្ងៀម គឺសំដៅទៅលើទីតាំងមួយដែលមិនមានការបំពុលដោយសំឡេង។[២៩] ប្រសិនបើនៅក្នុងទីតាំងមួយមានការរំខានដោយសំឡេង នោះមានន័យថាទីតាំងនោះមិនទាន់មានសណ្តាប់ធ្នាប់ល្អប្រសើរនៅឡើយទេ ព្រោះក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ សុទ្ធសឹងតែត្រូវការភាពស្ងប់ស្ងៀមដោយមិនមានការរំខាន

[២៨] គោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព, លេខ ០១ គនប, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១

[២៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

សំឡេងពីមជ្ឈដ្ឋានខាងក្រៅ។ ជាងនេះទៅទៀត ការរំខានដោយសំឡេងវាមានឥទ្ធិពលមិនល្អទៅដល់សុខភាព ផ្លូវចិត្ត និងផ្លូវកាយរបស់ប្រជាពលរដ្ឋ ជាពិសេសប៉ះពាល់ដល់សតិអារម្មណ៍កាន់តែខ្លាំងថែមទៀត។ ជាក់ស្ដែង រដ្ឋបាលស្រុកកោះធំ បានខិតខំប្រឹងប្រែងរិះរកវិធីទប់ស្កាត់ និងដោះស្រាយនូវរាល់ការរំខានដោយសំឡេងនៅក្នុង ភូមិស្រុករបស់ខ្លួន ដើម្បីធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយភាពស្ងប់សុខ និងមិនមានការរំខាន ដោយសំឡេងផងដែរ។

### ២.១.២.៣. គ្មានការបំពុលបរិស្ថាន

បរិស្ថាន គឺជាអ្វីដែលជុំវិញខ្លួនរបស់យើងមិនថាជាភាវៈមានជីវិតក្ដី ឥតមានជីវិតក្ដី។ ក្នុងជីវភាពរស់នៅ របស់មនុស្ស សត្វ រុក្ខជាតិសុទ្ធសឹងតែត្រូវការរស់នៅក្នុងមជ្ឈដ្ឋានមួយដែលប្រកបដោយ បរិស្ថានស្អាតគ្មានការ បំពុលផ្សេងៗ។ ប្រសិនបើបរិស្ថានមួយមាននូវការបំពុលនោះ ពិតប្រាកដណាស់នឹងធ្វើឱ្យមានផលមិនល្អដែល ប៉ះពាល់សុខភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ជាពិសេសអាចធ្វើឱ្យខូចខាត និងបាត់បង់នៅសោភ័ណភាព។ ដូច្នេះ បរិស្ថាន ជាកត្តាដ៏សំខាន់មួយដែលត្រូវតែគិតគូរជាចាំបាច់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ទីកន្លែងមួយដែលគ្មាន ការបំពុលកើតមានឡើង ជាទីកន្លែងដែលគួរឱ្យចង់រស់នៅបំផុត ដែលធ្វើឱ្យយើងមានអារម្មណ៍ថាស្រស់ស្រាយ និងសប្បាយចិត្តក្នុងការរស់នៅ។ បរិស្ថានស្អាត គឺជាបរិស្ថានមួយដែលគ្មានការបំពុលទាំងប្រាំ ដែលការបំពុល ទាំងប្រាំនោះរួមមាន ការបំពុលទឹក ដី ខ្យល់ សំឡេង និងសំណង់រឹង-រាវ។

#### ក. ការបំពុលទឹក

ទឹក ពិតជាមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ។[៣០] ការបំពុលទឹក គឺ ជាការធ្វើឱ្យកខ្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុលនានា បានហូរចូលទៅក្នុងប្រភពទឹក ដោយមិនបានធ្វើ ការឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម (ដកយកសារធាតុបំពុលចេញ)។[៣១] មិនតែប៉ុណ្ណោះ ការបំពុលទឹកក៏បានជះឥទ្ធិពល ដ៏អាក្រក់ដល់គុណភាពបរិស្ថាន ជាពិសេសប៉ះពាល់ដល់សុខភាពក្នុងការរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ តាមកម្រិតនៃការបំពុលនោះផងដែរ។ ប្រភពនៃការបំពុលទឹកកើតឡើងដោយកត្តាដូចជា៖

- **កត្តាមនុស្ស** ទាក់ទងនឹងមុខរបរអាជីវកម្មដែលប្រជាពលរដ្ឋប្រកបជារៀងរាល់ថ្ងៃ និងវិស័យកសិកម្ម ការប្រើប្រាស់ជីគីមីបានបន្សល់ទុកនូវកាកសំណល់ដោយសារការគ្រប់គ្រងមិនបានល្អ និងមិនត្រឹមត្រូវ ទៅតាមបច្ចេកទេសនាំឱ្យសំណល់អាចហូរធ្លាក់ចូលប្រឡាយទឹក ទឹកស្រះនៅតាមទីជនបទដែលថ្លា

---

[៣០] គេហទំព័រ http://www.healthcambodia.com/p6241/ ចូលទស្សនានៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤

[៣១] គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/ ចូលទស្សនានៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤

និងគ្មានក្លិនស្អុយដែលតែងតែប្រើប្រាស់សម្រាប់បរិភោគ និងសម្រាប់ងូត ប៉ុន្តែដោយសារតែការបង្ហូរកាកសំណល់ចេញពីកសិដ្ឋានចិញ្ចឹមជ្រូក មាន់ និងទា ទឹកស្រះនោះក៏ប្រែពណ៌ទៅជាល្អក់ និងមានក្លិនស្អុយ ដូច្នេះហើយមិនអាចប្រើប្រាស់ទឹកនោះតទៅទៀតបានទេ ព្រោះទឹកត្រូវបានបំពុលឱ្យកខ្វក់។ ការធ្វើដំណើរកម្សាន្តទៅតាមទូក កប៉ាល់ ឬកាណូតអ្នកដំណើរខ្លះក៏នូវតែមានការបន្ទោរបង់នៅតាមបង្គន់អនាម័យលើយានជំនិះ ដោយបង្គន់អនាម័យខ្លះជួនកាលមិនបានរៀបចំឱ្យបានត្រឹមត្រូវ ពេលនោះហើយលាមក និងកាកសំណល់ផ្សេងៗត្រូវធ្លាក់នៅលើផ្ទៃទឹក។ នៅតាមទីក្រុង ឬទីសាធារណៈការបោះសំរាម ឬកាកសំណល់ពាសវាលពាសកាល ជួនកាលអាចបោះចោលទៅក្នុងទឹក ជាពិសេសទឹកលូដែលអាចបង្កជាការកកស្ទះផងដែរ។ ទឹកលូ គឺសំដៅទៅលើទឹកកខ្វក់ ដែលបានបញ្ចេញពីលំនៅឋាន និងអគារសាធារណៈ។[៣២]

- **កត្តាធម្មជាតិ** សារធាតុនីត្រូសែនដែលមាននៅក្នុងទឹកភ្លៀង ហើយនៅពេលដែលទឹកភ្លៀងធ្លាក់ចូលទៅក្នុងទឹកស្ទឹង ស្រះ ឬទន្លេ ក៏បានបំប្លែងទៅជាអាស៊ីតនីត្រាដែលអាចបង្កឱ្យគ្រោះថ្នាក់ និងបំផ្លាញជីវិតរុក្ខជាតិព្រមទាំងជីវចម្រុះដែលរស់នៅក្នុងទឹក ថែមទាំងអាចបង្កឱ្យមនុស្សកើតមានជំងឺបានតាមរយៈការបរិភោគទឹក និងប្រើប្រាស់ផងដែរ។

### ខ. ការបំពុលដី

ការបំពុលដី គឺជាការធ្វើឱ្យខូចខាតទ្រង់ទ្រាយដី ដីមានសភាពកខ្វក់ និងធ្វើឱ្យដីគ្មានសោភ័ណភាព។ ម្យ៉ាងវិញទៀត ការបំពុលដី គឺជាការធ្វើឱ្យដីខូចបាត់បង់ជីវជាតិ បណ្តាលឱ្យមនុស្ស សត្វ និងរុក្ខជាតិពិបាកនឹងរស់រានមានជីវិត ឬក៏ឈានទៅដល់ការបាត់បង់ជីវិតក៏មានដែរ។[៣៣] ការបំពុលដីស្តែងឡើងតាមរយៈ៖

- **បំពុលដោយសកម្មភាពកសិកម្ម** រាល់សកម្មភាពកសិកម្ម គឺសុទ្ធសឹកតែត្រូវការប្រើប្រាស់ដីជីសម្រាប់ផ្គត់ផ្គង់ទៅតាមតម្រូវការនៃការដាំដុះដំណាំនោះ។ ដើម្បីទទួលបាននៅផលដំណាំល្អមានជីវជាតិដោយគ្មានការបំផ្លិចបំផ្លាញពីមេរោគ ក៏ដូចជាសត្វល្អិតផ្សេងៗ ពិតណាស់ត្រូវតែមានការមើលថែរក្សាឱ្យបានល្អ ជាពិសេសត្រូវយកចិត្តទុកដាក់ក្នុងការដាំដុះនៃដំណាំនោះតាមរយៈការប្រើប្រាស់នូវជីគីមីថ្នាំសម្លាប់សត្វល្អិត និងសារធាតុគីមីផ្សេងៗទៀត។ សកម្មភាពនៃការប្រើប្រាស់នៅសារធាតុគីមីទាំងអស់នេះហើយ ដែលធ្វើឱ្យមានការបំពុលដី និងបរិស្ថានយ៉ាងធ្ងន់ធ្ងរ។

[៣២] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ. បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៣

[៣៣] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី២៦

- **ការបំពុលដោយសំណល់ផ្សេងៗ** ការបោះចោលសំណល់ដូចជា ថង់ប្លាស្ទិក កាតុង ក្រដាស កែវ សំណល់សរីរាង្គ សំបកដប សំបកកង់ឡាន សំបកកង់ម៉ូតូ វត្ថុទាំងអស់នេះមិនងាយរលាយទៅក្នុងធម្មជាតិទេ បើទោះបីជារលាយ ក៏មានរយៈពេលយូរដែរ ដែលធ្វើឱ្យបរិស្ថានមិនស្រស់ស្រាយ ហើយការបោះចោលសំរាមពាសវាលធ្វើឱ្យខូចនូវសោភ័ណភាពរបស់ដីថែមទៀតផង។

**គ. ការបំពុលខ្យល់**

ការបំពុលខ្យល់ គឺកើតចេញពីសកម្មភាពជាប្រចាំថ្ងៃរបស់មនុស្សដូចជា ផ្សែងដែលចេញពីយានយន្តគ្រប់ប្រភេទ ការបូជាសព ផ្សែងចេញពីរោងចក្រ សហគ្រាស សិប្បកម្ម អាហាដ្ឋាន។ល។[៣៤] ជាងនេះទៅទៀតសារធាតុដែលបំពុល គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ ឧស្ម័ន ចំហាយទឹក ក្លិន និងដោយសារតែសារធាតុវិទ្យុសកម្ម។ ការបំពុលខ្យល់ គឺប៉ះពាល់ជាខ្លាំងក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស ព្រោះមនុស្សគ្រប់រូបចាំបាច់ណាស់ត្រូវការខ្យល់សម្រាប់ដកដង្ហើម និងសម្រាប់ទ្រទ្រង់ជីវិតរស់នៅរបស់ខ្លួនប្រកបដោយសុខភាពល្អ ប្រសិនបើខ្យល់ត្រូវបានបំពុលច្បាស់ណាស់សុខភាពមនុស្សក៏ប៉ះពាល់ទៅតាមកម្រិតនៃការបំពុលនោះផងដែរ។

ប្រភពបំពុលត្រូវបានចែកចេញជាពីរ គឺប្រភពចល័ត និងប្រភពអចល័ត។

- **ប្រភពចល័ត** គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មានដូចជា យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្តជាដើម។
- **ប្រភពអចល័ត** គឺជាប្រភពដែលស្ថិតនៅទីតាំងដែលអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មានដូចជា រោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម សិប្បកម្ម និងកន្លែងកសិដ្ឋានគ្រប់ប្រភេទ។[៣៥]

ការកម្រិតនៅស្តង់ដាគុណភាពខ្យល់ និងកម្រិតស្តង់ដាអតិបរិមានៃសារធាតុពុលជារឿងដែលចាំបាច់សម្រាប់កត់សម្គាល់ដល់កម្រិតស្តង់ដានៃខ្យល់មានគុណភាព ឬមួយមានផលប៉ះពាល់យ៉ាងណា ដើម្បីឱ្យមានភាពងាយស្រួលក្នុងការទប់ស្កាត់ និងកាត់បន្ថយនៃកម្រិតជាតិពុលរបស់ឧស្ម័ន នោះវានឹងមានភាពល្អប្រសើរ

[៣៤] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៤៧

[៣៥] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ ៤២ អនក្រ. បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា៣

ក្នុងជីវភាពរស់នៅ។ ជាងនេះទៅទៀត កម្រិតស្តង់ដានេះ ក៏មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី២ ៣ និងទី៤នៃអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការបំពុលសំឡេង ត្រង់មាត្រា៤ និងមាត្រា៥ផងដែរ។

### ឃ. ការបំពុលដោយសំឡេង

ក្នុងការរស់នៅរបស់មនុស្សសំឡេង គឺមានសារៈសំខាន់ និងចាំបាច់បំផុតដែលត្រូវប្រើប្រាស់ក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក និងប្រើប្រាស់ទៅតាមតម្រូវការ ប៉ុន្តែប្រសិនបើសំឡេងនោះលើសពីកម្រិត និងលើសស្តង់ដានៃការបញ្ចេញ ឬប្រើប្រាស់នោះមានន័យថានឹងក្លាយជាការបំពុលសំឡេង។ លើសពីនេះទៀត ការបំពុលសំឡេង គឺធ្វើឱ្យមានការរំខានក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស ជាពិសេសប៉ះពាល់ទៅដល់ផ្នែកសតិអារម្មណ៍មនុស្សទាំងការស្តាប់ និងសុខភាពថែមទៀតផង។ ជាងនេះទៅទៀត កត្តាដែលនាំឱ្យមានការរំខានដោយសំឡេងរួមមានៈ

- ការប្រើប្រាស់នូវម៉ាស៊ីនភ្លើង
- ការប្រើប្រាស់នូវយានយន្ត
- ការប្រើប្រាស់នូវគ្រឿងចក្រ គ្រឿងយន្តដូចជា ត្រាក់ទ័រ រថយន្តសម្រាប់ដឹកជញ្ជូនសម្ភារៈ ឧបករណ៍លាយបេតុង គ្រឿងចក្រសម្រាប់កិនបង្ហាប់ និងគ្រឿងចក្រធុនៗ នៅតាមការដ្ឋានសាងសង់
- សំឡេងចេញពីក្លឹបកម្សាន្ត ខារ៉ាអូខេ ដែលមិនបានបំពាក់នូវឧបករណ៍ទប់សំឡេង
- ការបើកនូវសំឡេងទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ធុងបាស លាន់លឺសំឡេងខ្លាំង
- សំឡេងចេញពី រោងចក្រ យន្តហោះ រថភ្លើង
- ការប្រើប្រាស់នូវឧបករណ៍បំពងសំឡេងគ្រប់ប្រភេទជាដើម។[៣៦]

### ង. ការបំពុលដោយសំណល់រឹង-រាវ

នាសព្វថ្ងៃនេះកំណើនចំនួនប្រជាជនកើនឡើងយ៉ាងខ្លាំងនៅលើសកលលោក ដូច្នេះតម្រូវការជីវភាពរស់នៅក៏មានការកើនឡើង និងសម្បូរបែប ការរីកដុះដាលនៃនគរូបនីយកម្ម និងសំណង់ផងដែរ។ ជាងនេះទៀត ការរីកចម្រើនខាងវិស័យឧស្សាហកម្ម និងកសិកម្ម ក៏ជាហេតុដែលនាំឱ្យមានកាកសំណល់ជាច្រើនសន្ធឹកសន្ធាប់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។

[៣៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៤៤

សំណល់រឹង គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កម្ទេចកម្ទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។

សំរាម គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកសារធាតុជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ហើយ ត្រូវបញ្ចេញពីលំនៅដ្ឋាន អគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកម្សាន្ត។ល។

សំណល់ប្រកបដោយគ្រោះថ្នាក់ គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជំងឺ មហារីកដែលចម្លងជំងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមាន គ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ សំណល់ដែលប្រកបដោយគ្រោះថ្នាក់មានប្រភពមកពីលំនៅឋាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្ម អាជីវកម្មផ៉ើ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់មានចែងនៅក្នុង តារាងឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង លេខ៣៦ អ.ន.ក្រ.បក. ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩។[៣៧]

សំណល់រាវ គឺជាវត្ថុរាវ ដែលជាផលិតផល និងជាសារធាតុរួមផ្សំជាមួយនឹងសារធាតុរឹងខ្លះ ដែលត្រូវ បានគេ បញ្ចេញចោលជាប្រចាំ ទៅតាមប្រព័ន្ធលូទឹកស្អុយផ្សេងៗ។ មួយវិញទៀត សំណល់រាវ គឺសំដៅទៅលើ វត្ថុរាវដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុងទឹកសាធារណៈ ឬក៏ចូលទៅក្នុងបណ្តាញប្រព័ន្ធលូសាធារណៈទោះ បានធ្វើប្រព្រឹត្តកម្ម ឬក៏មិនបានធ្វើប្រព្រឹត្តកម្មក្តី។[៣៨]

ការបំពុលដោយសំណល់បានផ្តល់ផលប៉ះពាល់ទៅដល់សុខភាពរបស់មនុស្ស សត្វ ជាពិសេសបាន ប៉ះពាល់ដល់បរិស្ថាន ពោលគឺបរិស្ថានមិនស្រស់ស្រាយ ។ ដូច្នេះហើយការទុកដាក់សំណល់ដែលប្រើប្រាស់រួច ឱ្យបានត្រឹមត្រូវ ពិតជាសំខាន់ដែលត្រូវគិតគូរ និងយកចិត្តទុកដាក់។

## ២.២. បច្ចុប្បន្នភាព នៃការរៀបចំស្រុកកោះធំ

នាពេលបច្ចុប្បន្ននេះស្រុកកោះធំ គឺជាស្រុកមួយដែលកំពុងតែមានការអភិវឌ្ឍស្ទើរតែគ្រប់វិស័យរួមមាន វិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យកសិកម្ម វិស័យសុខាភិបាល វិស័យអប់រំ និងវិស័យធនធានទឹក។ល។ ទន្ទឹមនឹង ការអភិវឌ្ឍនេះឃើញថា រដ្ឋបាលស្រុកកោះធំ អាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋ ក៏បានខិតខំយកចិត្តទុកដាក់

[៣៧] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អមក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

[៣៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៣២

ចូលរួមសហការគ្នាក្នុងការអភិវឌ្ឍស្រុករបស់ខ្លួនឱ្យកាន់តែល្អប្រសើរ និងរីកចម្រើនទៅមុខថែមទៀត។ ជាក់ស្តែងក្នុងបច្ចុប្បន្នភាពនៃស្រុកកោះធំនេះ ក៏មានលេចឡើងនូវសមិទ្ធផល និងការអភិវឌ្ឍវិស័យមួយចំនួនដូចជា៖

### ២.២.១. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ

វិស័យហេដ្ឋារចនាសម្ព័ន្ធ បានដើរតួយ៉ាងសំខាន់ក្នុងការជួយសម្រួលដំការអភិវឌ្ឍប្រទេសជាតិឱ្យមានសក្តានុពលកាន់តែខ្លាំងទៅមុខថែមទៀត។ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ និងពង្រឹងនូវគុណភាពក្នុងការអភិវឌ្ឍវិស័យមួយនេះឱ្យកាន់តែមានភាពរីកចម្រើនរលូនទៅមុខកាន់តែឆាប់រហ័ស និងប្រកបដោយស្តង់ដានៃការអភិវឌ្ឍប្រទេសជាតិផងដែរ។ ជាមួយគ្នានេះដែរ រដ្ឋបាលស្រុកកោះធំ ក៏បានអនុវត្តន៍ផែនការ និងគម្រោងនៃការអភិវឌ្ឍវិស័យមួយនេះឱ្យស្របតាមតម្រូវការ ជាពិសេសក៏បានបញ្ចប់នូវគម្រោងមួយចំនួន និងទទួលបាននូវសមិទ្ធផលនៃវិស័យហេដ្ឋារចនាសម្ព័ន្ធនេះដូចជា៖

**ការកសាងផ្លូវ** ដើម្បីងាយស្រួលដល់ការធ្វើដំណើរទៅមក ឬការដឹកជញ្ជូនទំនិញផ្សេងៗ ពិតណាស់ផ្លូវគឺជាកត្តាដ៏សំខាន់ដែលត្រូវតែគិតគូរ និងយកចិត្តទុកដាក់។ ការកសាងប្រព័ន្ធផ្លូវដែលល្អប្រកបដោយគុណភាព និងស្តង់ដាបានផ្តល់ភាពងាយស្រួល ឆាប់រហ័ស ជាពិសេសចំណេញពេលក្នុងការធ្វើដំណើរផងដែរ។ នៅក្នុងស្រុកកោះធំ ក៏មាននូវប្រព័ន្ធផ្លូវសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋងាយស្រួលក្នុងការធ្វើដំណើរ ជាពិសេសសម្រាប់ដឹកជញ្ជូនទំនិញផ្សេងៗ ដែលប្រព័ន្ធផ្លូវដែលបានកសាងនោះរួមមាន ផ្លូវជាតិលេខ២១ ផ្លូវជាតិលេខ១១០ និងផ្លូវបេតុងជាច្រើនខ្សែទៀត។ [៣៩]ហើយថ្មីៗនេះកំពុងតែបើកការដ្ឋានគម្រោងលើកកម្រិតជួសជុល និងថែទាំកំណាត់ផ្លូវជាតិលេខ២៣ដែលស្ថិតនៅក្នុងស្រុកកោះធំ និងស្រុកលើកដែក នៃខេត្តកណ្តាល ដែលមានប្រវែងសរុប ១៩.៨៣គីឡូម៉ែត្រ។ កំណាត់ផ្លូវជាតិលេខ២៣នេះ គឺជាផ្នែកមួយនៃផ្លូវជាតិលេខ២៣ ដែលជាខ្សែផ្លូវតភ្ជាប់រវាងខេត្តកណ្តាល និងខេត្តតាកែវ ដោយឆ្លងកាត់ស្រុកសំរោង ស្រុកព្រៃកប្បាស ស្រុកកោះធំ និងស្រុកលើកដែក។ គម្រោងនេះនឹងត្រូវស្តាបនាពង្រីកទទឹងតួផ្លូវប្រវែង ១១ម៉ែត្រ និងក្រាលកៅស៊ូ កម្រាស់ ៨សង់ទីម៉ែត្រ លើទទឹងតួផ្លូវប្រវែង ១០ម៉ែត្រ មានគន្លងសម្រាប់រថយន្ត និងគន្លងសម្រាប់ទោចក្រយានធ្វើចរាចរណ៍។[៤០]

**ការកសាងស្ពាន** ស្រុកកោះធំ ជាស្រុកមួយដែលជាប់នឹងទន្លេបាសាក់ ហើយក៏បានបែកចែកជាពីរត្រើយ គឺត្រើយខាងលិច និងត្រើយខាងកើត។ នាពេលបច្ចុប្បន្ននេះប្រជាពលរដ្ឋនៅក្នុងស្រុកកោះធំ ក៏មាន

[៣៩] គេហទំព័រ https://freshnewsasia.com/index.php/en/localnews/241433-2022-05-08-11-45-48.html ចូលទស្សនានៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤

[៤០] គេហទំព័រ https://www.cpp.org.kh/details/349851 ចូលទស្សនានៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៤

ស្ពានសម្រាប់ឆ្លងកាត់ធ្វើដំណើរទៅមកបានល្អប្រសើរហើយ ដោយកាលពីមុនដើម្បីធ្វើដំណើរឆ្លងកាត់ទៅមកបានប្រជាពលរដ្ឋត្រូវតែឆ្លងទន្លេបាសាក់ដោយត្រូវប្រើមធ្យោបាយឆ្លងកាត់ផ្លូវទឹកតាមរយៈដចម្លង ប៉ុន្តែកន្លងទៅនេះប្រជាពលរដ្ឋក្នុងស្រុកកោះធំ ក៏ទទួលបាននូវស្ពានសម្រាប់ឆ្លងកាត់ទន្លេបាសាក់ដ៏រឹងមាំមួយ និងមានលក្ខណៈស្តង់ដាបច្ចេកទេសនោះ គឺស្ពាន មិត្តភាពកម្ពុជា-ចិន (ស្ពានកោះធំ)។

ស្ពានកោះធំ ស្ថិតក្នុងភូមិព្រែកធន់ ឃុំព្រែកថ្មី ស្រុកកោះធំ ដែលលាតសន្ធឹងកាត់ដងទន្លេបាសាក់ប្រវែង៤១៥ម៉ែត្រ និងត្រូវដាក់ឱ្យដំណើរការជាផ្លូវការនៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧។ ស្ពានសម្រាប់ឆ្លងកាត់ទន្លេបាសាក់ក្នុងស្រុកកោះធំនេះ ត្រូវបានបើកការដ្ឋានសាងសង់កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ហើយត្រូវបានចំណាយថវិកាសាងសង់ ១៩.៣៩លានដុល្លារអាមេរិក។ ស្ពានកោះធំ តភ្ជាប់ពីផ្លូវជាតិលេខ២១ត្រង់ចំណុចភូមិព្រែកធន់ ឃុំព្រែកថ្មី ស្រុកកោះធំ ត្រើយខាងលិចទន្លេបាសាក់ ឆ្លងទៅផ្លូវជាតិលេខ១១០ នៅមាត់ទន្លេត្រើយខាងកើតទន្លេបាសាក់ ស្ថិតក្នុងភូមិព្រែកថ្មី ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល។[៤១] ការកសាងស្ពាននេះឡើង គឺជួយសម្រួលការធ្វើដំណើររបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែរស្ថិតនៅត្រើយខាងកើតទន្លេបាសាក់ ដែលតែងតែជួបការលំបាកខ្លាំងក្នុងការធ្វើដំណើរដឹកកសិផលទៅទីផ្សារ ទៅសាលារៀន និងទៅមន្ទីរពេទ្យ ជាពិសេសនៅពេលជួបគ្រោះអាសន្នពេលយប់ដូចជា មានជំងឺឈឺស្កាត់ ឬស្ត្រីត្រូវសម្រាលកូននៅពេលយប់ជាដើម។

**កីឡដ្ឋាន** កីឡដ្ឋានស្រុកកោះធំ ត្រូវបានដាក់សម្ពោធឱ្យប្រើប្រាស់នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨ ដែលមានតារាងបាល់ទាត់ទំហំស្តង់ដាអន្តរជាតិ និងទីលានកីឡាផ្សេងៗទៀត។ កីឡដ្ឋាននេះ ត្រូវបានសាងសង់ឡើងដោយចំណាយថវិកាអស់សរុប ៤២ម៉ឺនដុល្លារសហរដ្ឋអាមេរិក ដែលក្នុងនោះតារាងបាល់ទាត់មានប្រវែង១០៥ម៉ែត្រ និងទទឹង ៦៨ម៉ែត្រ សាងសង់ឡើងតាមស្តង់ដាអន្តរជាតិ ដោយកាលពីមុនជាដីលេចទឹកមិនអាចធ្វើការហ្វឹកហាត់បាន និងបច្ចុប្បន្នកីឡដ្ឋាននេះត្រូវបានប្រែក្លាយទៅជាមជ្ឈមណ្ឌលកីឡាដ៏ល្អមួយ ដែលជាកន្លែងសំខាន់សម្រាប់សិស្សានុសិស្សធ្វើការហ្វឹកហាត់កីឡាដើម្បីសុខភាព។[៤២]

---

[៤១] គេហទំព័រ https://freshnewsasia.com/index.php/en/localnews/276051-2023-01-31-14-18-26.html ចូលទស្សនានៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤

[៤២] គេហទំព័រ https://www.mpwt.gov.kh/en/press/3337 ចូលទស្សនានៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤

### ២.២.២. ការអភិវឌ្ឍវិស័យកសិកម្ម

ប្រទេសកម្ពុជា គឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម ហើយមានប្រជាពលរដ្ឋប្រមាណ៨០%ទាំងអស់នៅជនបទក្នុងនោះភាគច្រើនប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចសង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែចាត់ទុកថា កសិកម្ម គឺជាវិស័យមួយដែលមានអាទិភាពខ្ពស់ នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិ។

ការរីកចម្រើននៃវិស័យកសិកម្ម គឺជាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលវិស័យនេះបានចូលរួមចំណែកយ៉ាងច្រើនក្នុងកំណើនផលិតផលសរុបក្នុងស្រុក និងសេដ្ឋកិច្ច។ នាពេលបច្ចុប្បន្ននេះ វិស័យកសិកម្ម បានទ្រទ្រង់ដល់ការអភិវឌ្ឍប្រទេសជាតិ និងបានធ្វើឱ្យមានស្ថេរភាព ដោយសារការរីកចម្រើនប្រព័ន្ធធារាសាស្ត្រ ការចាប់យកនូវបច្ចេកវិជ្ជាកសិកម្ម ការខិតខំប្រឹងប្រែង ពិសេសសកម្មភាពស្រាវជ្រាវកសិកម្មដើម្បីឱ្យស្របទៅតាមបម្រែបម្រួលអាកាសធាតុ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ សម្រាប់ជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយនូវវិស័យកសិកម្ម និងជនបទ ដើម្បីការកាត់បន្ថយភាពក្រីក្រឱ្យបានក្នុងកម្រិតមួយសមស្របតាមរយៈការបង្កើនផលិតភាពកសិកម្ម ធានានូវសន្តិសុខស្បៀង បង្កើតការងារ និងបង្កើនចំណូលគ្រួសារកសិករ។ ជាការកត់សម្គាល់ នាពេលកន្លងមក វិស័យនេះអាចធានាបាននូវអតិបរិមានៃផលិតផលកសិកម្មបម្រើឱ្យការនាំចេញច្រើនទៀត។ ជាងនេះទៅទៀត នៅក្នុងការអភិវឌ្ឍវិស័យកសិកម្មនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកយ៉ាងខ្លាំងខ្លា ហើយក៏មាននូវការបង្កើតសហគមន៍កសិកម្មឡើងផងដែរ។ ការបង្កើតសហគមន៍នេះឡើងមានគោលបំណងជួយលើកកម្ពស់ការចូលរួមដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានមុខរបរចម្បងស្ថិតនៅក្នុងប្រព័ន្ធកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្មក្នុងការបង្កើត និងការអភិវឌ្ឍ ការលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។[៤៣]

សហគមន៍កសិកម្មចំនួន ១១ នៃស្រុកកោះធំ ស្រុកលើកដែក និងស្រុកស្អាងបានស្ម័គ្រចិត្តរួមគ្នាបង្កើតសហភាពសហគមន៍កសិកម្មស្ថិតនៅក្នុងខេត្តកណ្តាល ដែលមានគោលបំណង ដើម្បីប្រមូលផ្តុំកម្លាំងផលិតកម្ម មធ្យោបាយផលិតកម្ម និងពង្រីកសមត្ថភាពនៅក្នុងផលិតកម្មកសិកម្ម រួមទាំងសេវាកម្មពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម។ ការបង្កើតសហភាពសហគមន៍កសិកម្មក្នុងខេត្តកណ្តាលនេះមានសារៈសំខាន់ និងចាំបាច់ណាស់

[៤៣] ច្បាប់ ស្តីពីសហគមន៍កសិកម្ម, លេខ នស/រកម/០៦១៣/០០៨, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៣, មាត្រា១

ក្នុងការជំរុញផលិតកម្ម និងទីផ្សារផលិតផលកសិកម្ម ជាពិសេសដំណាំបន្លែចម្រុះ ស្របទៅតាមផែនការអភិវឌ្ឍន៍វិស័យកសិកម្មរបស់ខេត្តកណ្ដាល និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។[៤៤]

ស្រុកកោះធំ គឺជាស្រុកមួយដែលមានសក្ដានុពលទៅលើវិស័យកសិកម្ម ដែលនៅស្រុកកោះធំនេះ ក៏មាននៅសមាគមន៍កសិកម្មប្រចាំនៅក្នុងស្រុកដើម្បីគ្រាំទ្រ និងលើកកម្ពស់ដល់វិស័យកសិកម្មនៅក្នុងស្រុករបស់ខ្លួនប្រកបដោយភាពរីកចម្រើនទៅមុខថែមទៀត។ មិនតែប៉ុណ្ណោះ រដ្ឋបាលស្រុកកោះធំ ក៏បានរៀបចំផ្គត់ផ្គង់នូវប្រព័ន្ធទឹកសម្រាប់ផ្ដល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការស្រោចស្រពដំណាំ ចិញ្ចឹមសត្វ និងប្រើប្រាស់ទៅតាមតម្រូវការក្នុងការប្រកបមុខរបរកសិកម្មផងដែរ ហើយរដ្ឋបាលស្រុកកោះធំនឹងនៅតែបន្តសកម្មភាពក្នុងការរួមចំណែកលើកកម្ពស់វិស័យកសិកម្មមួយនេះឱ្យកាន់តែមានសក្ដានុពលទៅមុខបន្តបន្ទាប់ទៀត ដោយសារតែមានការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍវិស័យកសិកម្មនេះ ទើបធ្វើឱ្យប្រជាពលរដ្ឋដែលនៅក្នុងស្រុកកោះធំជាច្រើនគ្រួសារបានប្រកបមុខរបរធ្វើស្រែចំការ ចិញ្ចឹមសត្វ នេសាទ និងដាំដុះដំណាំផ្សេងៗទៀត ដើម្បីចិញ្ចឹមជីវិត ជាពិសេសសម្រាប់ផ្គត់ផ្គង់តម្រូវការជីវភាពរស់នៅប្រចាំថ្ងៃផងដែរ។ បើគិតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ សកម្មភាពក្នុងការបង្កបង្កើនផលមានដូចខាងក្រោម៖

**ដំណាំស្រូវ**

- ស្រូវប្រាំង ផែនការ ៤ ៥៥០ហិកតា អនុវត្តន៍បាន ៨៦ហិកតា។
- អនុផលប្រាំង ផែនការ ២ ៥៥៥ហិកតា អនុវត្តន៍បាន ៥០,៥ហិកតា។
- ស្រូវវស្សា ផែនការ ៧៥០ហិចតា អនុវត្តន៍បាន ១ ៣៥៥ហិចតា ប្រមូលផលបាន ១ ៣៥៥ ស្មើ ១០០% ទិន្នផលមធ្យម ៤,៣តោន/ហិកតា បរិមាណផល ៥ ៨២៧តោន។
- អនុផលវស្សា ផែនការ ១ ៦៣៩ហិចតា អនុវត្តន៍បាន ៩៤០.៥ហិចតា ប្រមូលផលបាន ៩៤០.៥ ស្មើ ១០០% បរិមាណផល ៦ ៥៨៣,៥តោន។
- ស្រូវប្រាំង ផែនការ ១៧ ០០០ហិចតា អនុវត្តន៍បាន ១៧ ៤៦៣ហិចតា ប្រមូលផល ១៧ ១៣៣ហិកតា ស្មើ ៩៨,១១% ទិន្នផលមធ្យម ៤.៧តោន/ហិកតា បរិមាណផលសរុប ៨០៥២៥,១០តោន។
- អនុផលប្រាំង ផែនការ ៦ ០៨៥ហិកតា, អនុវត្តន៍បាន ៤ ៧១៨ហិកតា ប្រមូលផល ៤ ៧១៨ហិកតា ស្មើ ១០០% បរិមាណផលសរុប ២៥ ៩៩៣,២៩តោន។

[៤៤] គេហទំព័រ រដ្ឋបាលខេត្តកណ្ដាល https://www.kandal.gov.kh/detail/11354 ចូលទស្សនានៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤

**ការចិញ្ចឹមត្រី**

- ការចិញ្ចឹមត្រីចម្រុះតាមស្រះ មានចំនួន ១៨គ្រួសារ ស្មើនឹង១៨ស្រះ មានផ្ទៃសរុប ៣៤,២០០ម៉ែត្រក្រឡា កូនត្រីពូជចំនួន ៥២០,០០០ក្បាល និងបរិមាណផលចំនួន ១១៤,៨៤៦គីឡូក្រាម។
- ការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោះតាមស្រះ មានចំនួន ០៧គ្រួសារ ស្មើនឹង០៧ស្រះ មានផ្ទៃសរុប ១១,៣០០ ម៉ែត្រក្រឡា កូនត្រីពូជចំនួន ១៨០,០០០ក្បាល និងបរិមាណផលចំនួន ៦១,៣៩១គីឡូក្រាម។
- ការចិញ្ចឹមត្រីចម្រុះតាមបែរ មានចំនួន ១១គ្រួសារ ស្មើនឹង ១១បែរ មានផ្ទៃសរុប ៣,២១៤ម៉ែត្រក្រឡា កូនត្រីពូជចំនួន ២០,០០០ក្បាល និងបរិមាណផលចំនួន ៤,៤១៧គីឡូក្រាម។
- ការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោះតាមបែរ មានចំនួន១០គ្រួសារ ស្មើនឹង១០បែរ មានផ្ទៃសរុប ២១១ ម៉ែត្រក្រឡា កូនត្រីពូជចំនួន ៣៥,០០០ក្បាល និងបរិមាណផលចំនួន ១៥,៩១៩គីឡូក្រាម។[៤៥]

### ២.២.៣. ការអភិវឌ្ឍវិស័យសុខាភិបាល

សមិទ្ធផល និងវឌ្ឍនភាពជាច្រើននៅក្នុងវិស័យសុខាភិបាលកំពុងតែបន្តកើតមានក្នុងការផ្តល់នូវសេវាសុខភាពតាមរយៈអន្តរាគមន៍នៃកម្មវិធីសុខភាពបន្តពូជ សុខភាពមាតា-ទារក កុមារ និងអាហារូបត្ថម្ភលើស្ត្រី និងកុមារ កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ។ ការពង្រីកការគ្របដណ្តប់នៃសេវាសុខភាព និងអន្តរាគមន៍សុខភាពសាធារណៈបានដើរទន្ទឹមគ្នាទៅនឹងការកែលម្អគុណភាពសេវាបង្ការពិនិត្យព្យាបាល និងថែទាំឱ្យកាន់តែប្រសើរឡើង។ សមធម៌ក្នុងការមកទទួលបានសេវាសុខភាពសុខាភិបាលត្រូវបានលើកស្ទួយជាបន្តបន្ទាប់តាមរយៈការគ្របដណ្តប់នៃមូលនិធិសមធម៌នៅទូទាំងប្រទេស ដែលបានផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ រួមជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកលែងនូវការបង់ថ្លៃសេវា ដោយបានដករបាំងឧបសគ្គភូមិសាស្ត្រផង និងរបាំងឧបសគ្គហិរញ្ញវត្ថុផង ពោលគឺផ្តល់ការបង្ការហានិភ័យហិរញ្ញវត្ថុដល់គ្រួសារក្រីក្រ ឱ្យមកប្រើប្រាស់សេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈដោយគ្មានបង់ថ្លៃនៅពេលមានបញ្ហាសុខភាព ឬជំងឺ។ ប្រការនេះមិនត្រឹមតែបានជួយលើកកម្ពស់នៅស្ថានភាពសុខភាព ប្រជាពលរដ្ឋក្រីក្រឱ្យកាន់តែប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានការពារប្រជាពលរដ្ឋទាំងនោះកុំឱ្យធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រ ដោយសារការចំណាយលើការថែទាំសុខភាពផងដែរ។ រាជរដ្ឋាភិបាលក៏បានធ្វើការវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលមានជាអាទិ៍ ការសាងសង់ថ្មី ពង្រីក និងជួសជុលប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ការផ្គត់ផ្គង់ឱសថបរិក្ខារ និងឧបករណ៍ពេទ្យ បណ្តាញ

---

[៤៥] របាយការណ៍ ស្តីពីការអនុវត្តការងាររដ្ឋបាល ស្រុកកោះធំ ប្រចាំឆ្នាំ២០២៣

ទំនាក់ទំនង ព័ត៌មានវិទ្យា ទូរគមនាគមន៍ និងបច្ចេកវិទ្យា មធ្យោបាយដឹកជញ្ជូន និងរថយន្តគិលានសង្គ្រោះ ដោយបានបណ្តុះបណ្តាលធនធានមនុស្ស អភិវឌ្ឍន៍សមត្ថភាពជំនាញ និងពង្រឹងសមត្ថភាពសេវាគាំទ្រដូចជា សេវាមន្ទីរពិសោធន៍ សេវាផ្តល់ឈាម។ល។ ការវិនិយោគទាំងអស់នេះបានរួមចំណែកយ៉ាងធំធេងដល់ការលើក កម្ពស់លទ្ធភាពមកទទួល និងប្រើប្រាស់សេវាសុខភាពដោយប្រជាពលរដ្ឋព្រមទាំងកែលម្អគុណភាពនៃសេវា ថែទាំសុខភាព។ [៤៦] ជាក់ស្តែង ឃើញថាស្រុកកោះធំ ក៏មាននៅមាននូវមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព កន្លែងផ្តល់សេវាសុខភាពនៅតាមភូមិ ឃុំ ស្រុកសម្រាប់ផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋ និងជួយសម្រួល ដល់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ ដើម្បីអាចមកព្យាបាលបញ្ហាសុខភាព ឬជំងឺឈឺស្កាត់របស់ខ្លួនផងដែរ។ ជាងនេះទៅទៀត នាពេលថ្មីៗនេះនៅក្នុងស្រុកកោះធំ ក៏ឃើញមានលេចរូបរាងឡើងនូវសមិទ្ធផលមន្ទីរពេទ្យដ៏ថ្មី មួយយ៉ាងទំនើបប្រកបដោយលក្ខណៈស្តង់ដា សម្រាប់ផ្គត់ផ្គង់ និងសម្រាប់ជួយសម្រួលសេវាសុខភាពជូនដល់ ប្រជាពលរដ្ឋ។

**មន្ទីរពេទ្យតេជោសែនកោះធំ** បិតនៅស្រុកកោះធំ ខេត្តកណ្តាល ដែលមន្ទីរពេទ្យនេះបានដាក់សម្ពោធឱ្យ ប្រើប្រាស់ជាផ្លូវការនាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ សាងសង់ឡើងដោយថវិកាបានមកពីការចូលរួមវិភាគទាន របស់សប្បុរសជននៅក្នុងស្រុកទាំងអស់ ដោយបានចូលរួមសហការជាមួយនឹងមន្ទីរពេទ្យកាល់ម៉ែត្រ ចំណាយ ថវិកាសរុបទាំងអស់ ១០លានដុល្លារសហរដ្ឋអាមេរិក។ ក្នុងនោះដែរការសាងសង់រចនាសម្ព័ន្ធអគារមន្ទីរពេទ្យ ចំណាយទឹកប្រាក់ ៦លាន២សែនដុល្លារសហរដ្ឋអាមេរិក និងធ្វើការបំពាក់សម្ភារបរិក្ខារពេទ្យចំណាយទឹកប្រាក់ពី ៤ ទៅ ៥លានដុល្លារសហរដ្ឋអាមេរិក។ លើសពីនេះទៀត មន្ទីរពេទ្យតេជោសែនកោះធំនេះនឹងក្លាយជាមន្ទីរពេទ្យ មានទីតាំងសម្រាប់ផ្តល់នូវសេវាសុខាភិបាលសាធារណៈជូនដល់ប្រជាពលរដ្ឋប្រមាណជាង ៦០ម៉ឺននាក់ដែល រស់នៅក្នុងស្រុកស្អាង ស្រុកកោះធំ ស្រុកលើកដែក នៃខេត្តកណ្តាល និងស្រុកព្រែកប្បាស នៃខេត្តតាកែវ ហើយ មន្ទីរពេទ្យនេះត្រូវបានកសាងឡើងក្រោមការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល ដែលបានគិតគូរយកចិត្តទុកដាក់លើ សុខទុក្ខ សុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ជាងនេះទៅទៀត ការសាងសង់មន្ទីរពេទ្យនេះត្រូវ បានសាងសង់អគារថ្មីចំនួន ០៣ខ្នង អគារទាំង ០៣ខ្នងនេះមានទំហំសរុបស្មើនឹង ១២.៥៤៤,៤ម៉ែត្រការ៉េ ដែល ផ្ទុកគ្រែអ្នកជំងឺបានចំនួន ១៥០គ្រែ បំពាក់ដោយម៉ាស៊ីនត្រជាក់ សម្ភារបរិក្ខារពេទ្យ និងឧបករណ៍បច្ចេកទេស ដ៏ទំនើបៗបម្រើឱ្យការព្យាបាល។[៤៧]

[៤៦] គេហទំព័រ https://moh.gov.kh/archives/2863 ចូលទស្សនានៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤

[៤៧] គេហទំព័រ https://mpwt.gov.kh/en/press/37412 ចូលទស្សនានៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

## ២.២.៤. ការអភិវឌ្ឍវិស័យអប់រំ

| ផ្នែក | សាលា/កន្លែង | ថ្នាក់ | បុគ្គលិក | សិស្ស |
|---|---|---|---|---|
| មត្តេយ្យរដ្ឋ | ១១ | ១៩ | សរុប១៩ ស្រី១៩ | សរុប៥៨៧ ស្រី២៨៩ |
| មត្តេយ្យសហគមន៍ | ៨ | ១០ | សរុប៨ ស្រី៨ | សរុប២០២ ស្រី១១១ |
| បឋមសិក្សា | ១៨ | ២៣០ | សរុប២១២ ស្រី១២៤ | សរុប៨,៤២៦ ស្រី៣,៩៩៦ |
| អនុវិទ្យាល័យ | ០៤ | ២៩ | សរុប៦១ ស្រី៣៣ | សរុប១,៣៩១ ស្រី៧២២ |
| វិទ្យាល័យ | ០៣ | ៨០ | សរុប១៧៦ ស្រី ៦៦ | សរុប៣,៦៦៨ ស្រី ១,៩៧៣ |
| ការិយាល័យអប់រំ | | | សរុប០៤ ស្រី ០០ | |
| **សរុប** | ៤៣ | ៣៦៦ | សរុប៤៨០ ស្រី ២៥០ | សរុប១៤,២៧៤ ស្រី ៧,០៩១ |

វិស័យអប់រំ គឺជាស្នូលយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយចំណេះដឹង គុណភាព និងការអភិវឌ្ឍ។ ក្នុងនោះផងដែរ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍធនធានមនុស្ស នៅក្នុងប្រទេសកម្ពុជាស្របទៅតាមតម្រូវការ និងចក្ខុវិស័យនៃការអភិវឌ្ឍប្រទេសផងដែរ។ ដើម្បីឱ្យកាន់តែមាន ភាពងាយស្រួលក្នុងការបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសឱ្យបានល្អប្រសើរ ការបង្កើតសាលារៀន គឺជា កត្តាចម្បងក្នុងការទទួលបានភាពងាយស្រួលក្នុងការអប់រំបណ្តុះបណ្តាលធនធានមនុស្ស។ ជាក់ស្តែង នៅក្នុង ស្រុកកោះធំ ក៏មានសាលារៀនគ្រប់កម្រិត ចាប់តាំងពីកម្រិតថ្នាក់មត្តេយ្យរហូតដល់វិទ្យាល័យ ដែលសាលារៀន ទាំងអស់នេះជាកន្លែងដ៏មានតម្លៃទុកសម្រាប់អប់រំបណ្តុះបណ្តាលសិស្សានុសិស្សក្នុងស្រុក ដើម្បីទទួលបាននូវ ធនធានប្រកបដោយ ចំណេះដឹង គុណភាព និងការអភិវឌ្ឍទៅមុខ។ ជាងនេះទៅទៀត ក្នុងឆ្នាំ២០២៣កន្លងមក នេះពុំមានជំងឺកូវីដ១៩កើតឡើងទេ សិស្សនៅតាមវិទ្យាល័យទាំង៣ របស់ស្រុកកោះធំចំនួន ៦០៣នាក់ក្នុងនោះ មានស្រី ៣៤២នាក់ បានចូលរៀននៅតាមក្នុងថ្នាក់នីមួយៗតាមធម្មតាវិញ ហើយបានធ្វើការដាក់ពាក្យប្រលង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០២៣ ទាំងអស់ចំនួន ៦០៣នាក់ ស្រី ៣៤២នាក់ ។ សិស្សបានទៅ ប្រឡងចំនួនសរុប ៦០៣នាក់ក្នុងនោះ ស្រី ៣៤២នាក់ និងអវត្តមាន០នាក់ ដែលលទ្ធផលប្រឡងសិស្សបាន

ជាប់ចំណាត់និទ្ទេសAចំនួន ២០នាក់ ស្រី ១៤នាក់ និទ្ទេសBចំនួន ៥៦នាក់ ស្រី ២៩នាក់ និទ្ទេសCចំនួន ១០៤នាក់ ស្រី ៦៣នាក់ និទ្ទេសDចំនួន ១០៦នាក់ ស្រី ៧១នាក់ និទ្ទេសEចំនួន ១២៦នាក់ ស្រី ៦៨នាក់ និទ្ទេសFចំនួន ១៩១នាក់ ស្រី ៩៦នាក់ និងសរុប ៦០៣នាក់ ស្រី ៣៤១នាក់ ស្មើ៦៨,៣៣% ។[៤៨]

### ២.២.៥. ការអភិវឌ្ឍវិស័យធនធានទឹក

ទឹក គឺជាធនធានដ៏សំខាន់ និងមានតម្លៃមួយដែលប្រជាពលរដ្ឋពឹងផ្អែកយ៉ាងខ្លាំងសម្រាប់ផ្គត់ផ្គង់ក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។ បុគ្គលគ្រប់រូប មានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងទៀត រួមមាន ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឱ្យមាន ការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។[៤៩]

ធនធានទឹកនៃប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងក្រោមច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកឆ្នាំ២០០៧។ ជាមួយគ្នានេះដែរ ក៏មាននៅការបង្កើតនៅក្រសួងធនធានទឹក និងឧតុនិយមសម្រាប់គ្រប់គ្រងធនធានទឹកនៅកម្ពុជាផងដែរ។ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ដើម្បីអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹកនៅប្រទេសកម្ពុជា ជាពិសេសទៀតនោះដើម្បីត្រួតពិនិត្យលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹកជំនន់។ ក្រសួងនេះ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងធនធានទឹកសាប និងសមុទ្រខណៈដែលក្រសួងអភិវឌ្ឍន៍ជនបទទទួលបន្ទុកលើការផ្គត់ផ្គង់ទឹកនៅតាមជនបទ។[៥០] ជាក់ស្តែង រដ្ឋបាលស្រុកកោះធំបានខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍នូវប្រព័ន្ធធនធានទឹកក្នុងស្រុករបស់ខ្លួនដើម្បីផ្គត់ផ្គង់ទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋផងដែរ។ ជាងនេះទៅទៀត ក៏បានចូលរួមខិតខំប្រឹងប្រែងក្នុងការអនុវត្តសកម្មភាពផ្សេងៗ និងរិះរកដំណោះស្រាយក្នុងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រឱ្យបានល្អប្រសើរឡើងដូចជា៖

- ចូលរួមចុះពិនិត្យ ស្ថានភាពទឹកបឹង និងទឹកអាងម្លេច ពាក់ព័ន្ធឃុំលើកដែក, ឃុំកំពង់កុង ស្រុកកោះធំ ដឹកនាំដោយលោកអភិបាលរងស្រុក។ ពិនិត្យ ជាទូទៅស្ថានភាពទឹក ពុំធ្វើឱ្យខូចខាតដល់ផលដំណាំកសិកម្ម, ប្រព័ន្ធធារាសាស្ត្រ និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋទេ។

---

[៤៨] សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល ស្រុកកោះធំ ឆ្នាំ២០២៤-២០២៦

[៤៩] ច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧, មាត្រា១

[៥០] ច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម, លេខ នស/រកម/០៦៩៩/០៨, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩

- បានចូលរួមពិភាក្សា នៅសាលាឃុំលើកដែក ស្តីពីការស្នើបង្ហូរទឹកចេញពីអាងទឹករាំងកូនក្អែក ស្ថិតនៅភូមិលើកដែក ឃុំលើកដែក និងមួយកន្លែងទៀត គឺអាងម្លេច ដើម្បីពន្លឿនការសាងសង់ផ្លូវលេខ២៣ (ទឹកលិចផ្លូវ និងជើងផ្លូវនៅកន្លែងទំនាបដោយកន្លែង) ក្រោយពីបានពិភាក្សារួច ក៏ចុះពិនិត្យដល់ទីតាំងជាក់ស្តែង ឃើញថាទឹកលិចប្រាកដមែន។ អភិបាលរងតំណាងលោកអភិបាលស្រុក បានណែនាំដល់ក្រុមការងារក៏ដូចជា តំណាងក្រុមហ៊ុនសាងសង់ផ្លូវលេខ២៣ថា ពាក់ព័ន្ធនឹងការបង្ហូរទឹកចោលដើម្បីពន្លឿនការសាងសង់ផ្លូវ គឺមិនអនុញ្ញាតឱ្យបើកទឹកចោលទេ និងនៅកន្លែងជីកបង្ហូរទឹកនោះ ត្រូវធ្វើការបិទខ្ទប់វិញជាបន្ទាន់ដោយឱ្យក្រុមហ៊ុនរងចាំទឹកស្រក និងស្នើសុំយោបល់ពីលោកអភិបាលដើម្បីរកវិធីជួយពន្លឿនឱ្យក្រុមហ៊ុនឆាប់បានសាងសង់។
- ចូលរួមចុះពិនិត្យ និងជួយផ្តល់យោបល់សម្របសម្រួលលើករណីបាក់ច្រាំងទន្លេបាសាក់ដល់ផ្ទះរបស់បងប្អូន ប្រជាពលរដ្ឋចំនួន ០២ខ្នង។
- ចូលរួមចុះពិនិត្យ ស្ថានភាពទឹកទន្លេបាសាក់ហូរចូលតាមបណ្តាព្រែកទៅបំពេញអាងម្លេចដែលពាក់ព័ន្ធនៅក្នុងឃុំលើដែក ស្រុកកោះធំ ជាលទ្ធផលឃើញថាទឹកទន្លេបាសាក់បានបំពេញអាងម្លេច១០០% លើសពីសេចក្តីត្រូវការ។
- ចូលរួមចុះពិនិត្យ ព្រែកតាហ៊ីង ភូមិព្រែកតាហ៊ីង, ព្រែកយាយហាយ ភូមិព្រែកយាយហាយ ឃុំព្រែកថ្មី ដែលរងប៉ះពាល់រអិលច្រាំងព្រែកកន្លងមក ជាលទ្ធផលធ្វើសំណើទៅមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ដើម្បីស្នើសុំទៅ។
- បានចូលរួមសហការ ជាមួយមន្ត្រីជាប់កិច្ចសន្យានៃមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ចុះពិនិត្យស្ថានភាពទឹកបឹងក្រៅ (ពីទន្លេមេគង្គ) ដែលកំពង់តែហូរចូលអាងទឹកស្រះ៨ទៅតាមប្រឡាយទ្វារទឹកលេខ១៤ និងលេខ១៤,៥ ផ្នែកខាងជើង ដោយកម្រិតទឹកហូរចូល ២០%។
- ចូលរួមសហការជាមួយមន្ត្រីមកពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកណ្តាល, មន្ត្រីជាប់កិច្ចសន្យានៃមន្ទីរធនធានទឹក និងឧតុនិយមខេត្ត និងលោកមេឃុំលើកដែក ដោយចុះពិនិត្យ ច្រាំងបាក់ស្រុតផ្លូវបេតុងចំណុចផ្សារជាប់មាត់ស្ទឹងស្ថិតនៅក្នុងភូមិលើកដែក ឃុំលើកដែក ជាលទ្ធផលសម្រេចជួសជុលបានប្រមាណ ៩០% គាំទ្រដោយក្រុមការងារថ្នាក់ជាតិចុះជួយ ឃុំលើកដែក។
- ចុះបើកទ្វារទឹកលេខ២៤ និងលេខ២៦ អាងទឹកម្លេច ដើម្បីបំពេញអាងទុកបម្រើការស្រោចស្រពលើដំណាំកសិកម្មនៅរដូវប្រាំងឆ្នាំ២០២៣ និងឆ្នាំ២០២៤។
- បានដាក់ស្លាកបង្គោលអ្នកឧបត្ថម្ភស្ពានប្រឡាយជើងក្អែបចំនួន ១៤ស្លាក ក្នុងឃុំលើកដែក។

- បានចូលរួមចុះពិនិត្យ ព្រៃកនៅឃុំពោធិបាន និងឃុំកំពង់កុង ដែលជាលទ្ធផល នៅឃុំពោធិបាន បានទប់ទំនប់ព្រែកស្ទះទឹករួចរាល់ចំនួន ១៣ព្រែក លើក ១៣ព្រែក និងនៅឃុំកំពង់កុង បានទប់ទំនប់ព្រែកស្ទះទឹករួចរាល់ចំនួន ១០ព្រែក លើក ១១ព្រែក។
- បានណែនាំដល់ឃុំឱ្យលាបខ្លាញ់គោ និងប្រេងរំអិលលើដងវ៉ាននៅគ្រប់សំណង់ទ្វារទឹក ហើយនៅគ្រប់ព្រែកទាំងអស់ត្រូវកាប់សម្អាតព្រៃក្នុងព្រែកឱ្យស្អាតមុនទឹកហូរចូល។
- បានចូលរួមចុះពិនិត្យ លើបញ្ហាលុបប្រឡាយដោយគ្មានការអនុញ្ញាត នៅឃុំលើកដែក ត្រង់ចំណុចក្នុងអាងទឹកស្រះ៨ជាប់ផ្លូវ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិព្រែកខ្នាច ឃុំលើកដែក ស្រុកកោះធំ។ ជាងនេះទៀត បានស្រាវជ្រាវរកមុខសញ្ញាលុបប្រឡាយនេះ ដើម្បីជីកស្តារឱ្យដូចស្ថានភាពដើមវិញ ដោយឃើញថាជាលទ្ធផលបច្ចុប្បន្នបានស្តាររួចរាល់ដូចដើមហើយ។ លើសពីនេះទៅទៀត សម្រាប់ការងារជួសជុលទំនប់អាងម្លេច ឃុំលើកដែក ស្រុកកោះធំ បាន១០០% ដោយបានជួសជុលទំនប់ប្រវែង ១០ ០០០ម៉ែត្រ ខ្នង ៦ម៉ែត្រ បាត ២០ម៉ែត្រ កំពស់មធ្យម ១,៥ម៉ែត្រ។ លើសពីនេះទៅទៀត សម្រាប់ការងារស្តារប្រឡាយជើងក្អែបវិញនៅក្នុងឃុំលើកដែកសម្រេចស្តារ និងដាំស្មៅប្រឡាយជើងក្អែបបានចំនួន ២២ខ្សែ (ភូមិ ចំការដូង ភូមិថ្មី និងព្រែកអណ្តូង) ប្រវែង ១០,៨៧៦ម បាន១០០% ដោយបានការជួយឧបត្ថម្ភគម្រោងពីមន្ទីរធនធានទឹក និងឧតុនិយមខេត្ត។[៥១]

## ២.៣. បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅអនុវត្តន៍បន្ត

### ២.៣.១. បញ្ហាប្រឈម និងដំណោះស្រាយ

ក្នុងការរៀបចំអភិវឌ្ឍន៍ប្រទេសជាតិមួយប្រកបដោយ សោភ័ណភាព សណ្តាប់ធ្នាប់ល្អ និងកាន់តែមានភាពរីកចម្រើនទៅមុខយ៉ាងល្អប្រសើរ ហើយប្រជាពលរដ្ឋរស់នៅដោយសុខសុវត្ថិភាព ជាការពិតណាស់មែងតែងតែជួបប្រទះនូវផលវិបាក បញ្ហាប្រឈមមួយចំនួនក្នុងការរៀបចំនោះជាក់ជាមិនខាន។ ទន្ទឹងនឹងការរៀបចំអភិវឌ្ឍន៍មួយនេះ បើទោះបីមានជួបប្រទះការលំបាក និងបញ្ហាប្រឈមយ៉ាងណាក្តី ក៏ថ្នាក់ដឹកនាំនៅតែខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរិះរកដំណោះស្រាយ ដើម្បីដោះស្រាយរាល់បញ្ហាប្រឈមដែលកើតមានឡើងនោះផងដែរ។ ជាក់ស្តែង ឃើញថារដ្ឋបាលស្រុកកោះធំ ក៏បានខិតខំរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្នុងស្រុករបស់ខ្លួនឥតឈប់ឈរ ដើម្បីធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយសុខសុវត្ថិភាព ស្ងប់សុខ

[៥១] របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាល ស្រុកកោះធំ ប្រចាំឆ្នាំ២០២៣

និងមានរបៀបរៀបរយ។ ស្ថិតនៅក្នុងការរៀបចំស្រុកនេះផងដែរ នៅក្នុងស្រុកកោះធំ ក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា៖

### ២.៣.១.១. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរមែងចង់បាននូវការរស់នៅមួយ ដែលល្អប្រសើរ រស់នៅប្រកបដោយសុខសុវត្ថិភាពទាំងផ្លូវកាយ ផ្លូវចិត្ត និងរស់នៅក្នុងមូលដ្ឋានមួយដែលមានសន្តិសុខសណ្តាប់ធ្នាប់ល្អ គ្មានអំពើលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសង ក្មេងទំនើង ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍ជាដើម។ ទន្ទឹមនឹងនេះ ប្រសិនបើនៅក្នុងមូលដ្ឋានមួយមានការកើតមានឡើងនៅអំពើខុសច្បាប់ទាំងអស់នេះ ពិតណាស់នឹងធ្វើឱ្យភូមិ ឃុំ ស្រុកជួបប្រទះទៅនឹងភាពអសន្តិសុខ មានភាពរញ៉េរញ៉ៃ ប្រជាពលរដ្ឋរស់នៅគ្មានភាពស្ងប់សុខ ជាពិសេសធ្វើឱ្យពួកគាត់មានភាពភ័យខ្លាច មានអារម្មណ៍ថាគ្មានសុវត្ថិភាព ក្នុងការរស់នៅផងដែរ។

ស្ថិតក្នុងការៀបចំស្រុកឱ្យមានសន្តិសុខសណ្តាប់ធ្នាប់ល្អ មានការរីកចម្រើន និងដើម្បីធានាទៅដល់សុខសុវត្ថិភាពជូនប្រជាពលរដ្ឋ នៅក្នុងស្រុកកោះធំផ្ទាល់ បានជួបប្រទះនូវបញ្ហាទាក់ទងទៅនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់នេះ ដោយឃើញថាក៏កើតមានឡើងនៅអំពើល្មើសមួយចំនួនផងដែរ។ ដើម្បីជួយពង្រឹងក្នុងការការពារ និងធានានូវផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋានឱ្យកាន់តែរឹងមាំជូនប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសុវត្ថិភាព រដ្ឋបាលស្រុកកោះធំ និងអាជ្ញាធរដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ក៏បានខិតខំប្រឹងប្រែងក្នុងការការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋដែលនៅក្នុងមូលដ្ឋានរបស់ខ្លួនទាំងយប់ទាំងថ្ងៃ ដោយអនុវត្តស្របតាមគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងខិតខំប្រឹងប្រែងរិះរកមធ្យោបាយក្នុងការដោះស្រាយ និងទប់ស្កាត់ទៅតាមសភាពការណ៍បទល្មើសដែលកើតមានឡើងដូចជា៖

- **ករណីលួច** កើតឡើង ២/១ករណី ដោយនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ភូមិចាមលើ ឃុំព្រែកថ្មី រងគ្រោះ ០១នាក់ ដោយចាប់ជនល្មើស ០២នាក់ ចាប់យកម៉ូតូ ០១គ្រឿង និងនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ភូមិព្រែកតាហ៊ីង ឃុំព្រែកថ្មី រងគ្រោះ ០១នាក់ ចាប់ជនល្មើស ០១នាក់។ ក្រោយពេលដែលអាជ្ញាធរបានយកចិត្តទុកដាក់ខិតខំប្រឹងប្រែងចុះបង្ក្រាប និងចាប់ខ្លួនបានជនល្មើសរួចរាល់ហើយអាជ្ញាធរបានកសាងសំណុំរឿងបញ្ជូនខ្លួនជនល្មើសអនុវត្តតាមផ្លូវច្បាប់។ ជាងនេះទៀត អាជ្ញាធរនៅក្នុងស្រុកកោះធំ បានធ្វើការដាក់កម្លាំងក្នុងការយាមល្បាតនៅក្នុងទីតាំងភូមិសាស្ត្រនៅក្នុងស្រុកកោះធំ ដើម្បីធានា និងការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងស្រុករបស់ខ្លួន ជាពិសេសបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យចូលរួមមានការប្រុងប្រយ័ត្ន មើលថែ ទុកដាក់សម្ភារៈ និងរបស់ដែលមានតម្លៃរបស់ខ្លួនឯងឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព។

- **ករណីគ្រឿងញៀន** កម្លាំងជំនាញស្រុក-ប៉ុស្តិ៍រដ្ឋបាលបានសហការចុះបង្ក្រាបបាន ១៥/៩ករណី ចាប់ជនល្មើស ២១/១៥នាក់ ដោយក្នុងនោះបាន ដកហូតគ្រឿងញៀន ៣៨កញ្ចប់ (ធំ៣), ទូរស័ព្ទ ០៦គ្រឿង, ម៉ូតូ ១១គ្រឿង និងសម្ភារៈដែលផេចខ្ចប់ប្រើប្រាស់មួយចំនួន។ បញ្ហាគ្រឿងញៀន ជាបញ្ហាដ៏សំខាន់មួយដែលរដ្ឋបាលស្រុកកោះធំ ក៏ដូចជាកម្លាំងជំនាញពាក់ព័ន្ធ បានធ្វើការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ ដើម្បីកាត់បន្ថយការកើតមានឡើងនៃការជួញដូរ និងការប្រើប្រាស់នូវគ្រឿងញៀនជាបន្តបន្ទាប់ ដោយបានធ្វើការអប់រំ និងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីបញ្ហា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀនតាមរយៈវេទិការសាធារណៈ។ មិនតែប៉ុណ្ណោះ បានអប់រំដល់សិស្សានុសិស្សនៅតាមសាលាឱ្យខិតខំប្រឹងប្រែងក្នុងការរៀនសូត្រ ក្លាយជាធនធានល្អ ពលរដ្ឋល្អនៅក្នុងសង្គម ហើយត្រូវចៀសឱ្យឆ្ងាយពីការប្រើប្រាស់គ្រឿងញៀន ព្រោះថាគ្រឿងញៀន គឺជាសារធាតុដ៏អាក្រក់ដែលអាចធ្វើឱ្យប៉ះពាល់ទៅដល់សុខភាព ហើយអាចធ្វើឱ្យប៉ះពាល់នៅសតិស្មារតី ខាតពេលពេលវេលា ថវិកា គ្មានសុភមង្គលក្នុងក្រុមគ្រួសារ ជាពិសេសធ្វើឱ្យសង្គមស្អប់ខ្ពើមថែមទៀតផង។
- **ករណីក្មេងទំនើង** អាជ្ញាធរបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ចុះបង្ក្រាបបាន ០៣លើក ចំនួន ១៤នាក់ ដោយក្នុងនោះចុះបង្ក្រាបបាន ០៦នាក់ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ភូមិកំពង់សំបូរលើ ឃុំព្រែកថ្មី។ បន្ថែមពីនេះ បង្ក្រាបបាន ០៦នាក់ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣ ភូមិកំពង់សំបូរលើ ឃុំព្រែកថ្មី និងចុះបង្ក្រាបបាន ០២នាក់ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ភូមិកំពង់ស្វាយកណ្តាល ឃុំព្រែកថ្មី។ ក្រោយពេលអាជ្ញាធរបានធ្វើការចុះបង្ក្រាបបានរួចរាល់ចំពោះក្មេងទំនើងទាំងអស់នោះ ហើយអាជ្ញាធរបានធ្វើការអប់រំពន្យល់ណែនាំទៅដល់ក្មេងៗទំនើងទាំងអស់នោះឱ្យឈប់ប្រព្រឹត្តនូវទង្វើដែលអសន្តិសុខធ្វើឱ្យរំខានដល់អ្នកដទៃ ហើយណែនាំឱ្យពួកគេខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីទទួលបានចំណេះដឹងក្លាយជាធនធានល្អមានតម្លៃ ដែលសង្គមត្រូវការ ពេលដែលណែនាំរួចហើយអាជ្ញាធរក៏បានឱ្យពួកគេវិលត្រឡប់ទៅលំនៅឋានវិញ។
- **គ្រោះថ្នាក់ចរាចរណ៍** កើតឡើង ២/៨លើក បណ្តាលឱ្យស្លាប់ ២/៥នាក់, របួស ០/៥នាក់, ខូចខាតម៉ូតូ ២/៧គ្រឿង, រថយន្ត ១/២គ្រឿង ដោយកើតឡើង នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ភូមិកំពង់សំបូរលើ ឃុំព្រែកថ្មី រវាងម៉ូតូ និងរថយន្ត បណ្តាលឱ្យស្លាប់ ០១នាក់ ខូចខាតរថយន្ត ០១គ្រឿង, ម៉ូតូ ០១គ្រឿង ហើយនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ភូមិព្រែកធន់ ឃុំព្រែកថ្មី រវាងម៉ូតូ និងម៉ូតូ ដែលបណ្តាលឱ្យស្លាប់ ០១នាក់ ខូចខាតម៉ូតូ ០១គ្រឿង ដែលគ្រោះថ្នាក់ចរាចរណ៍ខាងលើនេះសុទ្ធសឹងតែកើតឡើងពីការធ្វេសប្រហែស និងខ្វះនៅការប្រុងប្រយ័ត្ននៅពេលធ្វើដំណើរ។ គ្រោះថ្នាក់ចរាចរណ៍ គឺជាគ្រោះថ្នាក់មួយដែលងាយនឹងកើតមានឡើងបំផុតប្រសិនបើអ្នកដំណើរធ្វេសប្រហែស និងខ្វះនូវការប្រុងប្រយ័ត្ននោះវា

អាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯង អ្នកដទៃ ខូចខាតសម្ភារៈ ខាតពេលវេលា ថវិកា ហើយអាចឈានដល់ការបាត់បង់អាយុជីវិតថែមទៀតផង។ ដូច្នេះហើយទើបរដ្ឋបាលស្រុកកោះធំ ក៏ដូចជាអាជ្ញាធរពាក់ព័ន្ធបានខិតខំយកចិត្តទុកដាក់ ក្នុងការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ដោយធ្វើការចុះផ្សព្វផ្សាយច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកទៅដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងកងកម្លាំងប្រដាប់អាវុធផងដែរ។ លើសពីនេះទៅទៀត ក៏បានជួយពន្យល់ណែនាំទៅដល់អ្នកដំណើរឱ្យយល់ដឹងពីស្លាកសញ្ញាចរាចរណ៍ និងបានចុះពិនិត្យណែនាំអ្នកដំណើរដែលបើកបរមិនពាក់មួកសុវត្ថិភាព និងមិនពាក់ខ្សែក្រវាត់ឱ្យបានត្រឹមត្រូវនៅពេលធ្វើដំណើរនៅតាមផ្លូវទីសាធារណៈ។

**២.៣.១.២. បញ្ហាបរិស្ថាន**

បញ្ហាបរិស្ថាន គឺជាបញ្ហាប្រឈមមួយដែលនៅស្រុកកោះធំកំពុងតែជួបប្រទះនូវការលំបាក ក្នុងការរៀបចំស្រុករបស់ខ្លួនដើម្បីទទួលបាននូវសោភ័ណភាពស្រស់ស្អាត សណ្តាប់ធ្នាប់ល្អ និងមានភាពល្អប្រសើរទៅមុខ។ បរិស្ថានដែលមិនស្អាត គឺកើតចេញពីការបំពុលនានា ជាការពិតណាស់ការបំពុលមានច្រើនប្រភេទដែលអាចធ្វើឱ្យប៉ះពាល់ទៅដល់បរិស្ថាន ជាពិសេសប៉ះពាល់ទៅដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស សត្វ និងរុក្ខជាតិថែមទៀតផង។

ជាក់ស្តែង នៅក្នុងស្រុកកោះធំផ្ទាល់ ក៏បានជួបប្រទះនឹងបញ្ហាប្រឈមទាក់ទងនឹងបរិស្ថានខ្លាំងនោះ គឺដោយសារសំរាម ដែលបញ្ហានេះកើតមានឡើងតាមរយៈសកម្មភាពរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋមួយចំនួនមិនបានទុកដាក់សំរាមឱ្យបានត្រឹមត្រូវល្អ ដោយបានបោះចោលសំរាមពាសវាលនៅតាមដងផ្លូវ ជាពិសេសនៅតាមតំបន់ទឹកសាធារណៈ។ តំបន់ទឹកសាធារណៈ សំដៅទៅលើតំបន់ទឹកសម្រាប់ជាសាធារណៈដូចជា ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី។[៥២] ដោយឃើញថាសំរាមខ្លះមានសភាពស្អុយរលួយបង្កក្លិនអាក្រក់ប៉ះពាល់ទៅដល់សុខភាពប្រជាពលរដ្ឋតាមរយៈផ្លូវដង្ហើម ដែលសំរាមខ្លះរលាយ និងខ្លះមិនរលាយ។ ជាងនេះទៅទៀត ការបោះចោលសំរាមនេះបង្កជាការកកស្ទះនៅតាមប្រព័ន្ធទឹក។ សំរាម គឺជាប្រភពមិនល្អដែលធ្វើឱ្យមានការបំពុលកើតឡើង ជាពិសេសការបំពុលទឹក និងសំណល់រឹងរាវជាហេតុធ្វើឱ្យភូមិស្រុកបាត់បង់នូវសោភ័ណភាព សណ្តាប់ធ្នាប់ គ្មានរបៀបរៀបរយ គ្មានអនាម័យ ដែលពោរពេញដោយការបំពុលបរិស្ថាន។

[៥២] អនុក្រឹត្យលេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៣

រដ្ឋបាលស្រុកកោះធំ បានសម្របសម្រួលរៀបចំវគ្គឱ្យមានការអប់រំផ្សព្វផ្សាយ អនុក្រឹត្យលេខ១១៣ ស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលិខិតលេខ ១២៦០ សជណ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២។ រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តន៍នូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន តាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន
- អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយ ការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។[៥៣]

ទន្ទឹមនឹងនេះ ស្រុកកោះធំក៏មានការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានក្នុងស្រុកដោយបានអនុវត្តកម្មវិធីអប់រំបរិស្ថានទូទៅដល់ប្រជាពលរដ្ឋ តាមរយៈធ្វើស្លាកបម្រាមហាមចោលសំរាមនៅទីនេះ និងសហការជាមួយក្រុមប្រឹក្សាឃុំ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សធ្វើពលកម្មសម្អាតបរិស្ថាននៅតាមដងផ្លូវ និងបរិវេណសាលារៀននៅតាមបណ្ដាឃុំនីមួយៗក្នុងមួយសប្ដាហ៍២ដង។ ជាងនេះទៅទៀត ស្រុកកោះធំ ក៏មានក្រុមហ៊ុនប្រមូលសំរាម ០១សម្រាប់ប្រមូលសំរាមជាប្រចាំ គឺក្រុមហ៊ុន លឹមកៅជើងគ្រុប ខូអិលធីឌី ដែលមាននូវរថយន្តសម្រាប់ប្រមូលសំរាមចំនួន ០៤គ្រឿង ដែលក្នុងនោះសេវាប្រមូលសំរាមមានចំនួន ០៣ឃុំ គឺមាននៅឃុំព្រែកថ្មី ឃុំកោះធំ (ខ) និងឃុំកំពង់កុង។ បន្ថែមពីនេះទៅទៀត រដ្ឋបាលស្រុកកោះធំ ក៏បានចូលរួមរាល់សកម្មភាពនានាដូចជា បានធ្វើការផ្សព្វផ្សាយអំពីថ្ងៃនេះ «ខ្ញុំមិនប្រើប្រាស់ថង់ប្លាស្ទិកទេ» ដែលទាក់ទងទៅនឹងសកម្មភាពអនាម័យបរិស្ថានក្នុងរយៈពេល ០១ឆ្នាំនេះ សរុប ២១៣លើក៖

- នៅសាលាស្រុក ៣៥លើក វគ្គមានចូលរួម ១,២៩៨នាក់ ស្រី ៣៥៧នាក់

[៥៣] អនុក្រឹត្យ ស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥, មាត្រា៩

- ឃុំកំពង់កុង ៤២លើក វត្តមានចូលរួម ១,៨៨៧នាក់ ស្រី ៩៥១នាក់
- ឃុំកោះធំ (ក) ២៦លើក វត្តមានចូលរួម ៤៨៤នាក់ ស្រី ១៧០នាក់
- ឃុំកោះធំ (ខ) វត្តមានចូលរួម ៣៦៩នាក់ ស្រី ១២០នាក់
- ឃុំលើកដែក ២១លើក វត្តមានចូលរួម ៣៦២នាក់ ស្រី ២០៤នាក់
- ឃុំពោធិបាន ៣៨លើក វត្តមានចូលរួម ៤៧៣នាក់ ស្រី ១៩០នាក់
- ឃុំព្រែកថ្មី ៣០លើក វត្តមានចូលរួម ៣,២០៦នាក់ ស្រី ១,៦៦១នាក់។[៥៤]

### ២.៣.២. ទិសដៅអនុវត្តន៍បន្ត

រដ្ឋបាលស្រុកកោះធំបានរៀបចំផែនការ ដើម្បីមានភាពងាយស្រួល ច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងការរៀបចំស្រុកប្រកបដោយ សោភ័ណភាព សណ្តាប់ធ្នាប់ល្អ ដែលមានរបៀបរៀបរយ ជាពិសេសនោះដើម្បីធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ប្រកបដោយភាពងាយស្រួល និងមាននូវសុខសុវត្ថិភាព។

#### ២.៣.២.១. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ការរៀបចំផែនការអភិវឌ្ឍន៍ទៅលើការគ្រប់គ្រងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាផ្នែកមួយដ៏សំខាន់ក្នុងការសម្រេចគោលដៅប្រកបដោយភាពល្អប្រសើរ មានភាពរលូនទៅមុខ ដូច្នេះហើយត្រូវលើកកម្ពស់ការផ្តល់សេវាសាធារណៈដែលធានាបានតម្លាភាព ប្រសិទ្ធិភាព សមធម៌ មានជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ និងពង្រឹងសមត្ថភាពប្រកបដោយមនសិការ វិជ្ជាជីវៈរបស់មន្ត្រីរាជការ ដោយបើកវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍ចំពោះស្ថាប័នមុខងាររដ្ឋបាល និងជ្រើសរើសមន្ត្រីបន្ថែម ដើម្បីបម្រើការងារជូនទៅដល់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព ភាពងាយស្រួល និងឆាប់រហ័សផងដែរ។

ជាងនេះទៅទៀត ជួយលើកកម្ពស់ការគោរពច្បាប់ ការការពារសន្តិសុខ សុវត្ថិភាពក្នុងមូលដ្ឋានកាន់តែរឹងមាំ តាមរយៈគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងគ្រឿងញៀន ដោយត្រូវផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកទៅដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ ការយល់ដឹងអំពីស្លាកសញ្ញាចរាចរណ៍ និងចុះពិនិត្យណែនាំអ្នកដំណើរដែលបើកបរមិនពាក់មួកសុវត្ថិភាព មិនពាក់ខ្សែក្រវាត់នូវពេលធ្វើដំណើរនៅតាមផ្លូវទីសាធារណៈ។ លើសពីនេះទៅទៀត ត្រូវផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងកាន់តែច្បាស់អំពីបញ្ហា និងផលប៉ះពាល់ចំពោះគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនដល់ប្រជាពលរដ្ឋ យុវជន

[៥៤] របាយការណ៍ ស្តីពីការអនុវត្តន៍ការងាររដ្ឋបាល ស្រុកកោះធំ ប្រចាំឆ្នាំ២០២៣

សិស្សានុសិស្ស ដោយត្រូវចៀសឆ្ងាយពីការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ ដើម្បីឱ្យក្លាយទៅជាមនុស្សល្អ ប្រជាពលរដ្ឋល្អ ជាធនធានដ៏ល្អនៅក្នុងសង្គមជាតិ។

**២.៣.២.២. ផ្នែកសេដ្ឋកិច្ច**

ត្រូវជួយកសាងស្រុកឱ្យមានភាពជឿនលឿន មានវឌ្ឍនភាពរីកចម្រើនលើគ្រប់វិស័យ មានសាមគ្គីភាពល្អ គោរពច្បាប់ មានសីលធម៌ សេរីភាព យុត្តិធម៌ ជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋឱ្យមានភាពល្អប្រសើរឡើង កាត់បន្ថយភាពក្រីក្រ ការចំណាកស្រុកទៅធ្វើការនៅទីក្រុង ឬក្រៅប្រទេស។ បន្ថែមពីនេះ ជួយការជំរុញការអភិវឌ្ឍស្រុក ដោយយកកសិកម្មជាមូលដ្ឋាន គួបផ្សំជាមួយវិស័យនានា បង្កើនប្រាក់ចំណូលតាមគ្រួសារក្នុងមូលដ្ឋាន ក្នុងនោះផងដែរត្រូវបើកវគ្គសម្រាប់បណ្តុះបណ្តាលបច្ចេកទេស ដំណាំសមស្របតាមបម្រែបម្រួលអាកាសធាតុ ការប្រើប្រាស់ជីគីមី ថ្នាំពុលកសិកម្មកម្ចាត់សត្វល្អិត ការបើកវគ្គផលិតថ្នាំ និងជីបំប៉នផ្សំពីរុក្ខជាតិ ដាំដុះបន្លែសុវត្ថិភាព ដោយផ្សព្វផ្សាយពីការជ្រើសរើសពូជ បន្សុទ្ធពូជ និងព័ត៌មានទីផ្សារទៅដល់ប្រជាកសិករឱ្យយល់ដឹងកាន់តែច្បាស់លាស់។ ជាងនេះទៅទៀត ត្រូវមាននូវការបើកវគ្គសម្រាប់បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម សត្វមាន់ ដែលមានលក្ខណៈជាគ្រួសារ ដោយត្រូវចងក្រងកសិករជាបណ្តុំ ស្រូវ ពោត មាន់ និងបន្លែ ហើយទស្សនៈកិច្ចសិក្សាស្វែកយល់ពីសមាគមន៍ សហគ្រាស និងអាជីវកម្មដែលជោគជ័យ ជាពិសេសផ្សព្វផ្សាយពង្រឹងដេប៉ូលក់សម្ភារៈកសិកម្ម ស្របតាមបទដ្ឋានបច្ចេកទេស និងផ្សព្វផ្សាយគោលនយោបាយនៃការនាំចេញអង្ករផងដែរ។ ជាមួយគ្នានេះដែរ ត្រូវធានាបានការស្តារ ការគ្រប់គ្រង និងថែទាំប្រព័ន្ធស្រោចស្រព ដើម្បីស្រោចស្រពលើផ្ទៃដី ដាំដុះ និងស្រូវគ្រប់រដូវ ដោយត្រូវស្តារនូវប្រឡាយ ព្រែក ជួសជុលទំនប់អាងទឹក ថែទាំទំនប់ និងសាងសង់លូជ្រុងមានទ្វេទឹកទៀតផង។ បន្ថែមពីនេះទៅទៀត ដើម្បីមានភាពងាយស្រួលក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ដូច្នេះត្រូវធានាដល់ការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលចរាចរណ៍ គ្មានទឹកដក់ក្នុងភូមិ តាមផ្លូវ ហើយសាងសង់ផ្លូវលំដី ជួលជុលផ្លូវដោយចាក់បេតុងអាមេ និងដាក់លូរំដោះទឹកអមផ្លូវជាតិលេខ២១ ជាពិសេសនៅតាមផ្លូវជាតិ ផ្លូវលំត្រូវធានាឱ្យមាននូវបង្គោលភ្លើងបំភ្លឺ ដោយដាំបង្គោលភ្លើងនៅតាមគ្រប់ដងផ្លូវធ្វើដំណើរ។

**២.៣.២.៣. ផ្នែកសង្គម**

ការអប់រំ គឺជាគន្លឹះដ៏សំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យក្លាយទៅជាធនធានដ៏មានតម្លៃ មានគុណភាព និងប្រសិទ្ធភាព ក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយភាពរីកចម្រើន។ ដូច្នេះហើយត្រូវលើកទឹកចិត្តការគ្រប់គ្រង ការបង្រៀនក្នុងវិស័យអប់រំគ្រប់កម្រិត ដើម្បីធានាគុណភាពក្នុងការអប់រំ

នេះឱ្យបានល្អប្រសើរ ដោយត្រូវជំរឿនស្ថិតិកុមារគ្រប់អាយុបានចូលរៀន១០០%។ ជាងនេះទៅទៀត ត្រូវសាងសង់អគារសិក្សាថ្មី (សាលាបឋម មធ្យម មត្តេយ្យរដ្ឋ) និងជួសជុលអគារសិក្សាតាមការខូចខាតជាក់ស្តែង ជាពិសេសផ្តល់អាហារូបករណ៍ទៅដល់សិស្សក្រីក្រ ដើម្បីឱ្យសិស្សដែលមានជីវភាពខ្វះខាតអាចចូលរៀនបណ្តុះបណ្តាលចំណេះដឹងនៅក្នុងសាលាដូចសិស្សដែលមានជីវភាពល្អប្រសើរដែរ និងត្រូវផ្សព្វផ្សាយទៅដល់អាណាព្យាបាលឱ្យបញ្ជូនកូនដែលគ្រប់អាយុចូលរៀនឱ្យបានគ្រប់គ្នា។ [៥៥]

ដើម្បីធានាដល់សុខុមាលភាព និងអនាម័យជូនប្រជាពលរដ្ឋត្រូវអនុវត្តន៍បន្តនូវការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព បន្តការស្រាវជ្រាវ និងផ្សព្វផ្សាយពីជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែមដល់ប្រជាពលរដ្ឋ ដើម្បីឱ្យមកទទួលសេវានៅមន្ទីរពេទ្យបង្អែកស្រុកកោះធំ (តាមរយៈបុគ្គលិកមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិ)។ ផ្តល់សេវាពិនិត្យ និងព្យាបាលដល់ស្ត្រី និងគ្រួសារដែលក្រីក្រមិនយកកម្រៃ ហើយបន្តការចុះអប់រំផ្សព្វផ្សាយ និងដាក់ថ្នាំអាបែតនៅតាមសហគមន៍ដែលកើតមានករណីជំងឺគ្រុនឈាម ជាពិសេសជួយឧបត្ថម្ភគ្រួសារស្ត្រីក្រីក្រ ចាស់ជរា ជនពិការ កុមាររងគ្រោះគ្មានទីពឹង និងត្រូវធ្វើការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់។

ដើម្បីរក្សាអនាម័យជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ ត្រូវមានកន្លែងសម្រាប់លាងសម្អាតដៃឱ្យបានត្រឹមត្រូវ និងសង់បង្គន់អនាម័យនៅតាមទីសាធារណៈដូចជា សាលារៀន មន្ទីពេទ្យ វត្តអារាមសម្រាប់ផ្តល់នូវភាពងាយស្រួលជូនប្រជាពលរដ្ឋ។ ជាងនេះទៅទៀត ត្រូវមានកន្លែងទុកដាក់សំរាមត្រឹមត្រូវ ហើយនៅតែបន្តចុះសហការជាមួយរដ្ឋបាលឃុំផ្សព្វផ្សាយសេចក្តីណែនាំរបស់រដ្ឋបាលខេត្ត ស្តីពីការគ្រប់គ្រងសំណល់រឹង រាវ និងការសម្អាតអនាម័យបរិស្ថានតាមបណ្តាទីប្រជុំជន ដើម្បីរួមចំណែកក្នុងការផ្សព្វផ្សាយ និងចុះសហការជាមួយនឹងរដ្ឋបាលឃុំ និងនៅតាមសាលារៀនផ្សព្វផ្សាយអំពី (ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ)។[៥៦]

---

[៥៥] សៀវភៅ ផែនការអភិវឌ្ឍន៍ ស្រុកកោះធំ ឆ្នាំ២០២០-២០២៤

[៥៦] របាយការណ៍ ស្តីពីការអនុវត្តការងាររដ្ឋបាល ស្រុកកោះធំ ប្រចាំឆ្នាំ២០២៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ **ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ ខេត្តកណ្តាល** កន្លងមកនេះឃើញថា ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ គឺជាផ្នែកដ៏សំខាន់ និងចាំបាច់ក្នុងការជំរុញឱ្យមានការអភិវឌ្ឍសម្រេចទៅបានជោគជ័យ ប្រកបដោយភាពរីកចម្រើន។ យ៉ាងណាមិញ ការរៀបចំស្រុកកោះធំ អាចដំណើរការបានយ៉ាងល្អប្រសើរ លុះត្រាតែមានការចូលរួមសហការពីសំណាក់រដ្ឋបាលស្រុកកោះធំ អាជ្ញាធរដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋផងដែរ។

ជាការពិតណាស់ ការរៀបចំស្រុកឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អប្រសើរ ប្រកបទៅដោយភាពរីកចម្រើននោះ ស្រុកកោះធំក៏មាននូវរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងស្រុករបស់ខ្លួន ជាពិសេសបានកសាងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាច្រើនមានដូចជា ប្រព័ន្ធលូ ផ្លូវថ្នល់ បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ ការដាំដើមឈើលម្អបរិស្ថានជាដើម។ ជាងនេះទៀត រដ្ឋបាលស្រុកកោះធំ បានគិតគូរពីសុខសុវត្ថិភាពដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក ដោយបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តតាមគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និងធានាមិនឱ្យមានអំពើអសន្តិសុខកើតមាននៅក្នុងមូលដ្ឋាន។ បន្ថែមពីនេះ ក៏បានចូលរួមនិងផ្សព្វផ្សាយអំពីការថែរក្សាបរិស្ថានក្នុងស្រុក និងផលប៉ះពាល់ចំពោះការបំពុលបរិស្ថានផងដែរ។

យ៉ាងណាមិញ ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណា ស្តីពី**ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ ខេត្តកណ្តាល** ធ្វើឱ្យមានការយល់កាន់តែច្បាស់អំពីបុព្វហេតុ និងសារៈសំខាន់ដែលនាំឱ្យមានការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់របស់ស្រុកកោះធំនេះផងដែរ។ ការរៀបចំស្រុកកោះធំនេះមិនត្រឹមតែធ្វើឱ្យស្រុកមានសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងភាពស្រស់ស្អាតនោះទេ គឺថែមទាំងធ្វើឱ្យស្រុកមានភាពទាក់ទាញមួយកម្រិតទៀត។ លើសពីនេះ ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់បានធ្វើឱ្យស្រុកមានការអភិវឌ្ឍស្ទើរគ្រប់វិស័យដូចជា វិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យកសិកម្ម វិស័យសុខាភិបាល វិស័យអប់រំ និងវិស័យធនធានទឹក ព្រមទាំងបានផ្តល់នូវទំនុកចិត្តជូនដល់ប្រជាពលរដ្ឋឱ្យរស់នៅប្រកបដោយភាពសុខដុមរមនា និងមានភាពស៊ីវិល័យថែមទៀតផង។

សរុបសេចក្តីមក យើងអាចសន្និដ្ឋានបានថាការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ស្រុកកោះធំ ខេត្តកណ្តាល គឺពិតជាមានសារៈសំខាន់ កាលណាបើការរៀបចំនោះស្របទៅតាមលក្ខណៈស្តង់ដាបច្ចេកទេស និងត្រឹមត្រូវទៅតាមផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍ ដោយត្រូវមានការចូលរួមសហការពីសំណាក់រដ្ឋបាលស្រុក អាជ្ញាធរដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកផ្ទាល់តែម្តង នោះនឹងនាំឱ្យស្រុកមានសោភ័ណភាព សណ្តាប់ធ្នាប់ល្អ របៀបរៀបរយ និងប្រកបដោយភាពរីកចម្រើនទៅមុខជាក់ជាមិនខាន។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើនេះ និងពិនិត្យមើលតាមស្ថានភាពជាក់ស្តែងនៅក្នុងស្រុកកោះធំរួចមក យើងសង្កេតឃើញមានការអភិវឌ្ឍ ការរីកចម្រើនយ៉ាងគួឱ្យកត់សម្គាល់ មានដូចជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍវិស័យគមនាគមន៍ វិស័យកសិកម្ម វិស័យធារាសាស្ត្រ រួមទាំងការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ បរិស្ថាន និងសំណង់ជាច្រើនទៀត។ បើទោះបីជា មានការអភិវឌ្ឍយ៉ាងនេះក្តីក៏នៅមានបញ្ហាមួយចំនួនទៀត ដែលអាជ្ញាធរស្រុកបាននឹងកំពុងអនុវត្តន៍ហាក់បីដូចជាពុំសូវទទួលបានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរនៅឡើយនោះទេ ក្នុងការទប់ស្កាត់នៅបញ្ហាដែលកើតមានឡើងជាយូរមកហើយនោះ ដែលអាចបង្កជាផលលំបាកខ្លះសម្រាប់ការអភិវឌ្ឍ ប៉ុន្តែទោះជាយ៉ាងនេះក្តី បញ្ហាទាំងអស់នោះត្រូវបានរដ្ឋបាលស្រុកកោះធំ ក៏ដូចជាថ្នាក់ដឹកនាំរបស់រដ្ឋាភិបាលបានយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យការអភិវឌ្ឍបានដំណើរការយ៉ាងរលូន។

ដើម្បីចូលរួមដោះស្រាយបញ្ហាខាងក្រោមនេះ នាងខ្ញុំទាំងពីរនាក់សូមអនុញ្ញាតសំណូមពរដូចតទៅៈ

- ស្នើសុំឱ្យអាជ្ញាធរយកចិត្តទុកដាក់ទៅលើគ្រោះធម្មជាតិដូចជា ការបាក់ច្រាំងទន្លេ ឬស្រុតដីជាដើម ដោយស្វែងរកដំណោះស្រាយ ឬផ្សព្វផ្សាយពីគ្រោះធម្មជាតិទៅកាន់ប្រជាពលរដ្ឋដែលរស់នៅតាមច្រាំងទន្លេ ឬរស់នៅលើផ្ទៃទឹកដើម្បីស្វែងរកទីទួលសុវត្ថិភាព និងទប់ស្កាត់ជាមុន។
- ស្នើសុំឱ្យអាជ្ញាធរដែលពាក់ព័ន្ធក្នុងស្រុកកោះធំ សូមជួយពង្រឹងអំពីបញ្ហាអសន្តិសុខដូចជា អំពើចោរកម្ម ការលួច ឆក់ ប្លន់ ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន។ ជាងនេះទៅទៀត បញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដោយអនុវត្តស្របតាមគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពឱ្យបានតឹងរឹងជាទីបំផុត ដើម្បីធានាដល់សុខសុវត្ថិភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- ស្នើសុំឱ្យអាជ្ញាធរមានការយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថាននៅក្នុងស្រុករួមមានដូចជា ការទុកដាក់សំរាម ការប្រមូល ការដឹកជញ្ជូន និងផ្សព្វផ្សាយពីបញ្ហាបរិស្ថានផងដែរ។

ទន្ទឹមនឹងការអភិវឌ្ឍនេះ សូមឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកកោះធំទាំងអស់ចូលរួម នៅក្នុងសកម្មភាពថែរក្សាការពារ បរិស្ថាន អនាម័យ ដើម្បីឱ្យតំបន់នោះអាចប្រែក្លាយជាតំបន់ដែលទទួលបានបរិស្ថានល្អប្រសើរ និងដើម្បីការរស់នៅដែលប្រកបទៅដោយផាសុកភាព និងអនាម័យ សូមប្រជាពលរដ្ឋរស់នៅក្នុងស្រុកទាំងអស់យកចិត្តទុកដាក់ និងបើកចិត្តទទួលយកការអប់រំពីថ្នាក់ដឹកនាំស្រុក សូមគោរពទៅតាមសេចក្តីប្រកាស ការណែនាំ ព្រមទាំងអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួន។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២២, លេខ នស/រកម/០៦២២/០០៥, ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២
- ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៩, លេខ នស/រកម/០១១៩/០០៤, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩
- ច្បាប់ ស្តីពីសហគមន៍កសិកម្ម, លេខ នស/រកម/០៦១៣/០០៨, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៣
- ច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០១៦, ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧
- ច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម, លេខ នស/រកម/០៦៩៩/០៨, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០០០
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រង់សំណល់រឹង, លេខ ៣៦ អមក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អ.ន.ក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩
- គោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព, លេខ ០១ គនប, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១
- របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាល ស្រុកកោះធំ ប្រចាំខែមីនា ឆ្នាំ២០២៤

- របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាល ស្រុកកោះធំ ប្រចាំឆ្នាំ២០២៣
- ឯកសារព័ត៌មានស្ថានភាព ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ស្រុកកោះធំ ឆ្នាំ២០២៤

## ២. ឯកសារយោងជាសៀវភៅតែខនិពន្ធ

- វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជ ជួនណាត
- សៀវភៅ នីតិនគររូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្តដា បោះពុម្ពឆ្នាំ២០២៣
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលស្រុក, ក្រសួងមហាផ្ទៃ, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២
- សៀវភៅណែនាំ ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ខែសីហា ឆ្នាំ២០១៤
- សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ស្រុក, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ខែមីនា ឆ្នាំ២០១៧
- សៀវភៅ ផែនការអភិវឌ្ឍន៍ ស្រុកកោះធំ ឆ្នាំ២០២០-២០២៤
- សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល ស្រុកកោះធំ ឆ្នាំ២០២៤-២០២៦

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័រ https://www.popular.com.kh/tours/127956.html/
- គេហទំព័រ https://www.kandal.gov.kh/detail/16054
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/
- គេហទំព័រ http://www.healthcambodia.com/p6241/
- គេហទំព័រ https://freshnewsasia.com/index.php/en/localnews/241433-2022-05-08-11-45-48.html
- គេហទំព័រ https://www.cpp.org.kh/details/349851
- គេហទំព័រ https://freshnewsasia.com/index.php/en/localnews/276051-2023-01-31-14-18-26.html
- គេហទំព័រ https://www.mpwt.gov.kh/en/press/3337
- គេហទំព័រ https://www.kandal.gov.kh/detail/11354
- គេហទំព័រ https://moh.gov.kh/archives/2863
- គេហទំព័រ https://freshnewsasia.com/index.php/en/localnews/276051-2023-01-31-14-18-26.html

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២២, លេខ នស/រកម/០៦២២/០០៥, ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី២៖** ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៩, លេខ នស/រកម/០១១៩/០០៤, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៣៖** ច្បាប់ ស្តីពីសហគមន៍កសិកម្ម, លេខ នស/រកម/០៦១៣/០០៨, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ ២០១៣

**ឧបសម្ព័ន្ធទី៤៖** ច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/ ០៦០៧/០១៦, ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧

**ឧបសម្ព័ន្ធទី៥៖** ច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម, លេខ នស/រកម/០៦៩៩/ ០៨, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩

**ឧបសម្ព័ន្ធទី៦៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

**ឧបសម្ព័ន្ធទី៧៖** អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

**ឧបសម្ព័ន្ធទី៨៖** អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

**ឧបសម្ព័ន្ធទី៩៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ៣៦ អមក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

**ឧបសម្ព័ន្ធទី១០៖** អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អ.ន.ក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩

**ឧបសម្ព័ន្ធទី១១៖** គោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព, លេខ ០១ គនប, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីរដ្ឋបាលស្រុកកោះធំ នៃខេត្តកណ្ដាល

**ឧបសម្ព័ន្ធទី២៖** ទីតាំងសំខាន់ៗនៅស្រុកកោះធំ

**ឧបសម្ព័ន្ធទី៣៖** សកម្មភាពរដ្ឋបាលស្រុកកោះធំ

**ឧបសម្ព័ន្ធទី៤៖** សោភ័ណភាពពេលថ្ងៃ និងសោភ័ណភាពពេលយប់

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/០៦២២/០០៥

## យើង

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ១០៥
ថ្ងៃ: ព្រ. ទី ៨ ខែ មិថុនា ឆ្នាំ២០២២
ម៉ោង: ១០:១៥ នាទី

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ២១៧/០០២/២០២២ កបធ.ច ចុះថ្ងៃទី២[illegible] ខែឧសភា ឆ្នាំ២០២២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី
## ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
## ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ
## នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រាមួយ.-**

មាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១៤០.- ថ្មី**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើន១១(ដប់មួយ)រូប។

គណៈអភិបាលខេត្តមានចំនួនពី៧(ប្រាំពីរ)រូប ទៅ១១(ដប់មួយ)រូប។

គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពី៥(ប្រាំ)រូប ទៅ៧(ប្រាំពីរ)រូប។

ចំនួនជាក់ស្តែងនៃគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ៤កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២២

នរម.០៦០៦.២០៧

(ហត្ថលេខា) នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

# ព្រះរាជក្រម

នស/រកម/០១១៩/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៨/០០១/២០១៩ កបធ.ច ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

## ច្បាប់
## ស្តីពី
## វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រាមួយ.-**

មាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ១៨.- ថ្មី**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ ដូចខាងក្រោម ៖

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃប្រាំពីរ (២៧) រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីដប់ប្រាំ (១៥) រូប ដល់ម្ភៃប្រាំពីរ (២៧) រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីដប់មួយ (១១) រូប ដល់ម្ភៃមួយ (២១) រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីដប់មួយ (១១) រូប ដល់ម្ភៃមួយ (២១) រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០) ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៩

នស/រកម. ០១១៩-០០៤

(ហត្ថលេខា)

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

(ហត្ថលេខា និងត្រា)

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

Copy

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
... សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ចូល លេខ ១៨៤៦ ថ្ងៃទី ២៤/០៦ ឆ្នាំ២០១៣ ម៉ោង ... បញ្ជូនទៅ ...

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីសហគមន៍កសិកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៣ នា សម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

# ស្ដីពី

# សហគមន៍កសិកម្ម

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់ការចូលរួមដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានមុខរបរចម្បងក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬ សេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ក្នុងការបង្កើតនិងការអភិវឌ្ឍសហគមន៍កសិកម្មសំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការបង្កើត ការប្រព្រឹត្តទៅ និងការគ្រប់គ្រង ព្រមទាំងយន្តការគាំទ្រសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

សហគមន៍កសិកម្មជានីតិបុគ្គលឯកជនមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដែលបង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម តាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន រួមគ្នាធ្វើម្ចាស់ និងរួមគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ ដើម្បីពង្រីកសមត្ថភាពផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក ស្របតាមគោលការណ៍គ្រឹះមានដូចខាងក្រោម ៖

- ការចូលរួមដោយស្ម័គ្រចិត្តនិងបើកចំហសមាជិកភាព
- ការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដោយសមាជិក
- ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក
- ស្វ័យភាពនិងឯករាជ្យ
- ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន
- ការធ្វើសហប្រតិបត្តិការជាមួយសហគមន៍កសិកម្មផ្សេងទៀត
- ការគិតគូរដល់សហគមន៍ ។

**មាត្រា ៥.-**

ពាក្យពេចន៍ដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

Ksl

# ជំពូកទី ២
# យន្តការគាំទ្រសហគមន៍កសិកម្ម
## ផ្នែកទី ១
## ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម

**មាត្រា ៦.-**

ត្រូវបង្កើតក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាជិកជាតំណាងមកពីទីស្តីការគណៈរដ្ឋមន្ត្រី តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រសួង ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្ម តំណាងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិលនិងប្រធានអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្មមានលេខាធិការដ្ឋានមួយនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្មមានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- សិក្សាស្រាវជ្រាវ ពិគ្រោះយោបល់ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ពន្ធ័នឹងការអភិវឌ្ឍសហគមន៍កសិកម្ម ដោយអនុលោមតាមលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គម
- លើកសំណើជូនរាជរដ្ឋាភិបាលដើម្បីសុំការសម្រេចលើគោលនយោបាយជាតិស្តីពីការអភិវឌ្ឍសហគមន៍កសិកម្ម
- តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីការងារសម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្ម
- កំណត់ទិសដៅក្នុងការលើកកម្ពស់និងពង្រឹងសមត្ថភាពនិងការជំរុញកិច្ចសហប្រតិបត្តិការរបស់សហគមន៍កសិកម្មជាមួយផ្នែកឯកជននិងដៃគូអភិវឌ្ឍនានា
- សម្របសម្រួលរវាងស្ថាប័នរដ្ឋពាក់ព័ន្ធ ផ្នែកឯកជន និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីជំរុញទ្រទ្រង់ដល់ប្រតិបត្តិការរបស់សហគមន៍កសិកម្ម
- ចេញសេចក្តីសម្រេចឬសេចក្តីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត ក្នុងការដាក់ឱ្យអនុវត្តកម្មវិធីការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលពាក់ព័ន្ធនឹងគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអភិវឌ្ឍសហគមន៍កសិកម្ម

- ដោះស្រាយបញ្ហាឬឧបសគ្គដែលរាំងស្ទះដល់ការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍសហគមន៍កសិកម្ម

- ធ្វើរបាយការណ៍ជាប្រចាំជូនរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការអភិវឌ្ឍសហគមន៍កសិកម្ម

- បំពេញមុខងារផ្សេងទៀតដែលគាំទ្រដល់គោលនយោបាយអភិវឌ្ឍសហគមន៍កសិកម្ម ក្រោមវិសាលភាពនៃច្បាប់នេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្មត្រូវកំណត់ ដោយអនុក្រឹត្យ ។

## ផ្នែកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៨.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការជំរុញនិងគាំទ្រក្នុងការបង្កើត ការចុះបញ្ជី ប្រតិបត្តិការនិងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវមាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ស្ថិតនៅក្រោមអគ្គនាយកដ្ឋានកសិកម្ម ដើម្បីទទួលបន្ទុកការងារអភិវឌ្ឍន៍សហគមន៍កសិកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បំពេញសមត្ថកិច្ចក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍កសិកម្ម ដោយអនុលោមតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៩.-**

ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍កសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបំពេញបេសកកម្មដូចខាងក្រោម ៖

- ជំរុញនិងគាំទ្រការប្រព្រឹត្តទៅ ការប្រតិបត្តិ និងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម

- សិក្សា រៀបចំគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត ផែនការយុទ្ធសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ការជំរុញ ការពង្រឹងសមត្ថភាពនិងការអភិវឌ្ឍសហគមន៍កសិកម្ម

- កំណត់អង្គភាពទទួលបន្ទុកការងារចុះបញ្ជីនិងគ្រប់គ្រងទិន្នន័យសហគមន៍កសិកម្ម

- ផ្តល់សេវាកម្មបណ្តុះបណ្តាលដល់សហគមន៍កសិកម្មនិងភ្នាក់ងារអភិវឌ្ឍសហគមន៍កសិកម្ម

- អនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងនិងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម

- កំណត់ទម្រង់បញ្ជីគណនេយ្យរបស់សហគមន៍កសិកម្ម ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- សម្របសម្រួលរវាងសហគមន៍កសិកម្មជាមួយផ្នែកឯកជនឬផ្នែកពាក់ព័ន្ធផ្សេងទៀតនៅក្នុងប្រទេសឬក្រៅប្រទេស

- សិក្សានិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍កសិកម្មដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ព្រមទាំងផ្តល់ព័ត៌មានទីផ្សារកសិផលដល់សហគមន៍កសិកម្ម

- ធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិស្តីពីសហគមន៍កសិកម្ម

- ជ្រើសរើសសវនករឬអ្នកត្រួតពិនិត្យនិងអ្នកជម្រះបញ្ជីក្នុងករណីដែលសហគមន៍កសិកម្មណាមួយត្រូវបានរំលាយ

- តាមដាននិងវាយតម្លៃការប្រព្រឹត្តទៅនិងប្រតិបត្តិការរបស់សហគមន៍កសិកម្ម

- ចូលរួមដោះស្រាយពាល់ទំនាស់របស់សហគមន៍កសិកម្ម

- បំពេញភារកិច្ចផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍កសិកម្មក្រោមវិសាលភាពនៃច្បាប់នេះ ។

**មាត្រា ១០.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍កសិកម្ម ដើម្បីសិក្សាស្រាវជ្រាវនិងកសាងសមត្ថភាពបច្ចេកទេសសហគមន៍កសិកម្មក្នុងក្របខ័ណ្ឌជាតិឬអន្តរជាតិ ។

## ផ្នែកទី ៣
## មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម

**មាត្រា ១១.-**

ត្រូវបង្កើតមូលនិធិអភិវឌ្ឍសហគមន៍កសិកម្មដែលសរសេរជាអក្សរកាត់ថា "**ម.អ.ស.**" ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការគាំទ្រនិងការអភិវឌ្ឍសហគមន៍កសិកម្ម ។

មូលនិធិអភិវឌ្ឍសហគមន៍កសិកម្មត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន និងមានសមាជិកជាប្រធានឬតំណាងអង្គភាពពាក់ព័ន្ធចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និង មានអនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មមួយរូបជាសមាជិកអចិន្ត្រៃយ៍ និងជាលេខាធិការនៃ **ម.អ.ស.** ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍសហគមន៍កសិកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។

Kol

**មាត្រា ១២.-**

មូលនិធិអភិវឌ្ឍសហគមន៍កសិកម្មមានថវិកានិងទ្រព្យសម្បត្តិដែលមានប្រភពដូចខាងក្រោម ៖

១- វិភាគទានធនពីរដ្ឋ ។

២- អំណោយសប្បុរសជនជាថវិកាឬទ្រព្យសម្បត្តិ ។

៣- ហិរញ្ញប្បទានពីរដ្ឋឬពីប្រភពផ្សេងៗទៀត ។

៤- ការលក់ទ្រព្យសម្បត្តិដែលបានមកពីចំណុច(២)និង(៣) ។

៥- ការចូលរួមវិភាគទានរបស់សហគមន៍កសិកម្មដែលទទួលបានផលប្រយោជន៍ដោយផ្ទាល់ពី **ម.អ.ស.** ។

ថវិកានិងទ្រព្យសម្បត្តិរបស់ **ម.អ.ស.** ដូចបានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះត្រូវបានរក្សាទុកក្រោមគណនីរបស់ **ម.អ.ស.** ។

## ផ្នែកទី ៤
## ស្ថាប័នពាក់ព័ន្ធចំពោះសហគមន៍កសិកម្ម

**មាត្រា ១៣.-**

ក្រសួង ស្ថាប័នរដ្ឋដែលពាក់ព័ន្ធមានភារកិច្ចជួយគាំទ្រក្នុងដែនសមត្ថកិច្ចរបស់ខ្លួនចំពោះរាល់សកម្មភាពនិងប្រតិបត្តិការរបស់សហគមន៍កសិកម្ម តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ១៤.-**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ក្រោមដែនសមត្ថកិច្ចរបស់ខ្លួនត្រូវមានភារកិច្ចជួយដល់សហគមន៍កសិកម្មដូចខាងក្រោម ៖

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនិងបង្កលក្ខណៈងាយស្រួលដល់ការបង្កើតនិងការអភិវឌ្ឍសហគមន៍កសិកម្មនៅក្នុងមូលដ្ឋានសាមី
- បញ្ជាក់លើពាក្យស្នើសុំចុះបញ្ជីសហគមន៍កសិកម្ម
- ឧបត្ថម្ភ គាំទ្រទាំងផ្នែកស្មារតី ទាំងផ្នែកសម្ភារៈដល់ការអភិវឌ្ឍសហគមន៍កសិកម្ម
- សហការ សម្របសម្រួលជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនិងមន្ទីរកសិកម្មក្នុង ការបង្កើតនិងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម
- ចូលរួមដោះស្រាយរាល់ទំនាស់ដែលកើតឡើងនៅក្នុងដំណើរការរបស់សហគមន៍កសិកម្ម
- ចូលរួមតាមដាននិងវាយតម្លៃលើប្រតិបត្តិការនិងការអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្ម ។

**មាត្រា ១៥.-**

សហគមន៍កសិកម្ម ត្រូវទទួលបានការលើកទឹកចិត្តនិងសិទ្ធិអនុគ្រោះពីរាជរដ្ឋាភិបាលដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ក្លែងឯកសារចុះបញ្ជី ក្លែងស្លាកសម្គាល់ផលិតផល ក្លែងសំបកសម្រាប់វេចខ្ចប់ផលិតផល ឬក្លែងឯកសារផ្សេងទៀតរបស់សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មនៅក្នុងប្រតិបត្តិការមុខរបររបស់ខ្លួន ។

**មាត្រា ១១១.–**

មន្ត្រីទទួលបន្ទុកការចុះបញ្ជីសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដែលរំលោភលើតួនាទីរបស់ខ្លួនក្នុងការចុះបញ្ជីដែលផ្ទុយនឹងបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ១១២.–**

នៅក្រោយពេលដែលច្បាប់នេះចូលជាធរមាន លិខិតបទដ្ឋានដែលមានស្រាប់ ហើយដែលមិនខ្ទាស់នឹងច្បាប់នេះ ត្រូវបន្តអនុវត្តរហូតដល់មានលិខិតបទដ្ឋានថ្មីមកជំនួស ហើយរាល់កម្មវិធីនិងសកម្មភាពដែលទាក់ទងនឹងការងារសហគមន៍កសិកម្ម ត្រូវមានសុពលភាពរហូតថ្ងៃផុតកំណត់នៃកម្មវិធីនិងសកម្មភាពនោះ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ១១៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១៤.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣

នស/រកម/០៦១៣/០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ហត្ថលេខា

ច័ន្ទ សារុន

លេខៈ ៤៩១ ស.ណ

សំណៅដែលមានត្រឹមត្រូវតាមច្បាប់ដើមសម្រាប់ការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

# ព្រះរាជក្រម

នស/រកម/០៦០៧/០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងធនធានទឹកនៅក្នុង
# ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ ។

ច្បាប់នេះកំណត់ :

-សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក

-គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក

-ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព ។

**មាត្រា ២.-**

ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា :

-ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស ។

-ធនធានទឹក គឺសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក ។

-ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូច ធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ។

-ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី ។

-អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី ។

-អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ ។

-ទន្លេអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះរាជវាំង

-ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹកនៅក្នុងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬ អង្គធាតុដទៃទៀតដែលជាប់នៅនឹងច្រាំងនោះ ដោយមិនរាប់បញ្ចូលនូវដី ថ្ម ឬ អង្គធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះទេ ។

-ឆ្នេរ សមុទ្រ ទន្លេ ស្ទឹងគឺចំណែកដី ឬ ខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល ។

-បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹកដែលគ្របដណ្តប់ដោយទឹក ។

-តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គិសនី ការបំរើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឱ្យមានធារទឹកអប្បបរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្ស ជីវិតមច្ឆាជាតិ និងរុក្ខជាតិនានា ។

-ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វៀរ ទំនប់បញ្ឈប់ទឹក ទំនប់ការពារទឹកជំនន់ ប្រឡាយដោះទឹកធំតូច ប្រព័ន្ធស្រោចស្រព អាងទឹកធំ តូច ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គិសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទឹកប្រើប្រាស់ អភិរក្ស ការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹក ការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក ។

-អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឱ្យដល់បុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍ ។

-បុគ្គល គឺរូបវន្តបុគ្គល ឬ នីតិបុគ្គលទោះក្នុងន័យជាឯកជន ឬ សាធារណៈក៏ដោយ ។

**មាត្រា ៣.-**

ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ ។

៖

**មាត្រា ៤.-**

ទឹក និងធនធានទឹកត្រូវបានគ្រប់គ្រង និងអភិវឌ្ឍដោយផ្អែកទៅលើវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះ ។

វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះនេះ នឹងពិចារណាទៅលើ :

-គ្រប់ទិដ្ឋភាពទាំងអស់នៃធនធានទឹក

-ទំនាក់ទំនងរវាងធនធានទឹក និងទិដ្ឋភាពដទៃទៀតនៃបរិស្ថានធម្មជាតិ

-តម្រូវការប្រើប្រាស់ទឹកសំរាប់មនុស្ស បរិស្ថាន និងវិស័យផ្សេងទៀត ដើម្បីឱ្យមាននិរន្តរភាព និងប្រសិទ្ធភាព ។

ការអនុវត្តនីវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះ ត្រូវធ្វើក្នុងពេលតែមួយ និងក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរវាងរាល់ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៥.-**

ក្រសួងធនធានទឹក និងឧតុនិយមមានភារកិច្ចគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យ ក្នុងការអនុវត្តនីច្បាប់នេះ ។ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយនឹងក្រសួងពាក់ព័ន្ធនានា ។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចនឹងបង្កើតគណៈកម្មការចំរុះចំពោះមុខដើម្បីដោះស្រាយ និងសំរបសំរួលការងាររវាងបណ្តាក្រសួងពាក់ពន្ធ័ ។

**មាត្រា ៦.-**

ក្នុងការអនុវត្តនីច្បាប់គ្រប់គ្រងធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម ត្រូវកំណត់គោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹក ស្របតាមតម្រូវការរបស់តំបន់នីមួយៗនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងទិសដៅធានានិរន្តរភាពធនធានទឹក និងប្រសិទ្ធ-ភាពក្នុងការប្រើប្រាស់ទឹក ដើម្បីជៀសវាងមហន្តរាយ និងវិវាទផ្សេងៗ ។

ការបែងចែកតំបន់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹកត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

ការសហការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អ្នកទទួលផលគ្រប់ប្រភេទ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ នឹងត្រូវបានជំរុញដោយរាជរដ្ឋាភិបាល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

/.

**មាត្រា ៣៧.-**

បុគ្គលណាដែលបង្កឱ្យមានការខូចខាតដល់សំណង់ការងារទឹកសាធារណៈ នឹងត្រូវទទួលការផ្តន្ទាទោសទៅតាមក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣៨.-**

បន្ថែមលើទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រាខាងលើ ជនល្មើសត្រូវរុះរើចេញនូវប្រភេទសំណង់ ដែលខ្លួនបានសាងសង់ និងរៀបចំផ្លូវលំហូរទឹកទន្លេឱ្យបានដូចស្ថានភាពដើមវិញ ហើយឧបករណ៍ គ្រឿងចក្រដែលពាក់ព័ន្ធនឹងបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៣៩.-**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយមដែលបានសមគំនិតជាមួយជនល្មើស ឬ ជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើស ត្រូវទទួលទោសចំពោះមុខច្បាប់ ។

## **ជំពូកទី ១១**

## **អវសានប្បញ្ញត្តិ**

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៧០៦.២៧៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

**ហត្ថលេខា**

**លឹម គានហោ**

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ... ខែ ... ឆ្នាំ២០០៧

ប៊ុន ឈិនកេន

18/18

# ព្រះរាជក្រម

នស/រកម/០៦៩៩/០៨

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- ទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ ជំពូកទី ១៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជា ណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី ១

នីតិកាលទី ១ ហើយនិងដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របទាំងស្រុងនឹងរដ្ឋធម្មនុញ្ញ មានសេចក្តីទាំងស្រុងដូចតទៅ:

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

**មាត្រា ១ :** ត្រូវបានបង្កើតក្រសួងធនធានទឹក និងឧតុនិយម ចំណុះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ :** ក្រសួងធនធានទឹក និងឧតុនិយមមានសមត្ថភាពដឹកនាំ និងគ្រប់គ្រង លើវិស័យធនធានទឹក និងឧតុនិយម នៃព្រះរាជាណាចក្រ កម្ពុជា ។

**មាត្រា ៣ :** ក្រសួងធនធានទឹក និងឧតុនិយមត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការ និង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤ :** ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយមត្រូវកំណត់ ដោយអនុក្រឹត្យ ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១១៣..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច
## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យដាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# ផ្នែកទី២
# អំពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក

**មាត្រា ១៣៦.-**

ក្រុមប្រឹក្សាស្រុក ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម ។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ ។

**មាត្រា ១៣៧.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាស្រុកអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឡើយ ។

ក្រុមប្រឹក្សាស្រុក អាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលស្រុក ។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលស្រុក ។

**មាត្រា ១៣៨.-**

ក្រុមប្រឹក្សាស្រុក អាចតែងតាំងសមាជិកក្រុមប្រឹក្សាស្រុក អភិបាលស្រុក អភិបាលរងស្រុក តំណាងក្រុមប្រឹក្សាឃុំ តំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាស្រុក តំណាងសហគមន៍ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់សម្រាប់ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង ។

ក្រុមប្រឹក្សាស្រុក ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង ។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងប្រធាន ឬអនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង ។

ក្រុមប្រឹក្សាស្រុក អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចាំបាច់ឬតាមសំណើរបស់គណៈកម្មាធិការឬគណៈអភិបាលស្រុក។

**មាត្រា ១៣៩.-**

គណៈអភិបាលស្រុក អាចស្នើសុំក្រុមប្រឹក្សាស្រុកដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលស្រុក។

**មាត្រា ១៤០.-**

ក្រុមប្រឹក្សាស្រុក ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានានិងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

**មាត្រា ១៤១.-**

ក្រុមប្រឹក្សាស្រុក ត្រូវណែនាំឱ្យគណៈអភិបាលស្រុកផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង។

**មាត្រា ១៤២.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលស្រុក ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនក្រុមប្រឹក្សា។

ក្រុមប្រឹក្សាស្រុក អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកតាមការចាំបាច់របស់ខ្លួន។

## ផ្នែកទី៣

## គណៈអភិបាលស្រុក

**មាត្រា ១៤៣.-**

ស្រុកនីមួយៗ ត្រូវមានគណៈអភិបាលមួយដែលរួមមាន អភិបាល អភិបាលរង ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៤៤.-**

អភិបាល អភិបាលរងស្រុក មិនមែនជាសមាជិកក្រុមប្រឹក្សាស្រុកឡើយ។

**មាត្រា ១៤៥.-**

គណៈអភិបាលស្រុក ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុកនិងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៤៦.-**

គណៈអភិបាលស្រុក មានភារកិច្ចផ្ដល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាស្រុក និងជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាស្រុក ទាំងសេចក្ដីសម្រេចខាងបញ្ញត្តិនិងសេចក្ដីសម្រេចខាងប្រតិបត្តិ។

**មាត្រា ១៤៧.-**

គណៈអភិបាលស្រុក ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្ដល់យោបល់ជូនក្រុមប្រឹក្សាស្រុកអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាស្រុកនិងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រនិងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឬបានផ្ទេរស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ស្រុក
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុសម្រាប់ការិយាល័យនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យនិងអនុម័ត មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :

+ ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាស្រុកនិងសកម្មភាព លទ្ធផលនៃការអនុវត្ត
+ របាយការណ៍ហិរញ្ញវត្ថុ
+ ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលនិងបុគ្គលិក
+ វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
+ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
+ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាស្រុកយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការវាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក និងតម្រូវការគាំទ្រចំពោះឃុំសង្កាត់ក្នុងស្រុក
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាននិងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចសហការនិងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុករបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១៤៨.-**

នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច ដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលស្រុកត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាស្រុកនិងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៤៩.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៤៧និងមាត្រា១៤៨នៃអនុក្រឹត្យនេះ និងការងារដទៃទៀត ដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលស្រុកត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលស្រុករបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចនិងគោលការណ៍

ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលស្រុក ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាស្រុកអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងស្រុក ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលស្រុកលើភារកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលស្រុកត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលស្រុកអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ១៥០.-**

គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាស្រុក ការសម្រេចឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេចឬសកម្មភាពខាងលើនេះ។

**មាត្រា ១៥១.-**

គណៈអភិបាលស្រុក ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលស្រុកនិងអភិបាលរងស្រុក ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលស្រុក អភិបាលរងស្រុក និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ១៥២.-**

អភិបាលស្រុក ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាស្រុកចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣១នៃអនុក្រឹត្យនេះ។

អភិបាលស្រុក អាចប្រគល់សិទ្ធិដល់អភិបាលរងស្រុកក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងស្រុកនីមួយៗ។

អភិបាលស្រុកត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងស្រុក។

អភិបាលស្រុក មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងស្រុកណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលស្រុកត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ១៥៣.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងស្រុក អភិបាលស្រុក មានភារកិច្ច ៖

- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលស្រុកត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក អភិបាលស្រុកត្រូវសម្របសម្រួលតម្រង់ទិសការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាស្រុក។
- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យអង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាស្រុកជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យនិងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំក្នុងស្រុករបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលស្រុកត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី។
- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងស្រុករបស់ខ្លួនឬករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលស្រុកត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរនិងជាបន្ទាន់ទៅអភិបាលខេត្ត។ អភិបាលខេត្ត ត្រូវណែនាំដល់មន្ទីរ

អង្គភាពខ្សែបណ្ដោយសាមីនៅថ្នាក់ខេត្តឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារ ដែលមានការចូលរួមពីតំណាងស្រុកពាក់ព័ន្ធ ឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី ។

- អភិបាលស្រុកមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្ដូរឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន ។

ដើម្បីធានាឱ្យអភិបាលស្រុកអនុវត្តនូវភារកិច្ចខាងលើនេះ សេចក្ដីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅស្រុក ត្រូវដាក់ជូនអភិបាលស្រុកដើម្បីពិនិត្យនិងផ្ដល់យោបល់ ។ ប្រសិនបើអភិបាលស្រុកឯកភាព អភិបាលត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយប្រធានការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ ។ ចំពោះសេចក្ដីរាយការណ៍ក្រៅពីនោះរបស់ការិយាល័យ អង្គភាពនិងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ត្រូវចម្លងជូនសាលាស្រុក ។

**មាត្រា ១៥៤.-**

អភិបាលស្រុកត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលក្នុងការថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុក អំពីច្បាប់និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងស្រុក ។

អភិបាលស្រុក គឺជាប្រធានគណៈបញ្ជាការឯកភាពស្រុក ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្ដាប់ធ្នាប់និងរបៀបរៀបរយសាធារណៈនៅក្នុងស្រុក ។

**មាត្រា ១៥៥.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៥៣និងមាត្រា១៥៤នៃអនុក្រឹត្យនេះ អភិបាលស្រុកត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយខ្លួនក្នុងការងារខាងលើនេះ ។

អភិបាលរងស្រុកដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលស្រុក ។

អភិបាលស្រុក ត្រូវកោះប្រជុំគណៈអភិបាលតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលស្រុក សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងក្រសួង ស្ថាប័ននានា ។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ ។

ក្នុងការសិក្សាខាងលើនេះ គ.ជ.អ.ប. ត្រូវធ្វើការពិគ្រោះយោបល់និងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំយុទ្ធសាស្ត្រ និងដំណាក់កាលសមស្របក្នុងដំណើរការធ្វើសមាហរណកម្មនេះ ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

### មាត្រា ២១១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

### មាត្រា ២១២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៩ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ខ-តែងតាំងផ្លាស់ប្តូរមុខងារ :

១-ឧត្តមសេនីយ៍ទោ ពុត សំអោន អត្តលេខ ០០០១៦៣ នាយក នាយកដ្ឋានបុគ្គលិក បច្ចុប្បន្ន ជាទីប្រឹក្សា ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ត្រី ថ្រាំ ស៊ូ អត្តលេខ ០០៣៨០៥ បច្ចុប្បន្ន ជាទីប្រឹក្សាក្រសួងការពារជាតិ

៣-ឧត្តមសេនីយ៍ត្រី ទិតិន ជាតិ អត្តលេខ ០០០១១០ បច្ចុប្បន្ន ជាទីប្រឹក្សាក្រសួងការពារជាតិ

គ-តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ :

-ឧត្តមសេនីយ៍ត្រី មាស សំអុល អត្តលេខ ០០០២១១ នាយករង នាយកដ្ឋានបុគ្គលិក បច្ចុប្បន្ន ជានាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ

ឃ-តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-វរសេនីយ៍ឯក យៀង គឹមសួរ អត្តលេខ ០០០៨៩៥ នាយករង ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ឯក មាស សក្តិ អត្តលេខ ០០០៧៨៧ នាយករង អធិការកិច្ច អគ្គបញ្ជាការដ្ឋាន

៣-វរសេនីយ៍ឯក ពេជ្រ សុផា អត្តលេខ ០០០៣២០ នាយករង សាលានាយទាហានចំរុះ អគ្គបញ្ជាការដ្ឋាន

៤-វរសេនីយ៍ឯក ជាន់ សាមឆ្លា អត្តលេខ ០០១១៨៨ នាយករង នាយកដ្ឋាន សោធនទិវត្តន៍

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

**អនុក្រឹត្យ លេខ ៤២ អនក្រ.បក**

**ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់**

**និងការរំខានដោយសំលេង**

***

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម /·០១៩៤ / ២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រង ធនធានធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០០ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងដើម្បីទប់ស្កាត់ និងកាត់បន្ថយគុណធាតុដែលបំពុលខ្យល់ និងសំឡេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយ ដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំឡេងនៅក្នុងបរិយាកាស ។

**មាត្រា ៣ .-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែង ជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង ល្អងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុគ្រោះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុសធ្យូង ឬសារធាតុគីមីផ្សេងៗទៀតដែលមានប្រតិកម្មចំហេះ ។

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសារធាតុបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤ .-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥ .-**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាង ឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦ .-**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងមាត្រា៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ នឹងត្រូវ ពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តង តាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧ .-**

កំរិតកំណត់ស្តង់ដារបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំឡេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និង ឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨ .-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និង ឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩ .-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំឡេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមាន ចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

# អនុក្រឹត្យ លេខ ៣៦ អនក្រ.បក
# ស្ដីពីការគ្រប់គ្រងសំណល់រឹង

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-** អនុក្រឹត្យនេះ មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេស សមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវចំរុះ ។

**មាត្រា ២ .-** អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្ដុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣ .-** និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក- "**សំណល់រឹង** " គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬត្រូវអោយបោះបង់ចោល ។

ខ- "**សំរាម** " គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅដ្ឋាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ ល ។

ត- "សំណល់ប្រកបដោយគ្រោះថ្នាក់" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្ក អោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬ សារធាតុគីមីដទៃទៀត ដែលអាចនាំអោយមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និង សេវាកម្មអាជីវកម្មដ៏ ។ ល ។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## ការគ្រប់គ្រងសំរាម

មាត្រា ៤ .- ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពីគោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាម ប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

មាត្រា ៥ .- ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី១ នៃមាត្រា ៥ នេះ ត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៦ .- ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

មាត្រា ៧ .- ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរ មានសមត្ថកិច្ច ។

មាត្រា ៨ .- ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន ។

មាត្រា ៩ .- ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលើកណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

មាត្រា ១០ .-ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៧ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១** អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២** អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

**មាត្រា ៣** និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក- " **តំបន់ទឹកសាធារណៈ** " : គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្ដូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ- " **ប្រភពបំពុល** " : គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូននិងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្ដី ឬមិនផ្ទាល់ក្ដី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្ដាញលូសាធារណៈ ។

គ- " **សំណល់រាវ** " : គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្ដាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្ដី ។

ឃ- " **ទឹកល្អ** " : គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង- " **សំណល់រឹង** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច- " **សំរាម** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ- " **សារធាតុបំពុល** " ៖ គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទ ដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជាៈ ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹក ដោយចេតនាក្តី ឬអចេតនាក្តី ។

ជ- " **បរិមាណសារធាតុបំពុល** " ៖ គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅ ដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ- " **សារធាតុប្រកបដោយគ្រោះថ្នាក់** " ៖ គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមាន គ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយ ប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុង តារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់ និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤** កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាង ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥** ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្ស ជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦** ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយ ដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១ គនប

# គោលនយោបាយ

## «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើងមានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានា នៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឱ្យជនគ្រប់រូប និងសង្គមទាំងមូល មានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។

ឆ្លងកាត់បទពិសោធន៍អស់រយៈពេល១០ឆ្នាំ ក្រសួងមហាផ្ទៃដោយមានការគាំទ្រ និងចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋាន និងអ្នកពាក់ព័ន្ធ បានចាត់តាំងអនុវត្តប្រកបដោយជោគជ័យ និងបានធ្វើការកែលម្អផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ជាបន្តបន្ទាប់ ឱ្យស្របតាមបរិបទនៃការអភិវឌ្ឍរីកចម្រើនរបស់សង្គមជាតិ។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឱ្យមានការចូលរួមគាំទ្រកាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរ ដូចខាងក្រោម៖

១. បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងពគស្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

២. កសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

## I. លក្ខណសម្បត្តិរបស់ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

**១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។**

**២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។**

**៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។**

**៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។**

**៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។**

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ។**

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងរាល់ជំងឺឆ្លងពាក់ព័ន្ធការងារសាធារណៈប្រកបដោយប្រសិទ្ធភាព ។**

## II. វិធានការជាមូលដ្ឋាន

លក្ខណសម្បត្តិទាំង០៧យ៉ាង នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានចាត់តាំងអនុវត្តតាមវិធានការជាមូលដ្ឋានដូចខាងក្រោម៖

**១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត៖**

ចាត់វិធានការឱ្យបានហ្មត់ចត់ និងទាន់ពេលវេលាក្នុងការលើកកម្ពស់ការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននានានៅគ្រប់វិស័យ នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ទាំងផ្នែកបរិមាណ គុណភាព ប្រសិទ្ធភាព តម្លាភាព ពោលគឺជំរុញឱ្យការផ្តល់សេវា និងកិច្ចអន្តរាគមន៍នានាកាន់តែកៀកកិតនឹងប្រជាពលរដ្ឋ សំដៅបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋកាន់តែច្រើនឡើង។

**២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ៖**

- ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំអំពីច្បាប់ពាក់ព័ន្ធ និងផលប៉ះពាល់នានាដែលបណ្តាលមកពីបទល្មើសគ្រប់ប្រភេទ ជាពិសេសអំពើ លួច ឆក់ ប្លន់ ចាប់ជំរិតយកប្រាក់ ការប្រើប្រាស់អាវុធខុសច្បាប់ និងល្បែង

ស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសធនធានធម្មជាតិ និងបរិស្ថាន ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់។

- ត្រូវចាត់វិធានការក្នុងការបង្ការ ទប់ស្កាត់ឱ្យបានជាអតិបរមានូវការចរាចរ ការចែកចាយ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ព្រមទាំងខិតខំលុបបំបាត់ការដាំដុះ ការរក្សាទុក ការលួចកែច្នៃសារធាតុញៀនគ្រប់ប្រភេទតាមគ្រប់រូបភាពនៅតាមភូមិ ឃុំ សង្កាត់។

- ត្រូវជំរុញបំផុសចលនាអប់រំមហាជនដើម្បីចូលរួមបង្ការ ទប់ស្កាត់បទល្មើសគ្រឿងញៀនគ្រប់ប្រភេទ ជាពិសេសអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវខ្លឹមសារទិសស្លោក «បីកុំ-មួយរាយការណ៍» ៖

❖ **បីកុំ ៖**

- **កុំពាក់ព័ន្ធ** ៖ កុំជួញដូរ កុំចែកចាយ កុំធ្វើខ្នងបង្អែក កុំឃុបឃិតនិងកុំប្រើប្រាស់គ្រឿងញៀន។
- **កុំអន្តរាគមន៍** ៖ កុំរាំងការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ទោះបីជាក្រុមគ្រួសារ សាច់ញាតិ ឬមិត្តភ័ក្រក៏ដោយ។
- **កុំលើកលែង** ៖ កុំបន្ធូរបន្ថយការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ។ សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ និងស្មោះត្រង់វិជ្ជាជីវៈរបស់ខ្លួន ហើយជនគ្រប់រូបត្រូវគោរព និងអនុវត្តច្បាប់។

❖ **មួយរាយការណ៍៖** ត្រូវរាយការណ៍ ផ្តល់ព័ត៌មានដល់សមត្ថកិច្ចអំពីមុខសញ្ញាជួញដូរ ចែកចាយ ប្រើប្រាស់ ទីតាំងកែច្នៃ ផលិត និងទីតាំងស្តុកទុកគ្រឿងញៀន។

- ត្រូវសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ អនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន យុទ្ធសាស្ត្រទាំង០៥ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន បទបញ្ជាសារាចរណែនាំ និងផែនការយុទ្ធនាការក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាលតាមគ្រប់ដំណាក់កាល។

- ត្រូវជំរុញឱ្យមានការបំផុសចលនាចូលរួមសហការ គាំទ្រពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

### ៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍

- ជំរុញការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋាននានា ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមា នូវហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ រួមទាំងអ្នកស្លាប់ និងរបួស ដោយត្រូវចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់ តាមផែនការយុទ្ធនាការរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងផែនការសកម្មភាពរបស់អនុគណៈកម្មការទី២ នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

- ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ នៅទីប្រជុំជន តំបន់ផ្សារ នៅលើដងផ្លូវ និងតាមចិញ្ចើមផ្លូវ ដើម្បីសម្រួលដល់ការធ្វើដំណើរទៅមករបស់អ្នកប្រើប្រាស់ផ្លូវ និងជាពិសេសរួមចំណែកដល់ការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ដែលបណ្តាលមកពីគ្មានសណ្តាប់ធ្នាប់សាធារណៈ។

**៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង៖**

- ចាត់វិធានការឱ្យបានជាអតិបរមាដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់អំពើអនាចារ អំពើរំលោភសេពសន្ថវៈ ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ អំពើហិង្សាក្នុងគ្រួសារដើម្បីការពារសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋឱ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ដោយអនុវត្តឱ្យបានហ្មត់ចត់តាមច្បាប់ និងផែនការយុទ្ធសាស្ត្រជាតិរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

- ត្រូវចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់ និងជាប្រចាំ តាមស្មារតីនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល សេចក្ដីណែនាំរបស់ក្រសួងមហាផ្ទៃ និងផែនការ សកម្មភាពរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធដល់វិធានការក្នុងការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង។

**៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ៖**

- ពង្រឹងការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទនៅមូលដ្ឋាន នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ព្រមទាំងពង្រឹងសមត្ថភាព និងបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ សំដៅលើកកម្ពស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមយន្តការផ្សះផ្សា ឬសម្របសម្រួលដែលកំណត់ដោយក្រសួងយុត្តិធម៌។

- ខិតខំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ ជាពិសេសភាគីវិវាទ ឱ្យយល់អំពីខ្លឹមសារ និងសារសំខាន់នៃយន្តការ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងគោលដៅកាត់បន្ថយការកកស្ទះសំណុំរឿងនៅស្ថាប័នតុលាការ ការខាតបង់ពេលវេលា ថវិកាផ្ទាល់ខ្លួននិងការចំណាយថវិការដ្ឋ ព្រមទាំងបង្កើតភាពសុខដុមរមនាក្នុងសង្គម។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ៖**

- មានវិធានការក្នុងការគ្រប់គ្រង ថែរក្សា និងការពារធនធានធម្មជាតិ និងបរិស្ថាន អនាម័យក្នុងភូមិ ឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព ជាពិសេសយន្តការដោះស្រាយបញ្ហាសំរាម សំណល់រឹង និងសំណល់រាវ សំដៅធ្វើឱ្យភូមិ ឃុំ សង្កាត់ មានសោភ័ណភាព គ្មានសំរាម ធ្វើឱ្យការរស់នៅប្រកបដោយផាសុកភាព មានភាពថ្លៃថ្នូរ ស៊ីវិល័យ និងមានអនាគតរុងរឿង ផ្អែកតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ។

- បញ្ជ្រាបការអប់រំដល់ប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានា ស្ដីពីកិច្ចការពារថែរក្សាបរិស្ថាន រួមទាំងវិធីសាស្ត្រនៃការរក្សាសុខភាព ការចូលរួមថែរក្សាអនាម័យ សុវត្ថិភាពចំណីអាហារ ឧទាហរណ៍៖ ការផលិតស្រាឧសបទដ្ឋានបច្ចេកទេស ការចែកចាយ លក់ដូរ និងប្រើប្រាស់ថ្នាំពេទ្យ គ្រឿងសម្អាង... ក្លែងក្លាយ ឬអត់គុណភាព។

### ៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព៖

- រួមគ្នាចាត់វិធានការឆ្លើយតប និងផ្តល់ព័ត៌មានគ្រប់ឱ្យបានទាន់ពេលវេលា ក្នុងការកាត់បន្ថយនូវហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានាដែលកើតមានឡើងនៅក្នុងមូលដ្ឋាន ឧទាហរណ៍៖ ជំងឺកូវីដ-១៩...។

- ត្រូវបំផុសចលនាមហាជនដើម្បីចូលរួមនៅក្នុងការបង្ការ ទប់ស្កាត់ ការពារជំងឺឆ្លងរាតត្បាតកាចសាហាវ និងគ្រោះមហន្តរាយដែលបាននិងបម្រុងកើតឡើងជាយថាហេតុ។

## III. វិស័យការសន្តិភាព

### ១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព និងតម្លាភាពទទួលបានជំនឿទុកចិត្ត៖

- យកចិត្តទុកដាក់លើកកម្ពស់ក្នុងការផ្តល់សេវាសាធារណៈចាំបាច់ និងជាមូលដ្ឋាន រួមមាន ការអប់រំ សុខាភិបាល ផ្លូវគមនាគមន៍ ទឹកស្អាត អគ្គិសនី និងសេវាសាធារណៈចាំបាច់ដទៃទៀតដែលពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងសមធម៌។

- ពង្រឹង និងពង្រីកការអនុវត្តតួនាទីរបស់ការិយាល័យច្រកចេញ-ចូលតែមួយ និងយន្តការច្រកចេញ-ចូលតែមួយ លើការងារផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរថែមទៀត។ រៀបចំឱ្យមានអ្នកទទួលខុសត្រូវច្បាស់លាស់ក្នុងការប្រចាំការដោះស្រាយការស្នើសុំសេវានានារបស់ប្រជាពលរដ្ឋ ឱ្យបានទាន់ពេលវេលា ឆាប់រហ័ស មានប្រសិទ្ធភាព និងតម្លាភាព។

### ២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ៖

- ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ បញ្ជាដឹកនាំការអនុវត្តផែនការប្រយុទ្ធប្រឆាំងបទល្មើសពិសេស អំពើលួច ឆក់ ប្លន់ ចាប់ជំរិតទារប្រាក់នៅតាមភូមិ ឃុំ សង្កាត់។

- លើកកម្ពស់គុណភាព និងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ សំដៅបង្កើនប្រសិទ្ធភាពក្នុងការស្រាវជ្រាវស៊ើបអង្កេត ព្រមទាំងជំរុញសកម្មភាពតាមចាប់មុខសញ្ញា និងអនុវត្តដីកាដែលសេសសល់ ។

- តាមដាន ត្រួតពិនិត្យ និងដឹកនាំតម្រង់ទិសដល់នគរបាលប៉ុស្តិ៍រដ្ឋបាល ក្នុងការអនុវត្តការងារតាមបែបនគរបាលនិងសហគមន៍។

- យកចិត្តទុកដាក់គាំទ្រដល់ប៉ុស្តិ៍នគរបាលរដ្ឋបាល ទាំងស្មារតី សម្ភារ ការពង្រឹងសមត្ថភាព ដើម្បីមានលទ្ធភាពក្នុងការគ្រប់គ្រងស្ថានការណ៍សន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់។

- ពង្រឹងប្រជាការពារ ដើម្បីចូលរួមក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន និងលើកកម្ពស់កិច្ចសហការជាមួយកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើតឱ្យមានយន្តការផ្លាស់ប្តូរព័ត៌មាន និងគាំទ្រគ្នាទៅវិញទៅមក ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

- រៀបចំផែនការបង្ការ ទប់ស្កាត់ បង្ក្រាប សកម្មភាពលួចនាំសារធាតុញៀនខុសច្បាប់គ្រប់ប្រភេទ តាមច្រកព្រំដែន និងច្រករបៀងនៃប្រទេសជិតខាងចូលមកកម្ពុជា និងការរក្សាទុក ឬលួចកែច្នៃសារធាតុញៀនសំយោគគ្រប់ប្រភេទ។

- ជំរុញសកម្មភាពក្នុងការអនុវត្តផែនការផ្ទៃបាលស្របជាមួយនឹងផែនការច្បាប់ ក្នុងការស្រាវជ្រាវតាមដាន ត្រួតពិនិត្យ ការលួចជួញដូរ និងប្រើប្រាស់សារធាតុញៀននៅតាមទីតាំងសប្បាយដ្ឋាននានា និងនៅតាមភូមិ ឃុំ សង្កាត់។

- ជំរុញការផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ តាមសាលារៀន និងបញ្ជ្រាបការអប់រំនៅតាមពិធីផ្សេងៗដែលប្រារព្ធធ្វើឡើងនៅតាមមូលដ្ឋាន អំពីគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន។

- ខិតខំស្រាវជ្រាវ និងបង្ក្រាបឱ្យបានការលួចដាំដុះដំណាំដែលមានសារធាតុញៀននៅគ្រប់ភូមិសាស្ត្រ។

- បង្កើនការផ្លាស់ប្តូរព័ត៌មានជាមួយដៃគូជាតិ អន្តរជាតិ សំដៅម្ចាស់ការក្នុងការបង្ការ ទប់ស្កាត់ពីចម្ងាយ និងសហការស្រាវជ្រាវកាត់ផ្តាច់ខ្សែរយៈ និងជាពិសេសតាមចាប់មេខ្លោងមកផ្តន្ទាទោសតាមច្បាប់។

### ៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍

- បង្កើនការអប់រំ ផ្សព្វផ្សាយអំពីច្បាប់ និងផលប៉ះពាល់នានាដែលបណ្តាលមកពីការមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដោយត្រូវមានវិធីសាស្ត្រផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព មានជាអាទិ៍ កម្មវិធីសាសនា សិល្បៈ កម្មវិធីអភិវឌ្ឍន៍ វេទិកាសាធារណៈ និងកម្មវិធីផ្សេងៗក្នុងសង្គម។

- រៀបចំសណ្តាប់ធ្នាប់ឱ្យបានល្អនៅតំបន់មានផ្សារ ទីប្រជុំជន សាលារៀន និងតំបន់ស្មុគស្មាញនានា ត្រូវហាមឃាត់ការដាក់តាំងលក់ទំនិញនៅលើដងផ្លូវ ការចតយានយន្តគ្រប់ប្រភេទដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរ។ ចំពោះទីតាំងធ្វើអាជីវកម្ម សេវាកម្ម ត្រូវរៀបចំឱ្យមានចំណតសម្រាប់មធ្យោបាយនិងយានយន្តគ្រប់ប្រភេទ ដើម្បីបញ្ចៀសនូវការកកស្ទះចរាចរណ៍ និងការបាត់បង់សណ្តាប់ធ្នាប់។ ត្រូវមានផែនការរៀបចំសណ្តាប់ធ្នាប់ និងការឆ្លងកាត់ផ្លូវរបស់សិស្សានុសិស្សពេលម៉ោងចេញ-ចូលសាលារៀន។

### ៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង

- បង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ទាំងបច្ចេកទេសប្រតិបត្តិការ និងនីតិវិធីក្នុងការស្រាវជ្រាវ ស៊ើបអង្កេតប្រយុទ្ធប្រឆាំងអំពើអនាចារ ការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ។

- ខិតខំជំរុញសកម្មភាពស្រាវជ្រាវ ស៊ើបអង្កេតរកមេខ្លោងពាក់ព័ន្ធដល់អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ ព្រមទាំងសកម្មភាពជួញដូរតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប។

- សហការជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជំរុញសកម្មភាពផ្សព្វផ្សាយអប់រំ ការជួយសង្គ្រោះ និងស្តារនីតិសម្បទាដល់ជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

- ពង្រឹងការគ្រប់គ្រង និងស្រាវជ្រាវតាមទីតាំងអាជីវកម្ម សេវាកម្មដែលលួចប្រព្រឹត្តអំពើអនាចារ និងការជួញដូរផ្លូវភេទ។

- ពង្រឹងយន្តការសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ ក្នុងការផ្លាស់ប្តូរព័ត៌មាននានា ពាក់ព័ន្ធដល់សភាពការណ៍ បណ្តាញឧក្រិដ្ឋជន ព្រមទាំងព័ត៌មានដទៃផ្សេងទៀត ពាក់ព័ន្ធដល់ជនរងគ្រោះនៅក្រៅប្រទេស។

- មានកម្មវិធីច្បាស់លាស់ក្នុងការរៀបចំវេទិកាផ្សព្វផ្សាយអប់រំអំពីគុណធម៌ សីលធម៌ វប្បធម៌ និងច្បាប់ពាក់ព័ន្ធ សំដៅកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសកម្មភាពក្មេងទំនើងនៅតាមភូមិ ឃុំ សង្កាត់។

**៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព**

- ខិតខំបង្កើនសមត្ថភាព ចំណេះដឹង និងជំនាញបន្ថែមទៀតដល់អ្នកទទួលសិទ្ធិក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទទួលបាននូវយន្តការផ្សេងៗដែលសមស្របទៅនឹងវិធានច្បាប់ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ កាន់តែទទួលបាននូវជំនឿទុកចិត្តពីប្រជាពលរដ្ឋ។

- ត្រូវខិតខំពង្រឹងអព្យាក្រឹតភាព វិជ្ជាជីវៈរបស់អ្នកសម្របសម្រួល ឱ្យប្រកាន់ខ្ជាប់នូវភាពមិនលំអៀង រក្សាការសម្ងាត់ ដើម្បីបង្កើនភាពជឿជាក់ដល់ភាគីវិវាទ។

- អ្នកសម្របសម្រួល ត្រូវធ្វើកំណត់ហេតុនៃការដោះស្រាយ និងជូនព័ត៌មានអំពីលទ្ធផលនៃដំណោះស្រាយរបស់គូវិវាទ ដែលទទួលយកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការឱ្យបានលឿន និងចំណេញពេលវេលា ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅបានជ្រាប។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ**

- បង្កើនការតាមដាន ត្រួតពិនិត្យនៅតាមទីតាំងសាធារណៈ អំពីការគ្រប់គ្រងអនាម័យ បរិស្ថាន ឈរលើគោលការណ៍ «ការរស់នៅស្អាត ភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ អនាគតរុងរឿង»។

- ទប់ស្កាត់ និងឆ្លើយតបឱ្យបានទាន់ពេលវេលានូវគ្រោះថ្នាក់ដែលបណ្តាលមកពីការពុលចំណីអាហារ និងភេសជ្ជៈនានា ជាពិសេសត្រូវមានការត្រួតពិនិត្យតាំងពីដើមទី ទាំងការនាំចូល ការដាំដុះ និងការផលិត។

- មានផែនការបង្ការ ទប់ស្កាត់ឱ្យបានទាន់ពេលវេលា នូវសកម្មភាពលួចកាប់បំផ្លាញ និងទន្ទ្រានទីតាំងព្រៃឈើនៅក្នុងសហគមន៍ និងសហការជាមួយឧទ្យានុរក្សដើម្បីបង្ការ និងទប់ស្កាត់ការកាប់ទន្ទ្រាននៅតាមតំបន់ការពារធម្មជាតិ។

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតការងារសាធារណៈប្រកបដោយប្រសិទ្ធភាព**

មានផែនការម្ចាស់ការទុកជាមុនក្នុងការសង្គ្រោះបឋមជួយដល់អាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានា។ ត្រូវអប់រំអំពីវិធីការពារ ទប់ស្កាត់ជំងឺឆ្លងរាតត្បាតដែលមានហានិភ័យខ្ពស់ វិធីបង្ការគ្រោះថ្នាក់បណ្តាលមកពីគ្រោះមហន្តរាយ តាមវិធានការនានាដែលកំណត់ដោយក្រសួងជំនាញ។

## IV. **ការចាត់តាំងអនុវត្ត**

១. ក្រសួងមហាផ្ទៃធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលដោយត្រូវ៖

- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងដឹកនាំតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- បង្កើតលេខាធិការដ្ឋានដើម្បីរៀបចំផែនការសកម្មភាព និងតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿនក្នុងការអនុវត្តលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងបូកសរុបវាយតម្លៃ រាយការណ៍តាមដំណាក់កាលនីមួយៗ ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការចាត់តាំងអនុវត្តគោលនយោបាយនេះ។

២. ក្រសួង ស្ថាប័ននានាចំណុះរាជរដ្ឋាភិបាល ត្រូវរៀបចំក្រុមការងារដើម្បីជួយក្នុងការរៀបចំផែនការសកម្មភាព និងជួយតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿនក្នុងការអនុវត្តលក្ខណសម្បត្តិ នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលមានការពាក់ព័ន្ធទៅនឹងវិស័យជំនាញរបស់ក្រសួង ស្ថាប័ននីមួយៗ និងត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃតាមកាលកំណត់។

៣. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមឱ្យបានសកម្ម គាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ឱ្យទទួលបានជោគជ័យ។

៤. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងទទួលខុសត្រូវដឹកនាំផ្ទាល់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវ៖

- រៀបចំលេខាធិការដ្ឋានដោយមានអង្គភាពនគរបាលធ្វើជាសេនាធិការ និងមានសមាសភាពមកពីមន្ទីរ អង្គភាពពាក់ព័ន្ធនានា ព្រមទាំងរៀបចំឱ្យមានក្រុមការងារចុះជួយតាមមូលដ្ឋានឃុំ សង្កាត់ ដោយយកភូមិជាគោលដៅ ដើម្បីសហការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- ជំរុញការផ្សព្វផ្សាយ និងបំផុសចលនាមហាជន ព្រមទាំងផ្នែកពាក់ព័ន្ធ ដើម្បីសហការ និងចូលរួមគាំទ្រ ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- រដ្ឋបាលឃុំ សង្កាត់ត្រូវដាក់បញ្ចូលការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិល ព្រមទាំងក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីជួយគាំទ្រ និងជំរុញការអនុវត្តឱ្យទទួលបានជោគជ័យ។

៥. នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីស្នូលក្នុងការចាត់ចែងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវ៖

- អនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវតួនាទី ភារកិច្ច និងតាមទម្រង់នៃការងារនគរបាលនិងសហគមន៍

- ដឹកនាំពង្រឹងកម្លាំងប្រជាការពារ និងធ្វើការផ្សព្វផ្សាយបំផុសចលនាមហាជន រួមទាំងផ្នែកពាក់ព័ន្ធ ដើម្បីចូលរួមក្នុងចលនាអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- ត្រូវមានកិច្ចសហការ ទំនាក់ទំនងជាមួយកងកម្លាំងសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឱ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសគ្រប់ប្រភេទ ការរៀបចំអនាម័យ បរិស្ថាន កាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីជំងឺឆ្លងរាតត្បាតកាចសាហាវ និងគ្រោះមហន្តរាយនានាក្នុងភូមិ ឃុំ សង្កាត់។

៦. វេទិកាសាធារណៈ និងការផ្សព្វផ្សាយ៖

ត្រូវរៀបចំឱ្យមានវេទិកាសាធារណៈ និងវេទិកាផ្សព្វផ្សាយអំពីគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដើម្បីបញ្ជ្រាបការយល់ដឹង និងបំផុសឱ្យមានការសហការ ចូលរួមគាំទ្រពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋនៅទូទាំងប្រទេស៖

- ការរៀបចំវេទិកាសាធារណៈ គួរខិតខំរៀបចំឱ្យបានញឹកញាប់តាមរូបភាពតូចៗ យ៉ាងហោចណាស់ក្នុង០១ខែ ឱ្យបានម្តង ដោយក្នុងវេទិកានេះ ត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធទៅនឹងលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងត្រូវខិតខំដោះស្រាយរាល់បញ្ហាប្រឈមនានាដែលបានលើកឡើង ព្រមទាំងផ្តល់ព័ត៌មានឆ្លើយតបឱ្យបានសមស្របជូនប្រជាពលរដ្ឋវិញ។ ក្នុងករណីដោះស្រាយមិនបាន ត្រូវរាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីមានវិធានការដោះស្រាយបន្ត។

- ការផ្សព្វផ្សាយគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» គួររៀបចំឱ្យបានញឹកញាប់តាមរូបភាពតូចៗជាក់ស្តែងទៅតាមភូមិសាស្ត្រនីមួយៗ សំដៅផ្សព្វផ្សាយចំគោលដៅ មុខសញ្ញា និងបង្កលក្ខណៈដល់អ្នកចូលរួមមានឱកាសបំពេញមុខរបរផង និងអាចទទួលបានការផ្សព្វផ្សាយដោយផ្ទាល់ផងដែរ។

៧. ការប្រឡងប្រណាំង៖

ត្រូវចាត់តាំងឱ្យមានចលនាប្រឡងប្រណាំងបង្កើតស្នាដៃប្រចាំឆ្នាំនីមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញកាតព្វកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ។

៨. គ្រប់ក្រសួង ស្ថាប័ន និងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ត្រូវចាត់តាំងប្រជុំបូកសរុប រយៈពេលយ៉ាងយូរ០៦ខែម្តង ដើម្បីមានមូលដ្ឋានក្នុងការវាយតម្លៃ ដកពិសោធន៍ និងដាក់ចេញទិសដៅអនុវត្តបន្ត។

ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

៩. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃអង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

១០.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានការគិតគូរគ្រោងថវិកាសម្រាប់អនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» នៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗ។

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានយកទៅផ្សព្វផ្សាយទូលំទូលាយទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋដើម្បីយល់ជ្រួតជ្រាប និងចូលរួមគាំទ្រអនុវត្តប្រកបដោយជោគជ័យ។

ថ្ងៃ អង្គារ ១៣ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សម្តេច ឯកឧត្តម លោកជំទាវប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
-គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អាជ្ញាធរ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ក្រោមជាតិ
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលស្រុកកោះធំ




ផែនទីរដ្ឋបាលស្រុកកោះធំ

## ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗមួយចំនួននៅក្នុងស្រុកកោះធំ (ខេត្ត កណ្ដាល)




សាលាស្រុកកោះធំ





ទីតាំង៖ មន្ទីរពេទ្យតេជោសែនកោះធំ





ទីតាំង៖ កីឡដ្ឋាន ស្រុកកោះធំ





ទីតាំង៖ ស្ពានមិត្តភាពកម្ពុជា~ចិន កោះធំ (ឬហៅថា ស្ពានកោះធំ)





ទីតាំង៖ វត្តទួលរាជា






ទីតាំង៖ កំពង់ចម្លង ស្រុកកោះធំ






ទីតាំង៖ ផ្សារទីរួមស្រុកកោះធំ

# ឧបសម្ព័ន្ធទី៣៖ សកម្មភាពរដ្ឋបាលស្រុកកោះធំ





សកម្មភាព៖ រដ្ឋបាលស្រុកកោះធំ ដាំដើមឈើលំអបរិស្ថាន






សកម្មភាព៖ រដ្ឋបាលស្រុកកោះធំ ចុះផ្សព្វផ្សាយការងារបរិស្ថាន "ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ"





សកម្មភាព៖ ចុះសម្អាតអនាម័យ និងបរិស្ថានក្នុងបរិវេនសាលាស្រុកកោះធំ





សកម្មភាពៈ ចុះត្រួតពិនិត្យ ការបើកការដ្ឋានលើកកម្រិត និងជួសជុលផ្លូវ





សកម្មភាពៈ ចុះបើកការដ្ឋានសាងស្ពានបេតុងសរសៃដែក





សកម្មភាពៈ អាជ្ញាធរចុះរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ





សកម្មភាព៖ ចុះសួរសុខទុក្ខ និងនាំយកអំណោយជូនប្រជាពលរដ្ឋក្រីក្រជួបទុក្ខលំបាក





សកម្មភាព៖ បណ្តុះបណ្តាល និងអនុវត្តន៍ផ្ទាល់ ការដាំបន្លែសុវត្ថិភាព





សកម្មភាព៖ ចុះពិនិត្យស្ថានភាព ដំណាំស្រូវ

# ឧបសម្ព័ន្ធទី៤៖ សោភ័ណភាពពេលថ្ងៃ និងសោភ័ណពេលយប់ស្រុកកោះធំ








សោភ័ណភាពពេលថ្ងៃ







សោភ័ណភាពពេលយប់